# ព្រះពុទ្ធសាសនា នៅប្រទេសចិន

# លទ្ធិកុម្មុយនិស្តចិន និង ព្រះពុទ្ធសាសនា



ព្រះចៅអធិរាជចុងក្រោយបំផុត នៃប្រទេសចិន
ព្រះនាម ពូ-យី

LIBRARY
BUDDHIST INSTITUTE

២៣៧.

២៣៧.
៤

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh     www.elibraryofcambodia.org

www.budinst.gov.kh   www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

២៣៧.៤

# ព្រះពុទ្ធសាសនា
# នៅប្រទេសចិន

## លទ្ធិកុម្មុយនិស្តចិន
## និង
## ព្រះពុទ្ធសាសនា

និពន្ធដោយ

ទ្រិញ - ទ៉ាញ

LIBRARY
BUDDHIST INSTITUTE
៦០២៨/០២

ការផ្សាយរបស់សមាគមសម្ដេច ជួន - ណាត
លេខ ៩៨ វិថីតេជោដាំឌិន ក្រុងភ្នំពេញ

ទូរស័ព្ទលេខ ២.៥០៦៣

ព.ស. ២៥១៦ គ.ស. ១៩៧៣

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

នៅក្នុងសង្គ្រាមរវាងចិនជាតិនិយម និងចិនកុម្មុយនិស្ត ពួកចិនជាតិនិយមបានលើកយកនយោបាយបំផ្លាញព្រះពុទ្ធសាសនា ដែលពួកកុម្មុយនិស្តចិនបានធ្វើនោះ មកឃោសនាប្រឆាំងវិញ ព្រោះព្រះពុទ្ធសាសនាជាចំណុចសំខាន់បំផុតក្នុងចិត្តគំនិត និងអធ្យាស្រ័យនៃប្រជារាស្ត្រចិនភាគច្រើន ។

សាធារណរដ្ឋចិនប្រជាមានិតដោយយល់ឃើញថា ពុំអាចយកជ័យជំនះទៅលើការបំបាត់ព្រះពុទ្ធសាសនាបាន ក៏ងាកទៅផ្សាយសេចក្តីថ្លែងការណ៍ជាច្រើនច្បាប់ ក្នុងឆ្នាំ ១៩៦១ ស្តីអំពីនយោបាយដែលទាក់ទងនឹងពុទ្ធសាសនិកជនក្នុងប្រទេសចិន ហើយបានអួតអាងជាច្រើនលើកថា កុម្មុយនិស្តពុំមែនគ្រាន់តែអនុញ្ញាតឲ្យមានសេរីភាពខាងសាសនាប៉ុណ្ណោះទេ គឺបានទាំងជួយឧបត្ថម្ភផង ។ គណៈទូត

www.budinst.gov.kh www.elibraryofcambodia.org

សន្ធរមេត្រី ដែលធ្វើទស្សនកិច្ចនៅក្រុងប៉េកាំង តែងបានត្រូវផ្លូវការនាំទៅមើលវត្តអារាមផ្សេង ៗ នៃព្រះពុទ្ធសាសនា ព្រមទាំងអធិប្បាយពន្យល់ផង ។ នេះគឺជាសង្គ្រាមចិត្តសាស្ត្រ ដែលក្រុងប៉េកាំងបានធ្វើឡើង ដើម្បីដោះស្រាយចំពោះការចោទប្រកាន់របស់បក្សជាតិនិយម ។

ចំពោះសង្គ្រាមនៅសាធារណរដ្ឋខ្មែរវិញ ក៏រដ្ឋាភិបាលបានប្រកាសជាច្រើនលើកថា កងកម្លាំងយៀកកុងនិងយួនខាងជើង ដែលមានក្រុងប៉េកាំងនៅក្រោយខ្នង បានធ្វើសកម្មភាពនិងប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីបំផ្លាញព្រះពុទ្ធសាសនា ។ រដ្ឋាភិបាលបានលាតត្រដាងនូវអំពើឧក្រិដ្ឋយ៉ាងព្រៃផ្សៃ ដែលកងទ័ពឈ្លានពានបានប្រព្រឹត្តទៅលើជីវិតព្រះសង្ឃ និងទ្រព្យសម្បត្តិសាសនា ព្រមទាំងបង្ខំព្រះសង្ឃឲ្យសិក្សាមនោគមវិជ្ជាកុម្មុយនិស្តថែមទៀត ។

ការធ្វើទុក្ខបុកម្នេញព្រះពុទ្ធសាសនា ដែលចិនកុម្មុយនិស្តបានប្រព្រឹត្តនោះ បានបិតនៅក្នុងវាំងននដែកដែលគេបិទបាំងយ៉ាងប្រុងប្រយ័ត្ន ដើម្បីកុំឲ្យសាយភាយទៅក្រៅ ប៉ុន្តែខ្ញុំមានភ័ព្វអាចរកបានឯកសារខ្លះ ៗ ក្នុងដំណើរទៅកាន់ប្រទេសចិនប្រជាមានិតចំនួន៣លើក ដោយសារព្រះចៅអធិរាជ ស្តេចក្រុងចិនព្រះនាម ពូ យី ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកផងនៅចាំបានថា លោក ស៊ុន យឹត សេន បានធ្វើការបដិវត្តន៍រំលំរបប សក្តិភូមិនៅប្រទេសចិន ក្នុង ឆ្នាំ ១៩១១ ប្តូររបបដែលមានព្រះចៅអធិរាជ ឲ្យ ទៅជាសាធារណរដ្ឋ ។



អ្នកផងនៅចាំបានថា ព្រះចៅអធិ-រាជ ដែលសោយរាជ្យចុងក្រោយបំផុត ព្រះនាម ពូយី ក្នុងសន្តតិវង្សឡិង្គ ។

ក្រោយការបដិវត្តន៍ឆ្នាំ ១៩១១ មក ប្រទេសចិន ក៏ប្រែក្លាយទៅជាសាធា-រណរដ្ឋ ហើយក៏លែងមានអ្នកណា ដំ-ណាលអំពីស្ដេចក្រុងចិនទេ ។

ក្នុងខែឧសភា ១៩៦៤ គណៈប្រ-តិភូសភាខ្មែរមួយ ដែលមានលោក ស-ប៉ុរក្ខស៊ី ទ្រិញ-វាំញ ឧប-គឹម អាង ទូន-ឡាង ឈឹម-ទុំ ប៊ុត-ជួន និង ឡុង-បូរ៉េត បានទៅទស្សនា ប្រទេសចិន ។

នៅថ្ងៃទី ២២ ឧសភា ១៩៦៤ គណៈប្រតិភូសភាខ្មែរនិង

www.budinst.gov.kh www.elibraryofcambodia.org

ឥស្សរជនខ្មែរជាច្រើនទៀត ដែលបានធ្វើដំណើរទៅជាមួយ បានទៅទស្សនាព្រះរាជវាំងចាស់ ដោយមានអ្នកប្រវត្តិសាស្ត្ររ៉ាយរ៉ាប់អំពីការកសាងព្រះរាជវាំងពីអតីតកាល រហូតដល់ការបដិវត្តន៍ឆ្នាំ ១៩១១ ដែលពេលនោះ ព្រះចៅអធិរាជព្រះនាម ពូ យី គ្រងរាជ្យហើយដែលមានព្រះជន្មនៅរស់នៅឡើយ ។ សមាជិកគណៈប្រតិភូខ្មែរ ទាំងអស់បានការចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះស្មានថា ក្រោយការបដិវត្តន៍ស្ដេចក្រុងចិនស្លាប់អស់ទៅហើយ ខ្ញុំក៏បានសួរថា « ស្ដេចក្រុងចិនសព្វថ្ងៃនៅឯណា ? ខ្ញុំអាចសុំជួបបានឬទេ ? »

ក្នុងពេលនោះ សមាជិកសភាចិន ដែលបានជូនដំណើរ បានឆ្លើយថា អ្នកណាក៏អាចជួបព្រះចៅពូ-យីបានដែរ សព្វថ្ងៃព្រះចៅធ្វើការនៅវិទ្យាស្ថានវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ និងវប្បធម៌ ក្រុងប៉េកាំង ។

ចំពោះចម្លើយនេះ ខ្ញុំចេះតែនឹកក្នុងចិត្តដូចជាពុំចង់ជឿថា ម្ដេចក៏ស្ដេចក្រុងចិន នៅមានជីវិតរហូតមក ខ្ញុំចេះតែចង់ដឹងចង់ជួបស្ដេចក្រុងចិនណាស់ ។ ខ្ញុំចង់ជួបបានជួបមែន ក្នុង ២ ម៉ោងក្រោយមក ។ ខ្ញុំបានជួប បានថតជាមួយ និងបានសន្ទនាជាមួយស្ដេចក្រុងចិនយ៉ាងយូរ ។ ក្នុងការសន្ទនានោះស្ដេចក្រុងចិន បានរ៉ាយរ៉ាប់អំពីព្រះជីវប្រវត្តិ របស់ព្រះអង្គដែលបានគ្រងរាជ្យ នៅប្រទេស

www.budinst.gov.kh www.elibraryofcambodia.org

ចិនពីរលើក និងបានជាប់គុកនៅប្រទេសរុស្សី ៥ ឆ្នាំ នៅក្នុងប្រទេសចិនចំនួន ១០ ឆ្នាំ ។

ព្រះចៅ ពូ-យី មានព្រះជន្ម ៥៨ ឆ្នាំ នៅពេលដែលខ្ញុំបានជួប ។ ព្រះចៅ ពូ-យី ក៏បានថ្លែងដោយព្រះភក្ត្រញញឹមថា ៖

« ខ្ញុំពុំអាចបំភ្លេចបាន នូវព្រះមហាករុណាធិគុណដ៏លើសលប់ នៃព្រះសក្យមុនីព្រះបរមគ្រូ ដែលទ្រង់ប្រទានមួប់ពោធិដ៏ត្រជាក់ឲ្យខ្ញុំ ជាអតីតអធិរាជនៃប្រទេសចិន ព្រោះគ្មានព្រះចៅអធិរាជចិនអង្គណា ទោះក្នុងសន្តតិវង្សណាក៏ដោយ មានជីវិតរស់នៅបានឃើញអនាគតប្រទេសខ្លួនដូចរូបខ្ញុំឡើយ ។ ខ្ញុំរស់នៅនេះ សប្បាយជាងកាលខ្ញុំនៅជាអធិរាជចុងក្រោយបំផុត នៃសន្តតិវង្សឡែង ព្រោះជំនាន់នោះ ប្រទេសចិនជាសក្តិភូមិផង ចំណុះបរទេសផង ។

« ខ្ញុំមានអាយុ ៥៨ ឆ្នាំ ហើយ (១៩៦៤) ។ ខ្ញុំបានឡើងសោយរាជ្យតាំងពីអាយុ ២ ឆ្នាំ ។ លុះដល់ឆ្នាំ ១៩១១ គឺ ៤ ឆ្នាំក្រោយមក មានការបដិវត្តន៍មួយដឹកនាំដោយលោក ស៊ុនយ៉ាតសេន ប្រទេសចិនក៏ប្តូររបបគ្រប់គ្រង ។ ពិតមែនតែមានការប្រែប្រួល ក៏ពួកសាធារណរដ្ឋ បានទុកឲ្យខ្ញុំនៅមានងារ ជាអធិរាជដដែល ឲ្យរាជវាំងខ្ញុំនៅដដែល ឲ្យរាជបរិវារដដែល និងឲ្យប្រាក់ខ្ញុំប្រចាំឆ្នាំ ក្នុង ១ ឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

៤លានតាអែល (គឺ១២៥.០០០គីឡូ) សម្រាប់ចាយ ។

"ខ្ញុំរស់នៅដូចដើមរហូតមក ហើយបានទឹកស្មានថា ជាកូនព្រះឥន្ទ ដីទាំងឡាយជាមរតករបស់ខ្ញុំ ហើយមនុស្សទាំងអស់ជាខ្ញុំបំរើរបស់ខ្ញុំ ។ គេលើកខ្ញុំគ្រប់ពេលវេលា ខ្ញុំពុំដែលឮដល់ម្តងណានូវសំដីដែលថា ខ្ញុំធ្វើខុស ប្រព្រឹត្តអាក្រក់សោះឡើយ ។ លុះដល់ខ្ញុំអាយុបាន ១៨ ឆ្នាំ (១៩២៤) ដែលខ្ញុំបានដឹងកិច្ចការរាក់ជ្រៅ ចាត់ការខ្លួនឯង បានមានកងទ័ពជាតិនិយម ដែលមានឧត្តមសេនីយ ហ្វេង-យូ សៀង បានវាយលុកចូលកាន់កាប់ក្រុងប៉េកាំង ខ្ញុំក៏ត្រូវឃ្លាតចេញពីវាំង ។

« ខ្ញុំបានទៅជ្រកនៅនឹងសម្បទានជប៉ុន នៅទៀនត្សីនហើយបំរុងនឹងរៀបខ្លួនចូលទៅកាន់ក្រុងប៉េកាំងវិញ ដោយចូលជាមួយពួកចក្រពត្តិ ។

« កាលពីតូចខ្ញុំចេះតែកោតស្ញប់ស្ញែងបរទេស គឺពួកស្បែកស និង ជប៉ុន ។ ខ្ញុំបានយកអង់គ្លេសម្នាក់ឈ្មោះហ្ស៊ីន ស្តុន ជាអតីតលេខាធិការចៅហ្វាយក្រុង ហុងកុង ហើយជាអ្នកអភិបាលសម្បទានអង់គ្លេសនៅខេត្តចាន់ ទុង ជិតក្រុងស៊ាងហៃ ធ្វើជាអ្នកប្រៀន

www.budinst.gov.kh www.elibraryofcambodia.org

ប្រដៅខ្ញុំ ។ ពួកកុងស៊ុលអាមេរិកាំង អង់គ្លេស បារាំងសែស ជប៉ុន និង អ៊ីតាលី នៅតែហៅខ្ញុំថា ព្រះចៅអធិរាជនៃសន្តតិវង្សឆ្សិង្គ ហើយបានជួយគាំទ្រទៅរដ្ឋាភិបាលសាធារណរដ្ឋឲ្យខ្ញុំផង ។ ក្នុងបណ្ដាប្រទេសទាំងអស់ មានជប៉ុនបានថ្នាក់ថ្នមខ្ញុំជាងគេ គឺលោកកុងស៊ុលស៊ីហ្សេរូ-យ៉ាស៊ុដា ។ ពួកជប៉ុនបានបង្កើត រាជាណាចក្រមួយ នៅខាងទិសឦសាន គឺម៉ង់ជូកួ ឲ្យខ្ញុំសោយរាជ្យទៀត ។ លើកទី ២ នេះ ខ្ញុំសោយរាជ្យបាន ១៤ឆ្នាំ (១៩៣២-១៩៤៥) តែអំណាចនៅលើជប៉ុនទាំងអស់ ។ ហើយអំណាចខ្លះទៀតពួកគ្រួសារខ្ញុំ និងបរិវារខ្ញុំគេឆ្លៀតដោយយកឈ្មោះខ្ញុំ ទៅប្រើប្រាស់យ៉ាងឃោរឃៅ ។ សូម្បីតែជប៉ុនបានសម្លាប់ប្រជារាស្ត្រ អស់ប្រហែល ៧៦-០០០ នាក់ ដោយយកឈ្មោះខ្ញុំទៅប្រើ ក៏ខ្ញុំឥតបានដឹងដែរ ។

លុះដល់ជប៉ុនអស់អំណាចទៅ ខ្ញុំនិងមន្ត្រីរបស់ខ្ញុំ ត្រូវទាហានរុស្ស៊ីដែលបានជួយរំដោះដែនដីខាងជើង ចាប់យកទៅឃុំឃាំងនៅសហភាពសូវៀតអស់រយៈ ៥ ឆ្នាំ ។ នៅ គ.ស ១៩៥០ រដ្ឋាភិបាលសហភាពសូវៀតបានបញ្ជូនខ្ញុំ និងបរិវាររបស់ខ្ញុំតាមរថភ្លើងមកប្រទេសចិនវិញ ដែលខ្ញុំនឹកមមៃខ្វាចក្រៃណាខ្លាចថា មុខជាត្រូវទទួលទារុណកម្មដល់ស្លាប់ហើយ ។ មានស្លាប់ឯណា ខ្ញុំនៅរស់ , តែ

www.budinst.gov.kh www.elibraryofcambodia.org

នៅជាប់ឃុំឃាំងនៅហ្វូជុន ដែលជាកន្លែងអប់រំសារជាថ្មីដល់ពួកឈ្លើយសង្គ្រាមជប៉ុន ។ លោកប៉ាំងអ៊ី តាំងពីតូចមក ខ្ញុំចាំតែហាមាត់ញាំ លើកដៃជើងឲ្យគេស៊កអាវខោ ។ កាលខ្ញុំជាប់ឃុំដំបូង ខ្ញុំក៏ពុំទាន់ចេះ ដួសបាយ មិនចេះបោកខោអាវដែរ ព្រោះក្មួយខ្ញុំដែលជាប់ឃុំជាមួយ រាប់រើខ្ញុំ ។ ដល់យូរទៅ ខ្ញុំដូចជាចេះរៀន ព្រោះមានតែខ្ញុំទេដែលនៅ ស្ងៀម ឲ្យគេបំរើគ្រប់យ៉ាង ។ ខ្ញុំក៏ចាប់បោសបន្ទប់ លាងចាន ឡើង ។ ក្នុងឆ្នាំ១៩៥៣ ខ្ញុំបានចាប់ផ្ដើមធ្វើប្រអប់ក្រដាស ដំបូងឥតធ្វើកើតទេ តែយូរទៅ ខ្ញុំធ្វើប្រអប់បាន ៨ ក្នុង ២ ម៉ោង តែគេឯទៀត ធ្វើបាន ៣០ ប្រអប់ ។ លោកចាងហ្វាងមន្ទីរឃុំឃាំង បានយកប្រអប់ទៅលក់ រួចទិញនំមកចែកឲ្យខ្ញុំទទួលទាន ។ ទើបតែពេលនេះហើយ ដែល ខ្ញុំជញ្ជក់រសជាតិឆ្ងាញ់ពីផលដែលកើតបាន ពីកម្លាំងផ្ទាល់របស់ ខ្ញុំ ។ នៅឆ្នាំ ១៩៥៥ ខ្ញុំចាប់ផ្ដើមរៀនធ្វើចំការបន្លែ ខ្ញុំក៏បានស្គាល់ ថា ការហត្ថកម្មពុំមែនគ្រាន់តែឲ្យផលទេ ថែមទាំងផ្ដល់នូវសុខភាព ផង ។ ការពិសោធន៍របស់ខ្ញុំបានឲ្យខ្ញុំគិតឃើញថា អ្នកដែលគ្មានធ្វើអ្វី សោះ ហើយដេកចាំតែស៊ីផលពីអ្នកដទៃ ជាមនុស្សចំកួត ។

ខ្ញុំក៏នឹកឃើញសព្វគ្រប់ថា កាលខ្ញុំសោយរាជ្យលើកទី ២

មន្ត្រីខ្ញុំ បងប្អូនខ្ញុំ រាបញ្ញោរខ្ញុំ វានាំយកមកឲ្យខ្ញុំនូវរបស់ល្អ។ ផ្លែឈើល្អ។ មាសពេជ្រដ៏មានតម្លៃ ស្រីក្រមុំស្អាត ដោយវាប្រាប់ថា វាស្រឡាញ់ខ្ញុំ ជយោខ្ញុំ ហៃអើខ្ញុំ សុខចិត្តលះបង់គ្រប់យ៉ាងចំពោះខ្ញុំ តែអ្វីទាំងអស់ ខ្ញុំមានបានសំរាប់ខ្ញុំឯណា ខ្ញុំគ្រាន់តែបានវេទនាជាប់ឃុំឃាំង ១៥ឆ្នាំ ទើបរួចផុត មានសេរីភាពនៅថ្ងៃ ៤-១២-១៩៥៩ ។

ក្នុងពេលជាប់ឃុំឃាំង នៅប្រទេសរុស្ស៊ី ៥ ឆ្នាំ រហូតដល់មកស្រុកចិនក្នុងឆ្នាំ ១៩៥០ អាក្មួយខ្ញុំម្នាក់ឈ្មោះចេង-ជួយ មានវ័យក្មេង វាបានយកហិបដែកមួយជាប់នឹងខ្លួនវា វាដេកឱបហិប វាទៅណាសុខចិត្តលីហិប កណ្ដៀតហិប តាមជានិច្ច ។ ក្នុងឆ្នាំ១៩៥២ ក្មួយខ្ញុំនោះបានប្រាប់ខ្ញុំថា នៅបាតហិបដែកវាមានផ្សាភ្ជិតពីរជាន់ ហើយមានលាក់ទុកនៅក្នុងនោះ នូវមាសពេជ្រជាច្រើន ដែលវាសន្សំបាន ។ ខ្ញុំក៏ចាប់នឹកឃើញថាអាក្មួយខ្ញុំនេះ វាយកឈ្មោះខ្ញុំកាលគ្រងរាជ្យទៅជិះជាន់គេរឹបយកទ្រព្យទាំងនេះ តែបាបកម្ម បានផ្ដន្ទារូបខ្ញុំឲ្យអស់បុណ្យ អស់អំណាច ដោយសារមន្ត្រីខូចជុំវិញខ្ញុំ និងគ្រួសារខ្ញុំ ខ្ញុំលែងឃើញមុខអ្នកស្លូតត្រង់ដែលគេពុំចេះបញ្ញោរខ្ញុំ រហូតដល់ខ្ញុំវិនាស ។ ឯអាក្មួយខ្ញុំនេះវាខិតខំប្រមូលមាសពេជ្រ ឥឡូវមាសពេជ្រទាំងនោះ ដែលជា

របស់រាស្ត្រ វាមានតម្លៃឯណា នៅរុស្ស៊ីក៏ចាយវាយពុំបាន ហើយមក ដល់ស្រុកចិនក៏ចាយវាយពុំបាន ហើយថែមទាំងនាំឲ្យអស់ជីវិតទៀត ។ ខ្ញុំក៏គិតថា យកទៅឲ្យគេ ក៏ប្រហែលស្លាប់ លាក់ទុកទៅ ថ្ងៃណាគេ ដឹងក៏នឹងត្រូវស្លាប់ ខ្ញុំខំលាក់មក ២ឆ្នាំ ទៅហើយ តើខ្ញុំអាចរួចខ្លួនបានទេ ។ លុះក្រោយមក ខ្ញុំក៏ដាច់ចិត្តយកមាសពេជ្រ ទាំងនោះ ទៅឲ្យចាង ហ្វាងគុក គេក៏ឲ្យខ្ញុំមានឥស្សរភាពទៅ មាសពេជ្រទាំងនោះ គេបាន យកទៅដំកល់ទុកនៅសារមន្ទីរជាតិ សព្វថ្ងៃនេះ ។ √

ប្អូនឆ្នាំ ហើយ ដែលខ្ញុំចូលក្នុងជីវភាពថ្មី ក្នុងឋានៈជាពល រដ្ឋមួយរូប ។ ដំបូង ខ្ញុំធ្វើជាអ្នកថែរក្សាសួនរុក្ខជាតិ សព្វថ្ងៃ ខ្ញុំធ្វើការ ក្នុងវិជ្ជាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ និងវប្បធម៌ ។ កាលពីថ្ងៃ ១-៥-១៩៦៣ ខ្ញុំបានរៀបការជាមួយគិលានុបដ្ឋាយិកា ឈាម លីផូ-សៀន ធ្វើជាប្រពន្ធ ។ ១ឆ្នាំហើយ ដែលខ្ញុំស្គាល់តម្លៃស្រីភេទ ខ្ញុំ ស្គាល់ សេចក្តីស្នេហាខ្ញុំជាមនុស្សមួយរូប ។ កាលនៅគ្រងរាជ្យ គេនាំយកស្រី ៗ ក្រមុំឲ្យខ្ញុំ ១ថ្ងៃ ២ ឬ ៣ ខ្ញុំត្រេកត្រអាលមែន តែឥតមាន ស្គាល់នូវសេចក្តីស្នេហាដ៏បរិសុទ្ធអ្វីឡើយ ។

លាក់បាំងអី របបគ្រប់គ្រងថ្មី គេបានចាត់ចែងម្យ៉ាងដែរ តែ

www.budinst.gov.kh www.elibraryofcambodia.org

ពុំមែនប្រសើរណាស់ណាទេ វាពុំសូវមានសេរីភាព ហើយកិច្ចអនុវត្តន៍ខាងសាសនា ខ្ញុំចាប់អារម្មណ៍ជាប់ក្នុងចិត្តជានិច្ច ដែលខ្ញុំខិតខំស្រាវជ្រាវកត់ត្រាមកយូរហើយ ចាំខ្ញុំឲ្យគេយកឯកសារមកជូនលោក ព្រោះខ្ញុំបានគយគន់ទៅឃើញថា លោកមានលក្ខណៈជាអ្នកចង់រកការណ៍ពិត ចង់រកយុត្តិធម៌ឲ្យសង្គមជាតិ ។

ក្នុងឱកាសជប់លៀងមួយ នៃសមាគម ចិន-ខ្មែរ ស្រាប់តែខ្ញុំបានទទួលស្រោមសំបុត្រមួយ ដែលស្តេច ពូឃី វេធ្មីមកខ្ញុំ តែអ្នកប្រគល់ឲ្យខ្ញុំនោះ ប្រគល់យ៉ាងស្ងាត់ ហើយមានទឹកមុខភ័យខ្លាចយ៉ាងសម្បើម ខ្ញុំក៏ទទួលយកទុករហូតមកដល់ស្រុកខ្មែរ បានពឹងឲ្យគេប្រែឯកសារនោះឲ្យស្តាប់ គឺសុទ្ធតែឯកសារខាងព្រះពុទ្ធសាសនា នៅប្រទេសចិន ដែលត្រូវពួកកុម្មុយនិស្តបំផ្លាញ ។

ឥឡូវស្តេចពូ-ឃី បានសុគតទៅហើយ ខ្ញុំបានរៀបរៀង និងធ្វើអត្ថាធិប្បាយខ្លះ សំរាប់ពុទ្ធសាសនិកជនខ្មែរយើង ដែលកំពុងទទួលនូវការឈានពានអំពីពួកយួនកុម្មុយនិស្ត ដើម្បីជាគ្រឿងពិចារណាតទៅ ។ សៀវភៅរបស់ខ្ញុំ ដែលរៀបរៀងនេះ ខ្ញុំបានធ្វើជាសន្និសីទម្តងហើយ នៅសាកលវិទ្យាល័យបាត់ដំបង កាលពីថ្ងៃទី ៤

www.budinst.gov.kh www.elibraryofcambodia.org

កុម្ភៈ ១៩៣២ នោះ មានចំណងជើងថា « ព្រះពុទ្ធសាសនានៅប្រទេសចិន លទ្ធិកុម្មុយនិស្តចិន និងព្រះពុទ្ធសាសនា » ។

ខ្ញុំសង្ឃឹមថា ពុទ្ធសាសនិកជនដែលមានការចាប់អារម្មណ៍នឹងព្រះពុទ្ធសាសនា មេត្តាជួយផ្ដល់យោបល់ ដើម្បីជាប្រយោជន៍រួមសំរាប់អនាគតនៃសាធារណរដ្ឋខ្មែរ។

ខ្ញុំសូមថ្លែងនូវអំណរគុណទុកជាមុន ។

ទ្រិញ ទ៉ាញ

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះពុទ្ធសាសនានៅប្រទេសចិន
# លទ្ធិកុម្មុយនិស្តចិន និងព្រះពុទ្ធសាសនា

## ចំពូក ១

## ព្រះពុទ្ធសាសនានៅប្រទេសចិន

ព្រះពុទ្ធសាសនា នៅប្រទេសចិន បានចាប់ផ្ដើមឡើង ដោយមានប្រវត្តិរបស់ខ្លួនគប់យ៉ាងជ្រៅ ទៅក្នុងប្រវត្តិសាស្ត្រនៃប្រជាជនចិន ។ តាមការស្រាវជ្រាវ ពីគ្រប់មជ្ឈដ្ឋានឃើញថា ព្រះពុទ្ធសាសនាបានជ្រួតជ្រាបទៅក្នុងប្រទេសចិន ជាលើកដំបូងរវាងមួយរយឆ្នាំ មុនគ្រឹស្តសករាជ ( ព.ស.៤៣១ ) នៅពេលដែលប្រជាជនចិនបានធ្វើការទាក់ទងជាលើកដំបូងនឹងប្រទេសដទៃ ។ ប្រទេសចិនមានព្រះសូត្រនៃព្រះពុទ្ធសាសនា និងមានវត្តអារាមជាលើកដំបូងរវាង គ.ស. ៦០

www.budinst.gov.kh www.elibraryofcambodia.org

( ព-ស- ៦០៣ ) ។ ព្រះពុទ្ធសាសនា បានចាប់ផ្ដើម ចំរើនរុងរឿងតាំងពីគ្រិស្តសតវត្សទី ៣ ដល់គ្រិស្តសតវត្សទី ៦ ហើយរុងរឿងពេញទីក្នុងសម័យរាជវង្សស៊ុយ និងរាជវង្សថាង ដែលគ្រងរាជ្យពីសតវត្សទី ៦ ដល់សតវត្សទី ៩ ។ តាំងពីនោះមក ទោះបីព្រះពុទ្ធសាសនាពុំបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្ដី ក៏ពុទ្ធប្រាជ្ញានិងពាក្យប្រៀនប្រដៅបានជ្រួតជ្រាបទៅក្នុងអារ្យធម៌ចិនបន្តិចម្តង ៗ ព្រះពុទ្ធសាសនាបានចូលទៅទាក់ទងនឹងជីវភាពប្រចាំថ្ងៃ នៃប្រជាជនច្រើនផ្នែក ហើយមានសកម្មភាពយ៉ាងសំខាន់ក្នុងផ្លូវចិត្តរបស់ជាតិ ។

ក្នុងពេលដែលលោក ចាង-ឆៀន នៃរាជវង្សហាន់ខាងលិចទៅធ្វើជាទូតប្រចាំប្រទេសតៃសៀ ដែលតាំងនៅខាងទាយពីខេត្តដែនខាងលិចនៃប្រទេសចិននោះ លោកបានដឹងថា មានរដ្ឋនៅជិតខាងមួយទៀតដែលប្រជាជនហៅថា "ស៊ិន្ធូ" ឬ " តៀនចូវ " ។ ដោយហេតុនេះប្រជាជនចិនបានស្គាល់នូវប្រទេសដែលសព្វថ្ងៃនេះហៅថា " ឥណ្ឌា " ។

ក្នុងឆ្នាំដំបូងនៃរជ្ជកាល ចក្រពត្តិអេចុង នៃរាជវង្សហាន់ខាងលិច ( ២ ឆ្នាំ មុនគ្រីស្តសករាជ ) អ្នកសិក្សា ដែលមានសេចក្ដីព្យាយាមម្នាក់

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះ ជិន ធៀន ជៀន បានទទួលញចាំ ព្រះសូត្រផ្សេង ៗ ពីទូតនៃប្រទេស "តៃយូជី" ។

ក្នុងគ.ស.៦៤ (ព.ស.៦០៧) ច័ក្រពត្តិមីងទីនៃរាជវង្សហាន់ខាងលិច បានបញ្ជូនទូត ១៨ នាក់ ដែលមានថៃ-អាន និងជិន-ធៀន-ជៀនផង ឲ្យទៅកាន់រាជាណាចក្រខាងលិច ដើម្បីស្វែងរកគម្ពីរព្រះពុទ្ធសា-សនា ។ លុះទៅដល់ប្រទេសឥណ្ឌា ទូតទាំងនេះក៏បានជួបនឹងភិក្ខុ ២ រូប ព្រះនាមគោភរណ៍ និងមតាង្គ ដែលកំពុងនាំព្រះសូត្រនៃព្រះពុទ្ធសាសនា មកកាន់ប្រទេសចិន ។

គណៈទូតនេះ បានត្រឡប់មកកាន់ប្រទេសចិនវិញ ជាមួយនឹងភិក្ខុ ២អង្គនោះ ហើយមកដល់ក្រុងឡូយ៉ាំនៅក្នុង គ.ស.៦៧ (ព.ស.៦១០) ដោយបាននាំគម្ពីរពុទ្ធសាសនា៤២ក្បាល និងព្រះឆាយាលក្ខណ៍នៃព្រះសក្យមុនីមួយផ្ទាំងផង ។ ដោយសៀវភៅដែលនាំទៅកាន់ប្រទេសចិននេះ បានត្រូវគេរឹងនៅលើខ្នងសេះស ទើបគេសាងវត្តសេះសឡើង នៅត្រង់ជាយក្រុងឡូយ៉ាំ ទុកជាអនុស្សាវរីយ៍ដល់ការនាំព្រះពុទ្ធសាសនាទៅប្រតិស្ឋាន នៅក្នុងប្រទេសចិននេះ ។

តមក ព្រះមតាង្គបានប្រែគម្ពីរព្រះពុទ្ធសាសនា ទៅជាភាសាចិន

www.budinst.gov.kh www.elibraryofcambodia.org

មួយក្បាល ព្រះគោភរណ៍បានប្រែ៥ក្បាល ដែលហៅថា "ហូហែចូង" ព្រមទាំងបានប្រែសៀវភៅដទៃទៀត ដែលទាក់ទងនឹងព្រះពុទ្ធសា-សនាជាច្រើនក្បាលផង ។

លុះកន្លងបន្តិចមក មានព្រះថេរៈជាច្រើនរូបទៀត នៅប្រទេសជិតខាង បានចូលទៅកាន់ប្រទេសចិន ហើយបានជួយតែង ឬប្រែគម្ពីរបាន២៩២ក្បាល ព្រមទាំងបានចម្លងសំណៅគម្ពីរព្រះពុទ្ធសាសនា ៣៩៥ ក្បាលទៀត ។

យុគនេះ គ្រាន់តែជាការផ្សាយព្រះពុទ្ធសាសនា លើកដំបូងក្នុងប្រទេសចិនប៉ុណ្ណោះ ឯព្រះពុទ្ធសាសនា ពុំទាន់បានជ្រែកចូលទៅក្នុងសង្គមជាតិនៅឡើយទេ ។ ក្រោយពីសម័យរាជវង្សវ៉ៃមក មានភិក្ខុនិងឧបាសកចិន ដែលធ្វើដំណើរទៅកាន់ដែនដីខាងលិច ដើម្បីសិក្សាព្រះនវាទនៃព្រះពុទ្ធសាសនា បានទ្វេចំនួនឡើងរាល់ពេល ។ សេចក្តីចំរើនរុងរឿងនៃព្រះពុទ្ធសាសនា ក្នុងប្រទេសចិន ក៏បានចាប់ផ្តើមមានឫសគល់យ៉ាងមុតមាំតាំងពីពេលនោះមក ។

ការទាក់ទងរវាងប្រទេសចិននឹងប្រទេសដទៃ បានបង្ហំឲ្យមានការ

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

ប្រែគម្ពីរ និងការផ្សាយព្រះពុទ្ធសាសនា កាន់តែខ្លាំងឡើង ។ វត្ត អារាមជាច្រើនកន្លែងខាងព្រះពុទ្ធសាសនា ក៏បានត្រូវស្ថាបនាឡើងនៅ ពេលនោះ ។ ក្នុងសេចក្តីរាយការណ៍នៃរាជវង្សរៀ គ.ស. ៥៣៨ (ព.ស. ១០៦១ ) បានថែងថា មានការស្ថាបនាវត្ត នៅក្នុងប្រទេសចិន ច្រើន ជាង ៣០.០០០ កន្លែង ហើយការកសាងព្រះពុទ្ធរូបសិលា ឬ លោហៈ និងការកសាងគុហា ក៏បានផ្សព្វផ្សាយនៅក្នុងយុគនេះ ។

ក្នុងពេលមុនដំបូងនេះ មានតែពួកតាងប្រទេស ដែលមកពីភាគ ខាងលិចប៉ុណ្ណោះទេ ដែលអាចបួសជាភិក្ខុបាន ។ ប្រជាជនចិនជាកុល_ សម្ព័ន្ធហាន់ បានត្រូវហាម មិនឲ្យកាន់ប្រពៃណីនេះទេ ។ លុះដល់រជ្ជ- កាលចក្រពត្តិវ៉េនទី នៃរាជវង្សវី គ.ស ២២០ (ព.ស. ៧៦៣) ។ ប្រជា ជនចិន ក៏បានចាប់ផ្តើមបួស ហើយចំនួនភិក្ខុបានកើនឡើងជាលំដាប់ ។ គេបានបញ្ជាក់ថា ក្នុង គ.ស. ៥១១ ( ព.ស. ១០៥៥ ) មានភិក្ខុនិង នាងជី ១៣.៧២៧ រូប ហើយក្នុង គ.ស.៥២០ ( ព.ស. ១០៦០ )ចំនួន ពុទ្ធសាសនិកជនក្នុងប្រទេសចិន មានចំនួនប្រមាណជាងពីរលាននាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

ទោះបីរាជវង្សស៊ុយ បានគ្រងរាជ្យ អស់រយៈពេលយ៉ាងខ្លីក្តី ក៏ការប្រែគម្ពីរព្រះពុទ្ធសាសនា បានត្រូវធ្វើឡើងដោយចំនួនមិនតិចទេ ។ ព្រះថេរៈអង្គខ្លះ បានទទួលកិត្តិយសនិងការប្រតិបត្តិជាពិសេស ហើយបានអ្នកជួយទំនុកបម្រុងក្នុងការប្រែគម្ពីរព្រះពុទ្ធសាសនាជាច្រើនទៀត ។

ក្នុង គ.ស. ៦០៦ ( ព.ស. ១១៤៩ ) ព្រះចៅចក្រពត្តិមួយអង្គ បានទ្រង់បញ្ជាឲ្យចាត់តាំងវិជ្ជាឋានប្រែគម្ពីរព្រះពុទ្ធសាសនា នៅតំបន់សាងលីយួន ក្នុងក្រុងឡូយ៉ាំ ហើយបានទ្រង់តែងតាំងអ្នកជំនាញខាងការប្រែ ដែលមានតំណែងជាសាស្ត្រាចារ្យមួយចំនួនទៀត សម្រាប់ជួយបំពេញកិច្ចនេះ ។

ក្នុងសម័យរាជវង្ស ថាង កិច្ចការប្រែគម្ពីរនេះ បានត្រូវធ្វើឡើងយ៉ាងម៉ឺងម៉ាត់ ។ ក្រៅពីព្រះថេរៈចេញ មានការតែងតាំងអ្នកសិក្សាជាច្រើននាក់ទៀត សម្រាប់ជួយកែសម្រួលការប្រែព្រះគម្ពីរទាំងនោះ ។ ដូច្នេះ អត្ថបទនៃគម្ពីរដែលប្រែថ្មីក្នុងពេលនោះ ល្អជាងអត្ថបទដែលធ្វើក្នុងរជ្ជសម័យមុន ។

គួរកត់សម្គាល់ថា ក្នុងសម័យរាជវង្សថាង គ.ស. ៦៧ ដល់

www.budinst.gov.kh www.elibraryofcambodia.org

គ.ស.៧៣០ (ព.ស.៦១០-១២៧៣) ព្រះថេរៈទាំងឡាយ នៃភាគខាងលិច បានចូលទៅកាន់ ប្រទេសចិន កាន់តែច្រើនឡើងៗ ហើយក្នុងពេលជាមួយគ្នានោះ ភិក្ខុចិនយ៉ាងច្រើន ក៏បានធ្វើដំណើរទៅកាន់ភាគខាងលិច ដើម្បីសិក្សាបន្ថែម ។ អង្គខ្លះ បានឧទ្ទិសខ្លួនយ៉ាងសំខាន់ ក្នុងកិច្ចការប្រែគម្ពីរ ហើយនៅពេលត្រឡប់មកកាន់ប្រទេសវិញ ក៏បាននាំយកគម្ពីរភាសាសំស្ក្រឹតច្រើនជាងមុន មកជាមួយផង ។ ក្នុងពេលនោះ មានភិក្ខុជិត ២០០រូប បានរួមដៃគ្នាប្រែវិន័យ និងសៀវភៅក្បួនខ្នាតព្រះពុទ្ធសាសនា ។ ក្រោពីនេះ បានទាំងប្រែគម្ពីរមហាយាននិងហីនយានជាភាសាចិន ហើយបានធ្វើដូចគ្នា ទាំងព្រះត្រៃបិដក និងអដ្ឋកថាដទៃទៀតជាច្រើន ។ ក្រោពីការប្រែនេះ ភិក្ខុចិន បានតែងក្បួនខ្នាតព្រះពុទ្ធសាសនា ចំនួនពី៣០០ ដល់ ៤០០ក្បាល យ៉ាងតិច ។

ក្នុង គ.ស. ៨៤៥ (ព.ស. ១៣៨៨) នៅប្រទេសចិន មានវត្តអារាមច្រើនជាងបួនម៉ឺន (៤០.០០០) កន្លែង ហើយចំនួនភិក្ខុនិងភិក្ខុនីបានកើនចំនួនដល់ទៅ ២៦០.៤០០ រូប ។

ព្រះពុទ្ធសាសនា បានត្រូវផ្សាយយ៉ាងទូលំទូលាយផាលំផាប់

www.budinst.gov.kh www.elibraryofcambodia.org

ផរាបដល់ពេញទាំងប្រទេសចិន ទោះបីពុំបានរុងរឿងដល់កម្រិត ដែលអាចប្រៀបផ្ទឹមបាននឹងសម័យរាជវង្សថាងក្តី ក៏វត្តអារាម មានចំនួនច្រើនជាងប្រាំបីសែនកន្លែង ( ៨០០.០០០ )។

លុះរាជវង្សឈិន ឡើងគ្រងរាជ្យ ដោយមានការស្ថាបនាវត្តបន្ថែមទៀត ចំនួនភិក្ខុនិងនាងជី ក្នុងរជ្ជសម័យនេះ បានកើនចំនួនដល់ទៅ ៥ លានរូប ។

ក្នុងពេលដែលមានការបង្កើតសាធារណរដ្ឋចិន គ.ស. ១៩១១ ( ព.ស.២.៤៥៤ ) សេចក្តីចម្រើននៃព្រះពុទ្ធសាសនា ក្នុងប្រទេសចិន បានត្រូវសាបសូន្យទៅ ប៉ុន្តែនៅល្មមអាចនឹងប្រៀបធៀបបានទៅនឹងសេចក្តីចម្រើន ក្នុងសម័យរាជវង្ស ឈិន ។ ទោះបីគ្មានស្ថិតិពិតប្រាកដអំពីចំនួនភិក្ខុនិងនាងជី ក្នុងសម័យក្រោយ ៗ មកក្តី បើគេចាត់ទុកថា មានវត្តចំនួន ៨០០.០០០ ហើយវត្តនិមួយ ៗ ត្រូវមានភិក្ខុ ៥ រូបនោះ , មុនពេលដែលកុម្មុយនិស្តឡើងកាន់អំណាច ភិក្ខុអាចមានចំនួនជាអតិបរមា ៤ លានរូប ។ កាលបើភិក្ខុមានចំនួនច្រើនដូច្នេះ ជាពិសេស នៅក្នុងទីជនបទនោះ គេអាចយល់បានណាស់ហើយថា ព្រះពុទ្ធសាសនា មានអានុភាពចំពោះជីវិតប្រចាំថ្ងៃរបស់ប្រជាជនដល់កម្រិតណា ។

www.budinst.gov.kh www.elibraryofcambodia.org

## ប្រពៃណីរបស់ចិន គ្មានរង្កៀស
## ចំពោះព្រះពុទ្ធសាសនាទេ

ការដែលព្រះពុទ្ធសាសនា បានចូលទៅកាន់ប្រទេសចិន ហើយភ្ញាក់ខ្លួន ឲ្យចម្រើនរុងរឿងនោះ បានបញ្ជាក់ឲ្យឃើញច្បាស់នូវសេចក្តីអត់ធន់នៃប្រជាជនចិន ។ តាមពិត ព្រះពុទ្ធសាសនា ក្នុងប្រទេសចិន នៅពេលមួយនោះ បានត្រូវតស៊ូ នឹងវឌ្ឍនធម៌-ប្រពៃណី របស់ប្រទេសចិន គឺប្រយុទ្ធចំពោះចោមប្រហារក្នុងផ្លូវចរិយា ដែលធ្វើឡើងដោយអ្នកកាន់សាសនាខុងជឺ និងក្នុងផ្លូវប្រាជ្ញា ដែលធ្វើឡើងដោយអ្នកកាន់សាសនាតៅ ប៉ុន្តែ ព្រះពុទ្ធសាសនា អាចចម្រើនរុងរឿងតទៅបានដោយគ្មានជួបប្រទះនឹងឧបសគ្គធំ ៗ ណាមួយឡើយ ។ ក្នុងសម័យ-

www.budinst.gov.kh www.elibraryofcambodia.org

រាជវង្សថាង ទាំងពួកហាន់ បានចោមប្រហារព្រះពុទ្ធសាសនាយ៉ាងខ្លាំង ប៉ុន្តែ ទស្សនះរបស់ពួកនេះ ពុំបានធ្វើឲ្យរាជសម្នាក់ នៃព្រះចៅចក្រពត្តិ យកព្រះទ័យទុកដាក់ទេ, ផ្ទុយទៅវិញ ត្រឡប់ជានាំឲ្យទ្រង់ពិរោធ ហើយ សម្រេចដាក់ទោសដល់ពួកនោះផង ។

បើស្រាវជ្រាវរកតួយ៉ាងនៃការប្រតិបក្ស ចំពោះព្រះពុទ្ធសាសនា ក្នុងប្រវត្តិសាស្ត្ររបស់ចិនហើយ គេនឹងឃើញនូវករណី ៣ យ៉ាង ជាល័ក្ខឋាន ដូចតទៅ គឺ :

ក — ក្នុងសម័យបែងចែកដែនដីជាភាគខាងជើង និងភាគខាងត្បូង ចក្រពត្តិ វ៉ៃទូទី ដែលមានជំនឿយ៉ាងខ្លាំងចំពោះសាសនាចាស់របស់ចិន បានប្រហារពុទ្ធសាសនិកជន ហើយបានបំផ្លាញចោលនូវព្រះពុទ្ធរូប និងគម្ពីរដីកាទាំងអស់ ។ នេះជាលើកដំបូងហើយ ដែលសេចក្តីរុងរឿងនៃព្រះពុទ្ធសាសនានៅប្រទេសចិន ត្រូវអាក់ខានទៅវិញ ព្រោះការសង្កត់ខាងនយោបាយ ។ ទោះបីដូច្នេះក្តី នៅភូមិភាគខាងត្បូងនៃប្រទេសចិន ការហាមឃាត់មិនឲ្យរាប់អានព្រះពុទ្ធសាសនា ក៏ពុំបានសម្រេចលទ្ធផលយ៉ាងណាដែរ ។ ដោយហេតុនេះ ពុទ្ធសាសនិកជន

www.budinst.gov.kh www.elibraryofcambodia.org

ក៏លបកៀសខ្លួន ចូលទៅស្វែងរកសេចក្ដីស្ងប់ ក្នុងខេត្តនេះ បានជាច្រើនទាក់ ។

ខ-ចក្រពត្តិថៃវូទី នៃរាជវង្សភាគខាងជើង ដែលរាប់អានសាសនាខុងជឺ បានចេញព្រះរាជឧង្ការអំពាវនាវឲ្យពុទ្ធសាសនិកជន និងអ្នកកាន់សាសនាតៅ លាសិក្ខាបទត្រឡប់ទៅកាន់ជីវិតជាលោកិយវិស័យវិញ ។

គ-ចក្រពត្តិវូចុង នៃរាជវង្សថាង បានប្រកាសហាមមិនឲ្យមានការរាប់អានសាសនា ដោយបានទទួលការញុះញង់ពី ថោងក្វៃស៊ុនជាបព្វជិតនៃសាសនាតៅ ។

ទុកជាយ៉ាងណាក្ដី ការទំនាស់របៀបនេះ ចំពោះការរាប់អានព្រះពុទ្ធសាសនាដោយសេរី ក៏ពុំតាំងបាននៅយូរប៉ុន្មានទេ ។ នយោបាយផ្សេង ៗ ទំនងនេះ ជាទូទៅ ក៏ពុំសូវមានសេចក្ដីខ្លាំងក្លាប៉ុន្មានដែរ, ឬមិនដូច្នោះ ក៏ត្រូវផ្លាស់ប្ដូរទៅវិញ ទាល់តែអស់រលីង ។ ព្រឹត្តិការណ៍នេះ គេហៅថា "ហេតុកំណាចនៃចក្រពត្តិទាំង៣" ។

សរុបសេចក្ដីទៅ គេអាចពោលបានថា ក្នុងរយៈពេល២.០០០

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំ តាំងពីព្រះពុទ្ធសាសនា បានផ្សាយចូលទៅក្នុងប្រទេសចិន ដរាប ដល់ពេលដែលកុម្មុយនិស្ត បានឡើងកាន់អំណាចនោះ ក្រោយពីភស្តុតាង ក្នុងប្រវត្តិសាស្ត្រ ដែលអាងមកខាងលើនេះ ប្រជាជនចិនបានប្រព្រឹត្តចំ-ពោះព្រះពុទ្ធសាសនាដោយគ្មានរង្កៀស និងដោយគោរព ជាដរាបមក ។

គួរកត់សម្គាល់ថា ក្នុងពេលដែលពួកកុម្មុយនិស្តចិន ដណ្ដើម អំណាចគ្រប់គ្រង ទុកក្នុងកណ្ដាប់ដៃរបស់ខ្លួនបានហើយ ប្រពៃណីចិន ដែលមិនរង្កៀសចំពោះព្រះពុទ្ធសាសនានោះ ក៏បានសាបសូន្យទៅ ។ វត្ថុដែលកើតឡើងជំនួស គឺនយោបាយបំផ្លេចបំផ្លាញ ។

ដូច្នេះ ព្រះពុទ្ធសាសនា ដែលក្នុងរយៈពេល ២០០០ ឆ្នាំកន្លង មកហើយ បានត្រូវគេសាបព្រោះពូជចម្រើនលូតលាស់ រហូតដល់មាន ផ្លែផ្កា សំខាន់ នៅក្នុងប្រទេសចិននោះ ក៏បានត្រូវជួបប្រទះនឹងគ្រោះ កំណាចយ៉ាងធំ ពីនយោបាយនៃកុម្មុយនិស្តចិន ដែលត្រូវការបំផ្លាញ ព្រះពុទ្ធសាសនា ឲ្យសាបសូន្យទៅក្នុងទីបំផុត ។

www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ២

## ជេទ្ធិកុម្មុយនិស្តប្រឆាំងនឹងព្រះពុទ្ធសាសនា

### ១– ទស្សនៈកុម្មុយនិស្តចិន ចំពោះរឿងសាសនា

សាវ័កនៃលទ្ធិម៉ាក់ស្ទេនីន តាំងពីអ្នកធំរហូតដល់អ្នកតូច ពុំជឿព្រះជាម្ចាស់ទេ ។ ទិនានុប្បវត្តិ « ប្រជាជន » ដែលជាកាសែតផ្លូវការរបស់កុម្មុយនិស្តចិន បានផ្សាយថា កាលពីខែកញ្ញា គ.ស. ១៩៥១ (ព.ស. ២ ៤៩៤) គណៈបក្សកុម្មុយនិស្តចិន បានបញ្ជាក់ឲ្យឃើញថា លទ្ធិកុម្មុយនិស្ត និងសាសនាទាំងឡាយ បានស្ថិតនៅក្នុងទិសម្ខាងម្នាក់ ហើយជាប្រតិបក្សនឹងគ្នាយ៉ាងខ្លាំង ។ ពួកកុម្មុយនិស្ត ពុំជឿព្រះជាម្ចាស់ទេ ព្រោះគេយល់ឃើញគ្រប់បែបគ្រប់យ៉ាង ទៅក្នុងគន្លងនៃវត្ថុនិយមទាំងអស់ ហើយបដិសេធសេចក្ដីសំខាន់និងតម្លៃរបស់ចិត្តផង ។

www.budinst.gov.kh www.elibraryofcambodia.org

ពួកនេះ ពុំមែនគ្រាន់តែបដិសេធសាសនាទៅតាមគោលការណ៍ គឺតាមទ្រឹស្តីនៃយថាវត្ថុនិយម និងការតស៊ូវរវាងជាន់វណ្ណៈ ប៉ុណ្ណោះទេ ថែមទាំងចាត់ទុកសាសនានេះថា ជារបបមូលធននិយម និងជាប្រតិកិរិយា ដែលត្រូវតែបំផ្លាញចោលឲ្យសាបសូន្យអស់ទៅ ជាទីបំផុត ។

ទោះបីពួកកុម្មុយនិស្ត មានឥរិយាបថជូរចត់ចំពោះសាសនាជាដរាបមកក្តី ក៏ពុំដូចគ្នានឹងវិធីដែលពួកនេះបានប្រព្រឹត្តចំពោះ « ពួកអ្នកនយោបាយ » អ្នកធ្វើសកម្មភាពនយោបាយនោះទេ ។ តាមធម្មតា ពួកកុម្មុយនិស្ត ពុំបានបំពេញកិច្ចជាប្រតិបក្សដល់សាសនា ដោយធ្វើគ្រប់ផ្នែកភ្លាម ៗ នោះទេ, ផ្ទុយទៅវិញ ពួកនេះ បានប្រើកលឧបាយបែបស្ពាបស្ពង់ គឺធ្វើសន្សឹម ៗ ទៅសិន ។

## ចុះបើពួកកុម្មុយនិស្ត ពុំជឿព្រះអាទិទេព ជាផ្លូវការទេ ហេតុអ្វីក៏បើកឱ្យមានជំនឿ ក្នុងសាសនាដោយសេរី ?

ទិនានុប្បវត្តិ « ប្រជាជន » ចុះថ្ងៃទី ២៥ កញ្ញា គ.ស.១.៩៥០ បាននិយាយអំពីបញ្ហានេះថា « សាសនា បានកើតឡើងក្នុងពេលដែលមនុស្សបានជួបប្រទះនឹងវត្ថុ ដែលខ្លួនបានចូលចិត្តថា ជាច្បាប់ធម្មជាតិ ឬជាច្បាប់សង្គម ហើយខ្លួនពុំអាចតស៊ូនឹងវត្ថុនេះបាន ក៏ព្រមស្វែងរកជំនួយ ពីវត្ថុអាថ៌កំបាំង និងវត្ថុស័ក្តិសិទ្ធិទាំងនេះ » ។ ដោយហេតុនេះ ដើម្បីនឹងបញ្ឈប់ការរាប់អានសាសនាបាន លុះណាតែមនុស្សមានអំណាចត្រួតត្រាធម្មជាតិ និងបំបាត់ជាផ្លូវការនូវការជិះជាន់សង្កត់សង្កិនពីវណ្ណៈ ឬកម្ទេលនៃការជិះជាន់ដោយវណ្ណៈនោះ ឲ្យផុតរលត់អស់ទៅជាមុនសិន ។ កាលណា បើមានមនុស្សខ្លះពុំអាចដកខ្លួនបានពីទាសភាពនៃលទ្ធិនាយទុន និងលទ្ធិចៅហ្វាយនាយទេ ព្រោះភាពល្ងង់ខ្លៅឬពឹងពាក់

www.budinst.gov.kh www.elibraryofcambodia.org

អំណាចធម្មជាតិជានិច្ចនោះ ស្ទើរតែវត្ថុដែលប្រហែលគ្នានឹងសាសនា ក៏ពុំអាចនឹងលះបង់ ឲ្យអស់ទៅពីសង្គមមនុស្សបានដែរ ។

អត្ថបទនៃទិនានុប្បវត្តិ « ប្រជាជន » នេះ បានបញ្ជាក់ឲ្យឃើញច្បាស់ថា ពួកកុម្មុយនីស្ត ពុំអាចព្រួតគ្រាធម្មជាតិ ពុំអាចបំបាត់ការជិះជាន់សង្កត់សង្កិនពីវណ្ណៈ ឬកម្ទេចនៃការជិះជាន់ដោយវណ្ណៈនោះបានទេ បានជាបើកឲ្យមានជំនឿក្នុងសាសនាដោយសេរី ។

តាមពិត ពួកកុម្មុយនិស្ត បានចាត់ទុកសាសនា គ្រាន់តែជាប្រាកដការណ៍ម្យ៉ាងនៃសង្គម ដែលបញ្ជាក់ឲ្យឃើញថា មនុស្សជាតិបានខំព្យាយាមរត់ចេញពីសេចក្ដីពិត ហើយពួកកុម្មុយនិស្ត បានយល់ឃើញថា មានះរបស់មនុស្ស ក្នុងការស្វះស្វែងរកលោកុត្តរវិស័យនោះគ្រាន់តែជាជំនឿចំពោះជោគវាសនា ដើម្បីស្វែងរកជំនួយ ពីអាថ៌កំបាំងនិងសក្តិសិទ្ធ ដែលពួកកុម្មុយនិស្តចាត់ទុកថាជាការផ្លាស់ប្តូរសភាវៈផ្សេង ៗ ខាងផ្លូវលោក ។

ដោយមានការជំទាស់គ្នារវាងជាន់វណ្ណៈ ពួកកុម្មុយនិស្ត ក្នុងពេលជាមួយគ្នានោះ ក៏ព្រមឲ្យរាប់អានសាសនា ប៉ុន្តែ គង់នឹងបញ្ឈប់

www.budinst.gov.kh www.elibraryofcambodia.org

លែងឲ្យជឿវិញក្នុងទីបំផុត ដោយអាងថា ការផ្លាស់ប្តូរសម្ព័ន្ធនៃចំណែកផ្សេង ៗ ខាងការដោះនឹមនោះ កាលបើការជិះជាន់រវាងជាន់វណ្ណៈអស់ទៅ ក៏នឹងអាចបញ្ឈប់លែងកាន់សាសនាបាន ។

ដោយហេតុនេះ ក្នុងការអនុវត្តន៍កិច្ចបង្ក្រាបការទាស់ទែងគ្នារវាងវណ្ណៈនោះ ទីបំផុតទៅ ពួកកុម្មុនិស្តនឹងគេចឲ្យផុតពីការបំបាត់សាសនាឲ្យអស់ ពុំបានទេ ។

សាសនា មានគ្រឿងសម្គាល់សម្រាប់ពួកកុម្មុយនិស្តចិនដូចគ្នានឹងគ្រឿងសម្គាល់ ដែលមាននៅក្នុងវិន័យរបស់លទ្ធិម៉ាក់ឡេនីន ។ ក្នុងពេលមួយ ឡេនីន បានពោលថា “ សាសនា មានព្រឹត្តិការណ៍នៅជុំវិញ ។ ព្រះជាម្ចាស់ ដែលនៅកណ្តាល បានធ្វើសម្ព័ន្ធរវាងព្រះជាម្ចាស់និងមនុស្ស ” ហើយឡេនីនបានពោលទៀតថា “ សាសនា ជាអំណាចដែលសង្កត់សង្កិនផ្លូវចិត្ត ហើយកប់នៅគ្រប់ទីកន្លែង ដោយទូទៅច្រើនកប់នៅក្នុងកន្លែងដែលមានមនុស្សច្រើន ។ សាសនា បានស្នើឲ្យមនុស្សទៅជាអ្នកប្រៀនប្រដៅបានដោយងាយ ហើយអត់ធន់ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ជីវភាពរបស់ខ្លួន ធ្វើឲ្យមានសេចក្ដីសង្ឃឹមនិងសប្បាយចិត្តថា ក្នុងទីបំផុតទៅ នឹងបានទទួលរង្វាន់ពីឋានសួគ៌ខាងលើ ។

ចំពោះសម្អាងដូចខាងលើនេះ ពួកកុម្មុយនិស្តបាននិយាយមួយបែបទៀតថា "សាសនាសម្គាល់សេចក្ដីថា មនុស្សត្រូវជឿថា មានវត្ថុអាថ៌កំបាំង ឬមានអំណាចអស្ចារ្យម្យ៉ាង ដែលអាចគ្រប់គ្រងជតាកម្មរបស់មនុស្សនិងលោក ។ ដោយហេតុនេះ សាសនាទើបសង្កត់សង្កិនមនុស្សជាតិដោយគំរាមថា នឹងត្រូវបានទទួលទោស ប្រសិនបើពុំធ្វើតាមអំណាចនេះទេ" ។

ពួកកុម្មុយនិស្ត បានទាំងនិយាយទៀតថា "សាសនា បានញុះញង់និងគាំទ្រអ្នកដែលគោរពរាប់អានឲ្យលះបង់ការបម្រះ ដើម្បីស្វែងរកសេចក្ដីចម្រើនខាងផ្លូវលោក" ។

ពួកកុម្មុយនិស្ត បានដឹងច្បាស់ថា វិធានការបង្ក្រាបការរាប់អានសាសនានោះ នឹងប្រើរបៀបទារុណកម្មតែត្រឹមមួយលើក ពុំអាចសម្រេចលទ្ធផលបានទេ ប៉ុន្តែ ខ្លាចក្រែងមានពលិកម្មនិងការតស៊ូរបស់អ្នកកាន់សាសនាកើតឡើង ដែលអាចបណ្ដាលឲ្យមានការមិនស្ងប់នៅក្នុង

www.budinst.gov.kh www.elibraryofcambodia.org

សង្គម ហើយនាំឲ្យមានការលំបាកដល់ពួកកុម្មុយនិស្ត ក្នុងឆាកនយោបាយផង ។

គេបានដឹងថា ពួកកុម្មុយនិស្តបានព្រមទទួលស្គាល់ថា “ ចំពោះបញ្ហាស្ដីពីការរាប់អានសាសនានេះ, តាមពិត ការប្រើអំណាចបង្ខាប់បញ្ហា សូម្បីតែបន្តិចបន្តួច ក៏គ្មានប្រយោជន៍អ្វីទាល់តែសោះ ហើយវាត្រឡប់ជាបណ្ដាលឲ្យមានភ័យនិងគ្រោះថ្នាក់ទៅវិញ ” ។

**បើដូច្នេះ តើពួកកុម្មុយនិស្ត លើកលែងការវាយប្រហារសាសនាឬអ្វី ?**

ពុំឈប់វាយប្រហារទេ គ្រាន់តែពួកនេះងាកទៅប្រើវិធីផ្សេងទៀតប៉ុណ្ណោះ ។ ក្នុងករណីនេះ គេអាចសង្កេតឃើញច្បាស់ នូវភាពកន្ទះរា នៃពួកកុម្មុយនិស្តចិន ចំពោះព្រះពុទ្ធសាសនា ដោយបណ្ដាលមកពីមានបរាជ័យ នៃនយោបាយបង្ក្រាបរបស់ខ្លួន ។ ទិនានុប្បវត្តិ « ប្រជាជន » បានឲ្យដំបូន្មានថា « សាវ័កនៃលទ្ធិម៉ាក់ស៊ីនីទ កាលបើជួបនឹងបញ្ហាសាសនានៃប្រជាជន រមែងចាត់ទុកបញ្ហាទាំងនេះ ថាជាបញ្ហាដែលមានពិត ក្នុងប្រវត្តិសាស្ត្រ » ។

www.budinst.gov.kh www.elibraryofcambodia.org

ឡេនីនបានថែងនៅក្នុងសៀវភៅរបស់លោក ឈ្មោះ « គរិយាបថនៃបក្សកម្មាភិបាល ចំពោះបញ្ហាសាសនា » ថា : « យើងត្រូវអធិប្បាយអំពីគំនិតនៃលទ្ធិយថាវត្ថុនិយមថា ហេតុដូចម្ដេច ទើបសាសនាផ្សព្វផ្សាយទៅក្នុងចំណោមប្រជារាស្ត្រ ? » ។

បើប្រើ « ទស្សនៈនៃអ្នកយថាវត្ថុនិយម » ដើម្បីអធិប្បាយអំពីប្រភពកំណើតនៃសាសនាវិញ ក៏ត្រូវតែធ្វើសាសនានេះ ឲ្យទៅជាផលិតផលរបស់ធម្មជាតិ និងរបស់ភាពប្រតិបក្សគ្នានៃជាន់វណ្ណៈ ។ វិធីនេះ បានធ្វើឲ្យពួកកុម្មុនិស្ត មានផ្លូវអាចនាំយកសាសនាទៅប្រើធ្វើបធ្យោបាយសម្រាប់បង្កើតប្រយោជន៍ដល់ពួកខ្លួនបាន ព្រោះពួកកុម្មុយ-និស្តបានដឹងច្បាស់ថា សាសនា មានអានុភាពយ៉ាងធំនៅក្នុងចំណោមប្រជាជន ។

ពួកកុម្មុយនិស្ត បានយល់ឃើញចំពោះសាសនាថា « មានលក្ខណៈជាអំណាចដែលមានគេនិយមច្រើន ដែលនឹងអាចយកមកប្រើជាប្រយោជន៍បាន ។ ក្នុងពេលដែលមានការប្រឆាំងគ្នាខាងនយោបាយប្រសិនបើសង្កត់ពុំបាកទេ សាសនា អាចកើតទៅជាអំណាចប្រឆាំង

មួយដែលមានកម្លាំងច្រើន" ។

ដោយពិចារណាឃើញដូច្នេះហើយ បានជាពួកកុម្មុយនិស្ត ព្រមទុកសាសនា ឲ្យមានតទៅទៀតមួយរយៈមួយដំណើរសិន ។

ក្នុងសៀវភៅឈ្មោះ « គោលប្រជាធិបតេយ្យថ្មី » ម៉ៅសេទុង បានស្វាធ្យាយពាក្យប្រដៅរបស់ឡេនីន អំពីបញ្ហាប្រើសាសនា ឲ្យកើតជាប្រយោជន៍បានយ៉ាងណាខ្លះ ?

លោកម៉ៅសេទុង បានថែងថា «គណៈបក្សកុម្មុយនិស្តចិន អាចចាត់តាំងគណៈបក្សរួម បានយ៉ាងស្រួល ក្នុងកិច្ចការនយោបាយ សម្រាប់តស៊ូនឹងពួកចក្រពត្តិនិយម ដោយរួមគ្នានឹងពួកដែលមានឧត្តមគតិដទៃទៀត សូម្បីតែពួករាប់អានសាសនាក៏បាន ប៉ុន្តែ ត្រូវកុំបណ្តោយទៅតាមឧត្តមគតិឬពាក្យប្រៀនប្រដៅ នៃសាសនារបស់ពួកនេះ ជាដាច់ខាត » ។

សេចក្តីថ្លែងការណ៍នៃម៉ៅសេទុងនេះ បានបញ្ជាក់ឲ្យឃើញច្បាស់ថា ឥរិយាបថ នៃគណៈបក្សកុម្មុយនិស្តចិន ចំពោះសាសនានេះ បានត្រូវកំណត់ឡើង ដោយអនុលោម ទៅតាមវត្ថុបំណងនៃនយោបាយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ២–កុម្មុយនិស្តចិន មានទស្សនៈ ចំពោះព្រះពុទ្ធសាសនារបៀបណា ?

### ក– លទ្ធិកុម្មុយនិស្ត បានប្រឆាំង នឹងគោលធម៌នៃព្រះពុទ្ធសាសនា :

តាមព្រឹត្តិការណ៍ដែលមានមក ពួកកុម្មុយនិស្តពុំបានវាយប្រហារទ្រឹស្តី ឬ គោលធម៌ព្រះពុទ្ធសាសនាទេ ។ ដូច្នេះ ទើបគេពុំអាចនឹងសម្គាល់ឲ្យដឹងថា ពួកកុម្មុយនិស្តចិន មានយោបល់ ចំពោះព្រះពុទ្ធសាសនាត្រឹមថ្នាក់ណា ។ ទោះជាយ៉ាងណាក្តី បើធៀបប្រៀបគោលការណ៍របស់កុម្មុយនិស្ត និងគោលព្រះពុទ្ធសាសនាទៅ គេអាចសរុបភាពផ្សេងគ្នា នៃលទ្ធិទាំងពីរយ៉ាងនេះ :

ពួកកុម្មុយនិស្ត មានជំនឿចំពោះលទ្ធិយថាវត្ថុនិយម និងការតស៊ូរវាងជាន់វណ្ណៈ ។

ដូច្នេះ ការដែលពួកកុម្មុយនិស្តទុកព្រះពុទ្ធសាសនា ឲ្យឋិតនៅតទៅទៀតក្នុងប្រទេសចិននោះ គឺជាការលាក់ពុតមួយនៃនយោ - បាយទន់ភ្លន់ ដែលត្រូវឲ្យពុទ្ធសាសនានោះត្រូវបាត់បង់ទៅដោយឯកឯង ក្រោយដែលពួកចាស់ ៗ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនានេះស្លាប់បាត់បង់អស់ទៅ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធសាសនា បានលើកយកមេត្តាករុណា មកធ្វើជាគោលចារឹករបស់ខ្លួន ហើយប្រដៅប្រដៅមនុស្ស កុំឲ្យធ្វើបាបទាំងអស់ ឲ្យបំពេញកុសល និងឲ្យជម្រះចិត្តឲ្យបរិសុទ្ធ ។ គឺមេត្តាករុណាជាគោលចារឹកដំបូងនៃព្រះពុទ្ធសាសនានេះហើយ ដែលនាំឲ្យកើតសេចក្តីប្រណី ហើយលុះណាតែមានសេចក្តីប្រណីនេះ ទើបឧត្តមគតិសមភាព អាចកើតមានឡើងបាន ។

ចំណែកពាក្យប្រដៅរបស់កុម្មុយនិស្តវិញ មានលក្ខណៈនិងទីដៅផ្ទុយគ្នាយ៉ាងស្រឡះ ពីព្រះពុទ្ធសាសនា, ពាក្យប្រដៅស្តីពីការតស៊ូទល់នឹងជាន់វណ្ណៈនោះ បានត្រូវតាក់តែងឡើង ពីគោលនៃសេចក្តីស្អប់ខ្ពើម ។ លទ្ធផលពីពាក្យប្រៀនប្រដៅឲ្យស្អប់ខ្ពើមនេះ គេអាចឃើញបាន ពីសេចក្តីឫស្យាររវាងវណ្ណៈនាយទុន និងវណ្ណៈអធន, ពីការបង្ហូរឈាមគ្នា និងពីការបដិវត្តន៍ ។ ដូច្នេះ គោលព្រះពុទ្ធសាសនា និងគោលនៃលទ្ធិកុម្មុយនិស្ត ពុំមែនគ្រាន់តែចូលគ្នាពុំបាន ដូចទឹកនិងប្រេងប៉ុណ្ណោះទេ គឺត្រូវយកទៅប្រើខុសផ្លូវគ្នាទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

តាមសេចក្ដីយល់ឃើញនៃកុម្មុយនិស្ដចិន ពាក្យប្រៀនប្រដៅនៃព្រះពុទ្ធសាសនា ជាគ្រឿងរាំងរានូវចិត្ដសាស្រ្ដយ៉ាងខ្លាំង ចំពោះកិច្ចបង្ក្រាបតស៊ូរវាងជាន់វណ្ណៈ ដែលអាចត្រូវបំផ្លាញជីវិតគ្នា និងត្រូវបង្ហូរឈាមគ្នា ។ ដោយហេតុនេះ ពួកកុម្មុយនិស្ដ ក៏ចាត់ទុកព្រះពុទ្ធ-សាសនានៅក្នុងផ្នែកជាមួយគ្នានឹងសាសនាដទៃ ៗ ដែរ គឺទុកព្រះពុទ្ធសាសនា ជា «ថ្នាំញៀន» ដូចឡេនីនបានពោលទុកមក ដោយសំ-ដៅយកភាពស្រវឹងខាងផ្លូវចិត្ដ ដែលអាចធ្វើឲ្យខួរក្បាលនៃពួកអ្នកដែលត្រូវគេសង្កត់សង្កិននិងពួកអ្នកដែលត្រូវគេនាំមកប្រើ ដើម្បីឲ្យស្រវឹងនោះបង្កើតឲ្យមានគ្រោះភ័យដល់ឧត្ដមគតិនៃការតស៊ូ រវាងជាន់វណ្ណៈ ។ ក្នុងករណីនេះ ពួកកុម្មុយនិស្ដ បានចាត់ទុកព្រះពុទ្ធសាសនាថា ជារឿងជំនឿដោគគ្រោះ ហើយជាការថយក្រោយ និងងងឹតងល់ ។

សូមបែរទៅពិនិត្យពិចារណា អំពីទស្សនៈរបស់កុម្មុយនិស្ដដែលទាក់ទងនឹងរឿងនេះបន្ដិច ។ តទៅនេះ ជាពាក្យដែលចម្លងមកពីការពិចារណា នូវសេចក្ដីរាយការណ៍ ដែលមានឈ្មោះថា "ការអប់រំសម្រាប់នាងជី" ។

www.budinst.gov.kh www.elibraryofcambodia.org

ការបួសក្នុងព្រះពុទ្ធសាសនា សំដៅយកការសម្លឹងឃើញវត្ថុគ្រប់យ៉ាង ថាជាទោសកំណាច និងការប្រាថ្នាលះបង់លោកិយវិស័យ ហើយក្នុងពេលជាមួយគ្នានេះ ចំពោះស្ត្រីសម័យចាស់ អ្នកដែលបានត្រូវទុក្ខបៀតបៀនក្នុងជីវិតផ្លូវលោកច្រើនមកហើយ រមែងស្វែងរកទីពំនាក់ដើម្បីការរួចផុតរបស់ខ្លួន ។

ខ–ទស្សនៈរបស់កុម្មុយនិស្ត ទាក់ទងនឹងភារៈបច្ចុប្បន្ននៃព្រះពុទ្ធសាសនា៖

“ នយោបាយកុម្មុយនិស្តចិន ចំពោះព្រះពុទ្ធសាសនានោះ បានប្រកាន់យកភាពពិតប្រាកដ នៃព្រះពុទ្ធសាសនាក្នុងប្រទេសចិនសព្វថ្ងៃនេះ ជាគោលសំខាន់ ។

ពួកកុម្មុយនិស្តយល់ថា ព្រះពុទ្ធសាសនា ខ្វះការចាត់របៀប ហើយពុំបើកឱកាសឲ្យធ្វើ “ បដិរូប ”(Rèforme) ។

ដោយពួកកុម្មុយនិស្តបានដឹងច្បាស់ថា ព្រះពុទ្ធសាសនា បានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ទៅក្នុងចំណោមប្រជាជន បានជាពួកនេះចាត់ការប្រុងប្រយ័ត្នចំពោះផលវិបាក ដែលនឹងអាចកើតមានឡើងបានពីការប៉ះពាល់ខាងនយោបាយ ។

www.budinst.gov.kh www.elibraryofcambodia.org

ភាពបែកផ្សេងគ្នា រវាងព្រះពុទ្ធសាសនា និងសាសនាដទៃទៀត នៅក្នុងប្រទេសចិន ពុំបានត្រូវគេចាត់ការគ្រប់គ្រងឲ្យបានហ្មត់ចត់ទេ ព្រោះគេបានចាត់ទុកសាសនាទាំងអស់ គ្រាន់តែជាសាសនាផ្ទាល់ខ្លួនរបស់បុគ្គលនិមួយ ៗ តែប៉ុណ្ណោះ ។ ស្ទើរតែគ្រប់ប្រទេសគណៈសង្ឃ ដែលជាអ្នកគ្រប់គ្រងសាសនា ក៏ពុំបានទទួលកិច្ចការពារអ្វីយ៉ាងមុតមាំសោះដែរ ។

ពួកកុម្មុយនិស្តបានយល់ឃើញថា ជីវិតរបស់ភិក្ខុនិងភិក្ខុនី ឬនាងជី ជាជីវិតរស់នៅយ៉ាងសន្តោសក្នុងវត្ត ហើយបែកចេញពីប្រជាជនទាំងឡាយ ។ គណៈសង្ឃបានប្រៀនប្រដៅតែមួយកន្លែង ៗ ដូចបុគ្គលដែលគ្របដណ្តប់ដោយ សំពត់ភាសាខពស្រ្តទាប់ផ្កាំ ( សំពត់ជ្រលក់ទឹកអម្ពត់ពណ៌លឿង ) បានត្រាច់ទៅមកតែម្នាក់ឯង ក្នុងចំណោមពពួកមនុស្ស ហើយគ្មានទាំងអ្នកណាងាកមើលសោះផង ។

ក្នុងប្រទេសចិនដីគោក ពុទ្ធសាសនិកជន គ្មានការប្រជុំគ្នាដូចជាអ្នកមានសទ្ធាដែលពីដើមមកធ្លាប់តែមករួមប្រជុំយ៉ាងច្រើននោះទេ ។ គណៈសង្ឃ ក៏ពុំបានធ្វើកិច្ចការពារវត្តអារាមផ្សេង ៗ ដែរ ។ របៀបរបស់

www.budinst.gov.kh www.elibraryofcambodia.org

វត្តមានត្រឹមតែកិច្ចការប៉ុណ្ណោះ ហើយកុម្មុយនិស្តពុំបានយកចិត្តទុកដាក់ទំនុកបម្រុង នូវសម្ពន្ធភាពខាងផ្លូវចិត្ត រវាងភិក្ខុ ភិក្ខុនី និងឃរាវាសសោះទេ ។ ក្នុងទស្សនៈរបស់កុម្មុយនិស្ត បានប្រកាន់ថា វត្ត គ្រាន់តែជាកន្លែងសម្រាប់អ្នកផ្សងដោគមកអុជទៀនធូប ក្រាបសំពះ តែប៉ុណ្ណោះ ។

ពួកកុម្មុយនិស្ត ពុំបានចាត់ទុកព្រះពុទ្ធសាសនាក្នុងប្រទេសចិនឲ្យដូចគ្នានឹងការចាត់ទុកសាសនាឡាមៈ ( lama ) របស់ទីបេត៍ ( Tibet ) ឬម៉ុងហ្គោលី ( Mongolie ) ដែលមានការចាត់របៀបល្អយ៉ាងច្រើននោះទេ ហើយនៅទីបេត៍ មានភាពនយោបាយជាពិសេស ដែលនាំឲ្យពួកកុម្មុយនិស្តបដិសេធពុំបានថា គណៈសង្ឃ ពុំបានទទួលការគាំទ្រពីប្រជជននោះទេ ។

សេចក្ដីរាយការណ៍នៃកាសែតចេញរាល់ថ្ងៃ នៅក្រុងប៉េកាំងមួយច្បាប់ ឈ្មោះ ហួងមិន ( Huong Min ) បានពោលជាអាទិ៍ថា " អំបូរជនជាតិទីបេត៍ ទោះបីអ្នកចិញ្ចឹមសត្វ ឬ ជាកសិករក្ដី សុទ្ធតែជា

www.budinst.gov.kh www.elibraryofcambodia.org

អ្នកជ្រះថ្លាចំពោះសាសនាឡាមៈទាំងអស់ ។ ដូច្នេះហើយ បានជាអ្នកគ្រប់គ្រងទីបេត៍ យកសាសនាឡាមៈមកប្រើ ដើម្បីធ្វើឲ្យប្រជាជនវង្វេងវង្វាន់ទៅជាឧបករណ៍សម្រាប់គាំទ្រអំណាច ឬជនពួជពង្សនោះ និងដើម្បីឲ្យជនពួជពង្សនោះ ទៅជាឧបករណ៍សម្រាប់ធ្វើប្រយោជន៍ដល់ខ្លួន ។ នេះ ជាអត្ថាធិប្បាយដែលបញ្ជាក់ឲ្យឃើញថា ហេតុដូចម្ដេច បានជាកុម្មុយនិស្តប្រើនយោបាយទន់ភ្លន់សម្រាប់សាសនាឡាមៈ ។

ទោះជាយ៉ាងណាក្ដី កាលណា បើព្រះពុទ្ធសាសនាគ្មានចាត់របៀបគ្រប់គ្រងឲ្យបានត្រឹមត្រូវទេ ក៏សាសនានេះ គ្មានអំណាច និងគ្មានកម្លាំងអ្វី សម្រាប់តស៊ូទល់នឹងការសង្កត់សង្កិន របស់កុម្មុយនិស្តបានឡើយ ។ ដោយហេតុនេះ កិច្ចការបដិរូបយ៉ាងទូលំទូលាយ ដូចបានប្រើចំពោះអ្នករាប់អានសាសនាកាតូលីក (Catholique) និងប្រូ-

www.budinst.gov.kh www.elibraryofcambodia.org

គេស្តង់ (protestent) នោះ ស្ទើរតែយកមកប្រើពុំបានសោះទេ ចំពោះព្រះពុទ្ធសាសនាដែលមានរបៀបកិច្ចការពុំបានហ្មត់ចត់ ។

ដើម្បីផលប្រយោជន៍ខាងនយោបាយ ពួកកុម្មុយនិស្តក៏ងាកមកយកចិត្តទុកដាក់ ចំពោះរឿងដែលមានពុទ្ធសាសនិកជននៅពាសពេញទាំងពិភពលោក ព្រះពុទ្ធសាសនាក្រៅពីមានប្រវត្តិយ៉ាងយូរក្នុងប្រទេសចិន នៅមានការផ្សាយទូទៅក្នុងអាស៊ីភាគអាគ្នេយ៍ផង នៅសាធារណរដ្ឋខ្មែរ ភូមា លាវ ព្រះពុទ្ធសាសនាបានផ្សព្វផ្សាយជាពិសេស ព្រមទាំងបានត្រូវចាត់ទុកជាសាសនារបស់រដ្ឋផង ។

ក្នុងពេលជាមួយគ្នានេះ ព្រះពុទ្ធសាសនា ក្នុងប្រទេសចិនអាចមានឥទ្ធិពលជាងប្រទេសដទៃក្នុងអាស៊ី ដោយមានប្រទេសជាច្រើនបានចម្លងព្រះពុទ្ធសាសនាពីប្រទេសចិន ហើយមានអាណិកជនចិនក៏បានទៅនៅ និងយកសាសនានេះទៅផ្សាយក្នុងប្រទេសជាច្រើនទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

កាសែតកុម្មុយនិស្តមួយច្បាប់បានពោលថា » ការផ្សព្វផ្សាយយ៉ាងវិសាលនៃព្រះពុទ្ធសាសនានេះ បានទៅដល់លង្កា (Ceylan) ភូមា (Birmanie) វៀតណាម (Vietnam) ឥណ្ឌា (Inde) និងប្រទេសតូចដូចភូតាន (Bhutan) និងណេប៉ាល់ ( Népal ) ហើយផ្សាយយ៉ាងទូលំទូលាយ តទៅទៀតស្ទើរតែទូទៅទាំងទ្វីបអាស៊ី ។ ក្នុងប្រទេសខ្លះ ព្រះពុទ្ធសាសនា ជាសាសនារបស់ជាតិ ហើយប្រទេសខ្លះទៀតមានអ្នកជ្រះថ្លាចំពោះព្រះពុទ្ធសាសនាយ៉ាងច្រើន ព្រមទាំងប្រតិបត្តិសាសនកិច្ចរាល់ថ្ងៃផង ។

ទោះបីព្រះពុទ្ធសាសនាក្នុងប្រទេសចិន ពុំបានចាត់ការឲ្យមានរបៀបដូច្នេះក្តី ក៏មានប្រវត្តិរាប់រយឆ្នាំមកហើយ ហើយមានអ្នកមានសទ្ធាជ្រះថ្លាយ៉ាងច្រើន ដូចលោក ជូសាន លេខាធិការរងនៃសហពន្ធព្រះពុទ្ធសសនា បានពោលថា » ព្រះពុទ្ធសាសនាក្នុងប្រទេសចិនមានប្រវត្តិដ៏យូរលង់ ហើយក្នុងពេលមួយ ព្រះពុទ្ធសាសនាមានឥទ្ធិពល

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងខ្លាំងក្លាខាងនយោបាយ និងខាងវឌ្ឍនធម៌របស់ជាតិ ។ ប្រជាជនចិនចំនួនច្រើនបានរាប់អានព្រះពុទ្ធសាសនា គឺមួយភាគធំនៃពួកកម្មករ ជាពិសេសគឺពួកស្ត្រី ។ ក្នុងចំណោមពួកម៉ុងហ្គោល ជាពិសេសជាតិទីបេត៌ បានរាប់អានព្រះពុទ្ធសាសនា យ៉ាងច្រើន » ។

## ឥរិយាបថចំពោះព្រះសង្ឃ ;

កុម្មុយនិស្តចិនបានប្រកាន់ជានិច្ចថា ការរាប់អានព្រះពុទ្ធសាសនា គ្រាន់តែជាការប្រកាន់ជោគគ្រោះប៉ុណ្ណោះ ។ ដូច្នេះហើយបានជាពួកកុម្មុយនិស្ត ប្រកាន់ជានិច្ចថា ភិក្ខុ និងភិក្ខុនី មានអាជីវៈផ្សងជោគគ្រោះនិងហួសសម័យ ដោយត្រូវទៅសូត្រមន្ត និងប្រកបសាសនកិច្ចរាល់ថ្ងៃ នៅចំពោះមុខព្រះពុទ្ធរូប ។ ក្នុងទស្សនៈរបស់កុម្មុយនិស្តយល់ថា ភិក្ខុ និងភិក្ខុនី ពុំមែនគ្រាន់តែជាអ្នករាប់អានជោគគ្រោះប៉ុណ្ណោះទេ គឺថែមទាំងដឹកនាំអ្នកដទៃឲ្យរាប់អានជោគគ្រោះនោះផង ។ ជាងនេះទៅទៀត ក្នុងទស្សនៈរបស់កុម្មុយនិស្តបានចាត់ទុកភិក្ខុ និង ភិក្ខុនីថា ជាអ្នកពុំគួរទុកចិត្តខាងនយោបាយសោះទេ ។

ពួកកុម្មុយនិស្តចិន បានត្មះតិះដៀលនិងជេរប្រមាថព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសង្ឃតាមសារពត៌មានថា « ពួកចាស់ គណៈសង្ឃ ដោយផ្លូវត្រង់ និងដោយផ្លូវ អម មិនច្រើនក៏តិច តែងតែបានទទួលបំរើលទ្ធិចៅហ្វាយនាយ លទ្ធិចក្រពត្តិនិយម និងលទ្ធិនាយទុន ដែលជាពួកបដិកិរិយា » ។

កាសែតកុម្មុយនិស្តមួយច្បាប់ទៀតបានសរសេរថា « ត្រូវតែសន្មតថា ពុទ្ធសាសនិកជន ភិក្ខុ និងភិក្ខុនី ក្នុងប្រទេសទីបេត៍ ជាមនុស្សក្បត់នឹងប្រជាជន នឹងជាតិ ដោយពួកនេះយកអំណាច នៃលទ្ធិចក្រពត្តិនិយម មកធ្វើជាឧបករណ៍សំរាប់ធ្វើឲ្យរបបគ្រប់គ្រងសង្គត់សង្កិនរបស់ខ្លួនអាចមានជីវិតតទៅទៀត »

នេះគឺជាភស្តុតាងមួយបញ្ជាក់ឲ្យឃើញថា លទ្ធិកុម្មុយនិស្តប្រឆាំងចំពោះព្រះពុទ្ធសាសនា ដោយទុកសាសនានេះជាសត្រូវលេខ ១ របស់ខ្លួន ដែលត្រូវតែបំផ្លាញចោល ។

www.budinst.gov.kh www.elibraryofcambodia.org

# ចំពូក ៣

## នយោបាយចិនប្រជាមានិត

## ចំពោះព្រះពុទ្ធសាសនា

សេចក្ដីបរិយាយទាំងប៉ុន្មានរួចមកហើយនេះ បានបញ្ជាក់ឲ្យឃើញច្បាស់ថា កុម្មុយនិស្ដចិន មានបំណងនឹងចងក្រៀក ហើយបំផ្លាញចោលនូវព្រះពុទ្ធសាសនាឲ្យអស់ទៅក្នុងទីបំផុតមែន ។ បើពិនិត្យដោយសើ ។ វិញ នយោបាយកុម្មុយនិស្ដចិន ហាក់ដូចជាគ្មានគោលការណ៍អ្វីពិតប្រាកដចំពោះបញ្ហាព្រះពុទ្ធសាសនានោះទេ ។ ក្នុងគ្រោងការណ៍ពេជិរូបសាសនា របស់កុម្មុយនិស្ដ ក៏គ្មាននិយាយអំពីព្រះពុទ្ធសាសនានោះដែរ ។ ដូច្នេះទើបមានពាក្យចោទសួរថា តើកុម្មុយនិស្ដចិនកំពុងប្រើនយោបាយ បណ្ដោយលែងព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅតាមយថាកម្មមែនឬទេ ?

នយោបាយលាក់ពុតនៃក្រុងប៉េកាំងនេះ អាចនាំឲ្យពុទ្ធសាសនិកជនក្នុងប្រទេសដទៃ យល់ដោយភ័ន្ដច្រឡំថា ព្រះពុទ្ធសាសនា

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងប្រទេសចិនកុម្មុយនិស្តបានស្ថិតនៅក្នុងឋានៈរួចភ័យ ។ តាមពិត ពួកកុម្មុយនិស្តចិន បានខំប្រឹងលាក់បំបាំងនូវកិច្ចប្រតិបត្តិការរបស់ខ្លួន ប្រឆាំងចំពោះព្រះពុទ្ធសាសនា នៅក្នុងវាំងននដែកមួយដែលពិភព លោកខាងក្រៅពុំងាយនឹងបានដឹងទេ ហើយការនេះស្ទើរតែបានសម្រេច ទៅហើយផង ។

ពទៅនេះ យើងសូមងាកទៅពិចារណារកហេតុផលចំពោះ ការដែលកុម្មុយនិស្ត ចាត់វិធានការណ៍បំផ្លាញព្រះពុទ្ធសាសនាក្នុង ប្រទេសចិនឲ្យសាបសូន្យ ទៅបន្តិចម្តងៗនោះសិន ។ ក្នុងករណីនេះ ប្រសិនបើគេពិនិត្យមើល តែបទបញ្ញត្តិ និងសេចក្តីថ្លែងការណ៍ផ្សេង ៗ របស់កុម្មុយនិស្តមុខជាមានការភ័ន្តច្រឡំ ព្រោះនយោបាយរបស់កុម្មុយ និស្តចិន ចំពោះព្រះពុទ្ធសាសនាជានយោបាយ " **គុកចាំសីល** " គឺគុកដែលសម្រួមដើម្បីចាំចាប់ត្រីបរិភោគ ។

នៅក្នុងគ្រោងការណ៍សាមញ្ញ នៃក្រុមប្រឹក្សានយោបាយនៃ កុម្មុយនិស្តចិនដែលជានីតិសារមូលដ្ឋានមានមុនរដ្ឋធម្មនុញ្ញ គ.ស ១៩៥៤ ( ព.ស.២៤៩៧ ) ក្តី ក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតចិនក្តី

www.budinst.gov.kh www.elibraryofcambodia.org

មាននិយាយអំពី « សេរីភាពក្នុងការរាប់អានសាសនា » ប៉ុន្តែសេរីភាពនេះ មានត្រឹមតែនៅលើក្រដាសប៉ុណ្ណោះ គេពុំដែលឃើញពួកកុម្មុយនិស្តយកទៅអនុវត្តសោះទេ ។

-មាត្រា៥ ក្រោងការណ៍សាមញ្ញនេះ បានលក្ខខណ្ឌថា « ពលរដ្ឋ នៃសាធារណរដ្ឋ ប្រជាមានិតចិនមានសេរីក្នុងការគិត ការនិយាយ ការបោះពុម្ព ការជំនុំ ការរួមគ្នា ជាសមាគម ការទាក់ទងគ្នា សេរីភាពផ្ទាល់ខ្លួនបគ្គល សេរីភាពក្នុងទីលំនៅ ការផ្លាស់ទីលំនៅ ការរាប់អានសាសនា និងសេរីភាពក្នុងការធ្វើបាតុកម្ម » ។

មកទល់នឹងពេលនេះ គេពុំដែលឃើញក្នុងប្រទេសចិន ប្រជាមានិតមានសេរីភាពដូចជាគេរៀបរាងនេះសោះ ប៉ុន្តែគេឃើញតែភស្តុតាងផ្ទុយ គឺប្រជារាស្ត្រត្រូវស្ថិតទៅក្នុងរាំងននដែក និងក្នុងគំនរឈាមនៃការបង្ក្រាបសង្កត់ ។

www.budinst.gov.kh www.elibraryofcambodia.org

មាត្រា៨៨នៃរដ្ឋធម្មនុញ្ញចិនប្រជាមានិតក៏មានលក្ខខ័ណ្ឌដូចគ្នាថា « ពលរដ្ឋសាធារណរដ្ឋចិន មានសេរីភាពក្នុងការរាប់អានសាសនា » ។

ទិនានុប្បវត្តិប្រចាំសប្តាហ៍ឈ្មោះ « ប្រជាជន » បាននិយាយអំពីការរាប់អានសាសនា តាមគ្រោងការណ៍សាមញ្ញនេះថា :

« នយោបាយរបស់គណៈបក្សកុម្មុយនិស្តចិន ដែលទាក់ទងនឹងសាសនាមានជាដរាបមក ។ មាត្រា ៥ នៃគ្រោងការណ៍សាមញ្ញរបស់ក្រុមប្រឹក្សានយោបាយប្រជាជនចិន បានលក្ខខ័ណ្ឌថា « ប្រជាជនមានសេរីភាពក្នុងការរាប់អានសាសនា » ដែលបានន័យថាប្រជាជនចិនមានសិទ្ធិរាប់អានសាសនា ឬមិនរាប់អានសាសនាបានតាមសេចក្តីពេញចិត្ត ។ សេរីភាពទាំងពីរយ៉ាងនេះ មានច្បាប់ធានាអះអាង

ចំណែករដ្ឋធម្មនុញ្ញនៃសហភាពសូវៀត ត្រង់មាត្រា ១២៤ បានលក្ខខ័ណ្ឌថា « ពលរដ្ឋនិមួយៗអាចរាប់អាន ឬមិនរាប់អានសាសនាណាក៏បាន » ។ រដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

ធម្មនុញ្ញរបស់ស្តាលីន (Staline) នេះបានអនុញ្ញាតឱ្យប្រជាជនមានសេរីភាព ធ្វើការឃោសនាប្រឆាំងនឹងសាសនាបាន ។

ក្នុងអត្ថបទដែលប្រែជាភាសាចិន ដោយកុម្មុយនិស្តចិននោះ ពាក្យថា « សេរីភាពឃោសនាប្រឆាំងនឹងសាសនា » នោះមានគូសសំគាល់នៅពីខាងក្រោម ។ ការដែលពួកកុម្មុយនិស្តបានបើកឱ្យមានសេរីភាពខាងជំនឿ និងបើកឱ្យមានសេរីភាពក្នុងការឃោសនាប្រឆាំងនឹងសាសនា ជាគូគ្នានៅក្នុងរដ្ឋធម្មនុញ្ញនេះ បានបញ្ជាក់ឱ្យឃើញច្បាស់ថា ពួកកុម្មុយនិស្ត ចង់ចាត់ទុកវិធានការណ៍បំផ្លាញព្រះពុទ្ធសាសនា ដែលខ្លួនបានធ្វើទាំងប៉ុន្មាននោះ ជាវិធានការណ៍ស្របច្បាប់ ។ បើគេឱ្យធ្វើនំ ប៉ុន្តែគេមកដណើមទៅចាក់ចោលនៅដី បានន័យថា គេពុំត្រូវការឱ្យបរិភោគទេ ។

លោក លីវ ចាវឌី អតីតប្រធានាធិបតី

( LIV . . CHAO CHI )

នៃសាធារណរដ្ឋចិន កាលនៅជាអនុប្រធាននៃរដ្ឋាភិបាលកណ្តាលបានរាយការណ៍ស្តីពីសេចក្តីព្រាងរដ្ឋធម្មនុញ្ញ សាធារណរដ្ឋប្រជាមានិតចិន

www.budinst.gov.kh www.elibraryofcambodia.org

ដោយ បានបញ្ជាក់នូវអត្ថន័យរបស់ពាក្យថា « សេរីភាពក្នុងការរាប់អានសាសនា » យ៉ាងចំឡែក ។ លោកបានលើកយកបញ្ហាសេរីភាពក្នុងការរាប់អានសាសនា ហើយត្រូវមានការដាក់ទោសអ្នកធ្វើបដិវត្តន៍គប មកបញ្ជាក់ ( អ្នកវិចារនៃប្រទេសខ្លះ គង់នឹកឃើញចំឡែកក្នុងចិត្តដោយបានដឹងថា ក្នុងពេលជាមួយគ្នា ដែលយើងឲ្យកិច្ចការធានារ៉ាប់រងផល់សេរីភាព ក្នុងការរាប់អានសាសនាដល់ពលរដ្ឋ ហើយក៏ប្រាប់តែយើងដាក់ទោសអ្នកធ្វើបដិវត្តន៍គប . . . តាមលក្ខខ័ណ្ឌក្នុងរដ្ឋធម្មនុញ្ញចាស់ដែរ ។ ដែលប្រទេសយើង ឲ្យការឃុំគ្រងរក្សាចំពោះសេរីភាពក្នុងការរាប់អានសាសនាជាផ្លូវការ ហើយឲ្យការឃុំគ្រងរក្សាចំពោះសេរីភាពក្នុងការធ្វើបដិវត្តន៍នោះ ជារឿងពីរដោយឡែកពីគ្នានឹងរួមបញ្ចូលគ្នាបានដោយលំបាក ។

ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញនេះក៏មានខុសគ្នានឹង «គ្រោងការណ៍សាមញ្ញ » ខ្លះ ក្នុងរឿងស្តីពីការបង្ក្រាបបដិវត្តន៍ដូចក្នុងមាត្រា ៧ នៃ « គ្រោងការណ៍សាមញ្ញ » មានលក្ខខ័ណ្ឌថា . . . ចំពោះម្ចាស់ដីការ...ពិតប្រាកដ...ទូទៅ . . . ត្រូវតែដាក់បង្គាប់ឲ្យធ្វើពលិរូប

LIBRARY

ខ្លួនឯងដោយតម្រូវឲ្យធ្វើការដើម្បីកែខ្លួន ឲ្យបានត្រឡប់មកជាមនុស្ស ឡើងវិញជាថ្មី ....» ។

លក្ខខ័ណ្ឌនៃមាត្រានេះ បានត្រូវគេយកទៅអនុវត្តលើពួកអ្នកកាន់សាសនាដែរ ។ ដោយមកពីពួកកុម្មុយនិស្តចិន ចង់បំផ្លាញសាសនា ផ្ទុយស្រឡះហើយ បានជាចកស្រាយពាក្យថា « បដិកិរិយា » នេះ ដោយរាប់បញ្ចូលទាំងបព្វជិត ទាំងអ្នកកាន់សាសនាទូទៅ ។

លក្ខខ័ណ្ឌក្នុងរដ្ឋធម្មនុញ្ញ និងក្នុងគ្រោងការណ៍សាបញ្ញាស្តិពីសេរីភាព និងការរាប់អានសាសនានោះពុំបាននិយាយឲ្យបានជាក់លាក់អំពីនយោបាយពិតប្រាកដរបស់កុម្មុយនិស្តចិន ចំពោះព្រះពុទ្ធសាសនាទេ ដោយមកពីចង់បំភ័ន្តមតិអន្តរជាតិ និងកលល្បិចខាងសង្គ្រាមចិត្តសាស្ត្រ ប៉ុន្តែនៅក្នុងកិច្ចអនុវត្តន៍វិញ មានការជិះជាន់សង្កត់សង្កិន និងធ្វើទុក្ខបុកម្នេញយ៉ាងផ្ទួចក់ទៅលើសាសនា ។

គេបានដឹងថា កុម្មុយនិស្តពុំមែនគ្រាន់តែជាប្រតិបក្សចំពោះសាសនាប៉ុណ្ណោះទេ គឺថែមទាំងបានចាត់ទុកព្រះពុទ្ធសាសនា ជាជំនឿខាងជោគគ្រោះរបបនាយទុន និងជាបដិកិរិយាផង ។ ប៉ុន្តែពួក

www.budinst.gov.kh www.elibraryofcambodia.org

កុម្មុយនិស្ត ពុំទាន់បានប្រើនយោបាយបំផ្លាញព្រះពុទ្ធសាសនាដោយចេញមុខទេ ឃើញប្រើតែកលល្បិចលាក់ពុតនៅឡើយ ដោយមកពីខ្លាចការជ្រួលច្របល់ខ្លាំង ពីដោការពិតណាស់ ប្រសិនបើពួកកុម្មុយនិស្តបំផ្លាញព្រះពុទ្ធសាសនាដោយចេញមុខមែន មុខជាពុទ្ធសាសនិកជន ក្នុងប្រទេសចិន នឹងធ្វើការប្រឆាំងតបវិញយ៉ាងខ្លាំង ហើយនឹងបណ្ដាលឲ្យមានប្រតិកម្មពីពុទ្ធសាសនិកជន និងពុទ្ធបរិស័ទនៅប្រទេសដទៃទៀតផង ដូច្នេះឃើញថា ពួកកុម្មុយនិស្តធ្វើនយោបាយចំពោះព្រះពុទ្ធសាសនាយ៉ាងប្រយ័ត្នប្រយែង ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ក៏ធ្វើប្រតិបត្តិការយ៉ាងស្ងប់ស្ងៀមដោយកិច្ចកលផ្សេង ។ ដើម្បីបំផ្លាញឲ្យអស់ទៅ នូវសាសនានេះក្នុងទីបំផុត ។

ក្នុងកលល្បិចបំផ្លាញព្រះពុទ្ធសាសនា យ៉ាងស្ងប់ស្ងាត់នេះ ពួកកុម្មុយនិស្តបានធ្វើផែនការណ៍ដោយចែកជាចង្កោមតូច ។ យ៉ាងប៉ិនប្រសប់ ហើយកំពុងតែមានគ្រោង តទៅទៀតពុំចេះអស់ ពុំចេះហើយ ។

## ១ - នយោបាយបង្ក្រាបបែបស្ងប់ ៖

ក្នុងពេលដែលកុម្មុយនិស្ត ដណ្ដើមយកបានដែនដីរបស់ចិនសម្រេចហើយ កិច្ចត្រួតត្រាខាងនយោបាយរបស់កុម្មុយនិស្តចិន ពុំទាន់បានត្រូវចាត់ឡើងយ៉ាងមឹុងម៉ាត់ទេ ហើយគ្រោងការណ៍ខាងសង្គមក៏ពុំទាន់បានប្រាកដប្រជាដែរ ។ ដូច្នេះហើយបានជាពួកនេះធ្វើនយោបាយអត់ធ្មត់ចំពោះព្រះពុទ្ធសាសនាសិន ក្នុងពេលដែលខ្លួនកំពុងរវល់ដោយកិច្ចការយ៉ាងច្រើន ខាងបញ្ហាចាត់របៀបក្នុងប្រទេស និងបញ្ហារៀបចំសង្គម គ្មានពេលនឹងចាត់វិធានការណ៍បំផ្លាញព្រះពុទ្ធសាសនាកើត ។ ម្យ៉ាងទៀត ពួកកុម្មុយនិស្ត បានដឹងច្បាស់ថា ការបញ្ចេញឲ្យឃើញថាខ្លួនជាអ្នកជួយការពារព្រះពុទ្ធសាសនានោះ គឺជាកលល្បិចមួយយ៉ាងសំខាន់បំផុតខាងសង្គ្រាមចិត្តសាស្ត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

កុម្មុយនិស្ត ពុំទាន់បានប្រើនយោបាយបំផ្លាញព្រះពុទ្ធសាសនាដោយចេញមុខទេ ឃើញប្រើតែកលល្បិចលាក់ពុតនៅឡើយ ដោយមកពីខ្លាចការជ្រួលច្របល់ខ្លាំង គឺជាការពិតណាស់ ប្រសិនបើពួកកុម្មុយនិស្តបំផ្លាញព្រះពុទ្ធសាសនាដោយចេញមុខមែន មុខជាពុទ្ធសាសនិកជន ក្នុងប្រទេសចិន នឹងធ្វើការប្រឆាំងតបវិញយ៉ាងខ្លាំង ហើយនឹងបណ្តាលឲ្យមានប្រតិកម្មពីពុទ្ធសាសនិកជន និងពុទ្ធបរិស័ទនៅប្រទេសដទៃទៀតផង ដូច្នេះឃើញថា ពួកកុម្មុយនិស្តធ្វើនយោបាយចំពោះព្រះពុទ្ធសាសនាយ៉ាងប្រយ័ត្នប្រយ៉ែង ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ក៏ធ្វើប្រតិបត្តិការយ៉ាងស្ងប់ស្ងៀមដោយកិច្ចកលផ្សេង ៗ ដើម្បីបំផ្លាញឲ្យអស់ទៅ នូវសាសនានេះក្នុងទីបំផុត ។

ក្នុងកលល្បិចបំផ្លាញព្រះពុទ្ធសាសនា យ៉ាងស្ងប់ស្ងាត់នេះ ពួកកុម្មុយនិស្តបានធ្វើផែនការណ៍ដោយចែកជាចង្កោមតូច ៗ យ៉ាងប៉ិនប្រសប់ ហើយកំពុងតែមានគ្រោង តទៅទៀតពុំចេះអស់ ពុំចេះហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ១ - នយោបាយបង្ក្រាបបែបស្ងប់ ៖

ក្នុងពេលដែលកុម្មុយនិស្ដ ដណ្ដើមយកបានដែនដីរបស់ចិនសម្រេចហើយ កិច្ចត្រួតត្រាខាងនយោបាយរបស់កុម្មុយនិស្ដចិន ពុំទាន់បានត្រូវចាត់ឡើងយ៉ាងម៉ឺងម៉ាត់ទេ ហើយគ្រោងការណ៍ខាងសង្គមក៏ពុំទាន់បានប្រាកដប្រជាដែរ ។ ដូច្នេះហើយបានជាពួកនេះធ្វើនយោបាយអត់ឱនចំពោះព្រះពុទ្ធសាសនាសិន ក្នុងពេលដែលខ្លួនកំពុងរវល់ដោយកិច្ចការយ៉ាងច្រើន ខាងបញ្ហាចាត់របៀបក្នុងប្រទេស និងបញ្ហារៀបចំសង្គម គ្មានពេលនឹងចាត់វិធានការណ៍បំផ្លាញព្រះពុទ្ធសាសនាកើត ។ ម្យ៉ាងទៀត ពួកកុម្មុយនិស្ដ បានដឹងច្បាស់ថា ការបញ្ចោញឲ្យឃើញថាខ្លួនជាអ្នកជួយការពារព្រះពុទ្ធសាសនានោះ គឺជាកលល្បិចមួយយ៉ាងសំខាន់បំផុតខាងសង្គ្រាមចិត្តសាស្ត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីដកស្រង់តទៅទៀតនេះ បានបញ្ជាក់ឲ្យឃើញច្បាស់នូវនយោបាយ របស់បក្សកុម្មុយនិស្តក្នុងការបង្ក្រាបពុទ្ធសាសនិកជន តាមបែបស្ងប់ :

ក- នៅថ្ងៃទី ៨ ខែតុលា គ.ស. ១៩៤៨ (ព.ស. ២៤៩១) ទីចាត់ការកណ្ដាលប្រចាំប្រទេសចិន នៃគណៈបក្សកុម្មុយនិស្តចិន បានចេញលិខិតបង្គាប់ការមួយ ហៅថា « គោលការណ៍គ្រួតត្រាថ្ងៃឈ្នួល និងបញ្ចុះថ្លៃអាករ » លិខិត បង្គាប់ការស្ដីពីដីរបស់ព្រះសង្ឃ មានលក្ខ-ខ័ណ្ឌដូចតទៅ :

«ទីដីដែលជាសម្បត្តិសង្ឃ អ្នកណាក៏ប៉ះពាល់ពុំបាន បើពុំបានចាត់ការដោយអង្គការពិសេសណាទេ ទីដីនោះត្រូវចូលទៅក្នុងលក្ខខ័ណ្ឌស្ដីពីការ ចំណាយទីដីនៃម្ចាស់របស់ដែលរត់បាត់ទៅ » ។

បទបញ្ញត្តិស្ដីពីការចំណាយទីដី ដែលម្ចាស់រត់ចោលបាត់នោះ មានលក្ខខ័ណ្ឌដូចតទៅ :

www.budinst.gov.kh www.elibraryofcambodia.org

ទីដីដែលម្ចាស់របស់វត់បាត់ទៅ ត្រូវធ្លាក់ទៅនៅក្នុងការគ្រប់គ្រងរក្សានៃញាតិ បើគ្មានញាតិ ត្រូវរដ្ឋាភិបាលគ្រប់គ្រងរក្សា ។ ក្នុងករណីនេះ កាលបើកាត់ចំនួនប្រាក់ ដែលម្ចាស់របស់មានការទក់ទង ដែលត្រូវតែចំណាយចេញរួចហើយ រដ្ឋាភិបាលត្រូវអាយត្តិ«រក្សា»ប្រាក់ដែលសល់ និង គ្រប់គ្រងទីដី នោះហើយត្រូវប្រគល់ឱ្យម្ចាស់វិញ ក្នុងពេលដែលជននោះត្រឡប់មក» ។

បើគេគ្រាន់តែឃើញច្បាប់នេះដោយឥតពិចារណា ដោយពុំបានឃើញប្រតិបត្តិការ ចៃពួកកុម្មុយនិស្តផ្ទាល់នឹងភ្នែកទេ គេមានសេចក្តីយល់ខុសថា សម្បត្តិនិងទីដីសង្ឃបានទទួលការឃុំគ្រង រក្សាពីពួកកុម្មុយនិស្តគ្មានឃើញប្រតិបត្តិអ្វីសោះទេ ប៉ុន្តែបទបញ្ញត្តិនេះ ជាពិធីការបណ្តោះអាសន្នដែលមានតែនៅលើក្រដាស សម្រាប់ជាមធ្យោបាយឃោសនា បោកប្រាស ហើយគេមានយកទៅប្រើនៅខេត្តខ្លះគ្រាន់តែកលឧបាយសម្រាប់បំភ័ន្តមតិប្រជារាស្ត្រ និងមតិអន្តរជាតិតែ

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះមុនដំបូងពុទ្ធសាសនិកជនហាក់ដូចជាយល់ថា ពួកកុម្មុយនិស្តចិនជួយការពារសាសនា ដូចជាគេបានរ៉ាប់រងនៅក្នុងបទបញ្ញត្តិទាំងឡាយនេះមែន មិនយូប៉ុន្មានក្នុងពេលដែលពួកកុម្មុយនិស្តបានប្រកាសឲ្យប្រើច្បាប់បដិរូបកេរ្យត្រកិច្ច ( Réforme agraire ) គ.ស.១៩៤៩ ( ព.ស ២៤៩២ ) ក៏មានគ្រានៃច្បាប់នេះគម្រូវឲ្យរំលាយចោលនូវកម្មសិទ្ធិនៃអង្គការសាសនា និងរបស់វត្តអារាមនៃសាសនាផ្សេង ។ ។ ទោះបីក្នុងពេលនោះ គេពុំទាន់ដាក់ឲ្យអនុវត្តច្បាប់នេះយ៉ាងម៉ឺងម៉ាត់ក្តី ក៏កម្មសិទ្ធិសាសនា បានត្រូវពួកកុម្មុយនិស្តរំលាយចោល តាមផ្លូវច្បាប់ទៅហើយ ។ នេះគឺជាភស្តុតាងមួយនៃនយោបាយរបស់កុម្មុយនិស្តចិន ដែលតែងតែប្រើស្នៀតវាយអែបជាខាងដើម ហើយបន្ទាប់មក ក៏សម្លាប់អ្នកដែលចាញ់កលឧបាយរបស់ខ្លួននោះ ។

១-ក្នុងគ.ស.១៩៤៩ (ព.ស.២៤៩២) នៅពេលដែលកុម្មុយនិស្តចាត់ឲ្យមាន «កិច្ចប្រជុំទីប្រឹក្សានយោបាយរបស់ប្រជាជន» នៅប៉េកាំងគេបានអញ្ជើញស្តេចភូស្វ៊ីនិងជូសាន ទាំងពីររូបដែលជាពុទ្ធសាសនិកជនមានឈ្មោះបោះសម្លេង ឲ្យធ្វើជាអ្នកតំណាងព្រះពុទ្ធសាសនា

ក្នុងទីប្រជុំ ។ ក្នុងចំណោមអ្នកតំណាងដែលបានចូលរួមប្រជុំតាមការអញ្ជើញ នៃពួកកុម្មុយនិស្តនោះ គ្មានសិទ្ធិអ្វីទេក្រៅពីអង្គុយស្តាប់ និងលើកដៃតាមទំនៀមអនុម័តញត្តិ ដែលកុម្មុយនិស្តស្នើ ឬណែនាំឡើងនោះសោះទេ ។ ទោះបីដូច្នោះក្តី ការដែលពួកកុម្មុយនិស្តបានតម្រូវឲ្យពុទ្ធសាសនិកជន ធ្វើជាតំណាងអង្គការសាសនាក្នុងទីប្រជុំនោះ ក៏រឹតតែជាភស្តុតាងមួយបញ្ជាក់ឲ្យឃើញនូវនយោបាយ បង្ក្រាបព្រះពុទ្ធសាសនា ជាផ្លូវការនេះឯង ។

ការដែលពួកកុម្មុយនិស្តចិន បានក្លែងធ្វើហាក់ដូចជាគោរពព្រះពុទ្ធសាសនាជាធំ ដោយយកអ្នកតំណាងព្រះពុទ្ធសាសនា ទៅរួមក្នុងការប្រជុំកិច្ចការនយោបាយ នេះគឺជាកលល្បិចមួយសម្រាប់លួងលោមចិត្តពុទ្ធសាសនិកជនខាងផ្នែកនយោបាយ ហើយជាពិសេសសម្រាប់អ្នកអាងដល់ «បានះនយោបាយ» នៃព្រះពុទ្ធសាសនាក្នុងប្រទេសចិនថ្មី ដើម្បីយកព្រះពុទ្ធសាសនានេះ ធ្វើជាស្ពានកណ្តាល សម្រាប់ការផ្សាយលទ្ធិកុម្មុយនិស្តចិនដែលម៉ៅសេទុងបានគិតតែងឡើង ។

គួរកត់សម្គាល់ថា នយោបាយបង្ក្រាបបែបស្ងប់របស់កុម្មុយ

និស្តចិននេះ ពុំបានក្រែអនុវត្តយូរប៉ុន្មានទេ គ្រាន់តែបន្តិចមក ពួកកុម្មុយនិស្ត ក៏ប្រើនយោបាយវាយប្រហារដោយត្រង់ ។ នេះជានយោបាយខ្លាស្តម ដែលពុកភ្នែកធ្វើជាចាំសីល ប៉ុន្តែដើម្បីចាប់ត្រីដែលចាញ់កលខ្លួនធ្វើជាអាហារ ។

## ២- នយោបាយវាយប្រហារ

ក្នុងគ.ស.១៩៥១ (ព.ស២៤៩៤) ការគ្រប់គ្រងខាងនយោបាយនៃពួកកុម្មុយនិស្តក្នុងប្រទេសចិន បានចាប់ផ្តើមបង្កើតទៅជារឿងរ៉ាវយ៉ាងខ្លាំង ដោយគេលែងទុកចិត្តទុកថ្នើមព្រះពុទ្ធសាសនាតទៅទៀត ។ នយោបាយបង្ក្រាបបែបស្ងប់ បានក្លាយទៅជារឿងរ៉ាវមានតែក្នុងអតីត ហើយព្រះពុទ្ធសាសនា បានឋិតទៅក្នុងគ្រោះភ័យមួយយ៉ាងធ្ងន់ ដោយនយោបាយវាយប្រហារដែលកុម្មុយនិស្តបានយកមកប្រើជំនួស ។

តាមទ្រឹស្តីរបស់កុម្មុយនិស្ត សភាពសេដ្ឋកិច្ចខាងផ្នែកទ្រព្យសម្បត្តិ ជាគ្រឿងកំណត់មូលដ្ឋានរបស់សង្គម ។ ដូច្នេះ ដើម្បីនឹងផ្លាស់ឧត្តមគតិរបស់មនុស្ស និងធ្វើឲ្យរស់សទ្ធាក្នុងសាសនារបស់ខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ពួកកុម្មុយនិស្តយល់ថា ត្រូវតែផ្លាស់ប្ដូរស្ថានភាពខាងទ្រព្យសម្បត្តិ ដែលបះពាល់ដល់ជីវភាពនៃបុគ្គលនោះចេញជាការចាំបាច់ ។ គឺក្នុងគំនិតហើយ បានជាក្នុងកិច្ចចាត់ការ ប្រឆាំងចំពោះព្រះពុទ្ធសាសនានោះ ពួកកុម្មុយនិស្តបានប្រើនយោបាយវាយប្រហារ ដោយសំអាងថាជា « បដិរូបទិដី » ។

ពួកកុម្មុយនិស្ត បានចាត់ទុកការគោរពព្រះពុទ្ធសាសនាថាជា « ការប្រតិបត្តិតាមវត្ថុបំណងនៃលទ្ធិនាយទុន » ហើយពុទ្ធសាសនិកជនជា « បុគ្គលមានវណ្ណៈដែលត្រូវតែសង្កត់សង្កិន » ហើយបានចាត់ទុក « បដិរូបទិដី » ថាជាគ្រោងការណ៍សំខាន់មួយរបស់ខ្លួនសំរាប់ធ្វើឲ្យអស់ទៅនូវ « គំនិតសេរីសសេលំរាបដិកិរិយារបស់លទ្ធិនាយទុន» ។ បដិរូបទិដីនេះ ជាភស្តុតាងមួយដែលពុំអាចប្រកែកបាន នៃនយោបាយវាយប្រហារព្រះពុទ្ធសាសនានេះឯង ។

ក- រឹបយកសម្បត្តិព្រះសង្ឃនៃវត្ត និង អង្គការសាសនា

តាមពិតទ្រព្យធន ជាប្រភពនៃការចំរើនរុងរឿងរបស់សាសនានីមួយ ៗ ។ ការរឹបអូសទ្រព្យធននៃព្រះពុទ្ធសាសនានោះ

www.budinst.gov.kh www.elibraryofcambodia.org

ប្រទេសចិន បានត្រូវធ្វើឡើងដោយកម្រៃ ដែលបានមកពីថ្លៃឈ្នួលទ្រព្យសម្បត្តិរបស់វត្តដែលច្រើនតែទីដីក្នុងជនបទ ដែលពុទ្ធសាសនិកជនមានសទ្ធាវេរប្រគេនដល់សង្ឃ កម្រៃទាំងនេះបានត្រូវយកមកប្រើជនប្រាក់ចំណាយ សំរាប់និងគណៈសង្ឃ ព្រមទាំងធ្វើជាមុខចំណាយសំរាប់ចិញ្ចឹមភិក្ខុភិក្ខុនី និងនាងជី ដែលនៅក្នុងវត្តនេះផង ។ បើដូច្នេះគេរឹបយកទ្រព្យសម្បត្តិរបស់វត្តនោះ ដើម្បីទុកឲ្យព្រះពុទ្ធសាសនាមានតទៅទៀត ឬដើម្បីបំផ្លាញចោល ?

ក្នុងការអនុវត្តន៍គ្រោងការណ៍បដិរូបទីដីនេះ គេបានចាប់ផ្ដើមមុនដំបូងចំពោះសាសនា គឺរឹបយកទ្រព្យសព្បត្តិរបស់វត្ត ។ តាមពិតតាំងពីខែកញ្ញា គ.ស. ១៩៤៧ (ព.ស.២៤៩០) ជាដើមមក គឺក្នុងពេលដែលចាប់ផ្ដើមអនុវត្តន៍ «គ្រោងការណ៍ទូទៅនៃបញ្ញត្តិស្ដីពីកម្សេត្រកម្ម » ពួកកុម្មុយនិស្តបានលក្ខខ័ណ្ឌ តម្រូវឲ្យលុបបាត់ចោល នូវកម្មសិទ្ធិទីដីស្មសានបុព្វបុរសរបស់វត្ត របស់សាសនាផ្សេងៗ របស់សាលារៀន និងរបស់អង្គការផ្សេងៗ ។

ក្នុងថ្ងៃទី ១៣ មករា ១៩៥០ ( ព.ស២៤៩៣ )រដ្ឋាភិបាល

www.budinst.gov.kh www.elibraryofcambodia.org

បានប្រកាសបទបញ្ជាមួយ ស្តីពីការចែកទីដី ដើម្បីកែទម្រង់កសិកម្មក្នុងជនបទ ដែលនៅក្នុងខេត្តទេសបាល ក្នុងបរិវេណផ្សេង ៗ ដែលបានទទួលការលើកលែង ។ បទបញ្ជានេះ បានពោលជាពិសេសអំពីការរឹបយកទីដីរបស់វត្តសាសនាអ៊ីស្លាម និងវត្តព្រះពុទ្ធសាសនា ហើយបានកំណត់ទុកថា « ក្នុងកិច្ចប្រតិបត្តិការណ៍ លើទីវត្តសាសនាអ៊ីស្លាម របស់សាសនាឡាមៈនិងរបស់វត្តគ្រិស្តនោះ បញ្ហាទាក់ទងចំពោះការរាប់អានសាសនា ត្រូវចាត់ការដោយឡែក ហើយអ្នកដែលរាប់អានសាសនាទាំងនេះ ត្រូវបានទទួលពាក្យអធិប្បាយពន្យល់យ៉ាងល្អិតល្អន់ » ។

លក្ខខណ្ឌដែលផ្លូវការបានកំណត់ ឲ្យយកដីទីវត្តអារាមនោះ មានក្នុងមាត្រា៣នៃបញ្ញត្តិបដិរូបកែទម្រង់កសិកម្ម ដែលចែងថា " ទីដីជនបទដែលជារបស់ស្មសានបុព្វបុរស របស់វត្តអារាមនៃសាសនាផ្សេង ៗ របស់សាលារៀន និងរបស់អង្គការផ្សេង ៗ និងទីដីរបស់អង្គការសាធារណៈ នឹងត្រូវប្រគល់ឲ្យវិញ ក្នុងករណីបានប្រតិបត្តិទូវលក្ខខ័ណ្ឌតាមអត្រានេះ » ។ ដែលគេចែងនៅក្នុងច្បាប់ថា នឹងប្រគល់ឲ្យវិញនេះ គឺគ្រាន់តែជាលេសសម្រាប់បោកប្រាសតែប៉ុណ្ណោះ គ្មានឃើញ

www.budinst.gov.kh www.elibraryofcambodia.org

ប្រគល់ទីដី ដែលគេរឹបអូសយកនោះ ទៅឲ្យវត្តឬអង្គការ ណាវិញ សោះទេ ។

រួមសេចក្ដីទៅ ពួកកុម្មុយនិស្តចិន បានរឹបយកសម្បត្តិទីដី របស់វត្តអារាមនៃព្រះពុទ្ធសាសនា និងសាសនាដទៃទៀតរះរស់លើង ស្ទើរតែទីកន្លែងដែលជាវត្តឡាមះ ក៏ពុំបានលើកលែងសោះទេ ។ បទបញ្ញត្តិនេះ បានត្រូវដាក់ឲ្យអនុវត្ត មកទល់នឹងពេលដែលកុម្មុយ-និស្តចិនខំប្រឹងធ្វើ " នយោបាយដណ្ដើមយកទីបេតបានដោយស្ងប់ "

គឺដោយមកពីចង់យកទីបេតនេះហើយ បានជាក្នុងពេល នោះ អ្នកកាន់អំណាចប្រទេសចិនភាគពាយ័ព្យ បានប្រកាសជាផ្លូវការ ថា " ត្រូវលើកលែងការមិនប្រគល់ឲ្យវិញ ហើយកុំចែកចាយទីដីនៃវត្ត សាសនាឡាមះ " ប៉ុន្តែវិធានការណ៍នេះ គ្រាន់តែជាកិច្ចឃោសនា ដើម្បី ឲ្យសម្រេចវត្ថុបំណងនៃនយោបាយលេបទឹកដីតែប៉ុណ្ណោះ ។

## ១ - បន្ទោកបង្ខំនះភិក្ខុ ភិក្ខុនីនៅក្នុងសង្គម

ពួកកុម្មុយនិស្ត ពុំបានគ្រាន់តែរឹបយកទីដី និងវត្តអារាម ប៉ុណ្ណោះទេ ក្នុងពេលជាមួយគ្នានោះ ក៏បានចាប់ផ្ដើមកំទាស់មិនឲ្យ ភិក្ខុភិក្ខុនី និងនាងជី មានផ្លូវចិញ្ចឹមជីវិតព្រមទាំងចាត់វិធានការណ៍ផ្សេង ។

ដើម្បីផ្លាស់ឋានៈបព្វជិតទាំងនេះក្នុងសង្គមទៀតផង ។

ដំណាក់ការដំបូង នៃបដិវត្តទីដី គឺការបែងចែកឋានៈរបស់បុគ្គលនៃវណ្ណៈផ្សេង ៗតាម " មតិស្តីពីការបែងចែកឋានៈរបស់បុគ្គលវណ្ណៈផ្សេង ៗ ក្នុងជនបទ „ ដែលគណៈកម្មាធិការអនុវត្តនៃរដ្ឋាភិបាលកណ្តាលរបស់ប្រជាជនបានដាក់ឲ្យប្រើ កាលពីថ្ងៃទី ៤ ខែ សីហា គ.ស. ១៩៤០ ( ព.ស.២៤៩៣ ) ហើយបានកំណត់ឋានៈរបស់ភិក្ខុ ភិក្ខុនីនិងនាងជីទុកដូចតទៅ :

« ប្រជាជន ក្នុងរយៈពេល ៣ ឆ្នាំ មុនពេលដែលបានទទួលការរំដោះ ដែលបានទទួលចំណូលយ៉ាងច្រើន ពីអាជីវកម្មខាងសាសនា ហើយមានជំនឿខាងហោតគ្រោះ ដូចអ្នកបួសភិក្ខុ ភិក្ខុនី បព្វជិត និងឧបាសក នៃតៅយិន អ្នកទាយជោគជតា ហោរា និងអ្នកវិសេសជាដើម ត្រូវរាប់បញ្ចូលទៅក្នុងវណ្ណៈ នៃ « អ្នកចេះប្រតិបត្តិការខាងសាសនា និងអ្នកកាន់ជោគគ្រោះ » ។

នេះគឺភស្តុតាងមួយ ដែលបញ្ជាក់ឲ្យឃើញច្បាស់ថា ពួកកុម្មុយនិស្តផ្តល់នូវកិច្ចការពារ និងឧបត្ថម្ភព្រះពុទ្ធសាសនាដូចជាគេអួតអាង

www.budinst.gov.kh www.elibraryofcambodia.org

មែនឬទេ ?

ដែលពួកកុម្មុយនិស្តចាត់ទុកភិក្ខុ- ភិក្ខុនីក្នុងព្រះពុទ្ធសាសនាទៅក្នុងជំពូកហោរា និងគ្រូទាយជោគជតានេះ ដើម្បីធ្វើឲ្យការគោរពបូជាដែលពុទ្ធសាសនិកជនមានចំពោះភិក្ខុ ភិក្ខុនីអស់តម្លៃទៅហើយ ការទាក់ទងសាសនារវាងឧបាសកឧបាសិកា និងព្រះសង្ឃ ក៏នឹងសាបសូន្យទៅផងដែរ ។ គឺដោយការបន្ថោកបន្ទាបឋានៈនៃភិក្ខុ ភិក្ខុនីដូច្នោះហើយ ដែលជានុកាសអាចឲ្យចាត់ចែងនយោបាយ បំផ្លាញបានដោយងាយ ។

## គ—ចោទភិក្ខុ ភិក្ខុនីថា ធ្វើអាជីវកម្មខាងការកាន់ជោគនិងជាបញ្ញើក្អែក :

នៅក្នុងបទបញ្ញត្តិស្តីពីការបែងចែកវណ្ណៈមនុស្សនោះ ពួកកុម្មុយនិស្តបានអធិប្បាយថា « អាជីវកម្មដែលប្រើវិធីល្បួងបោកប្រាសផ្សេង ៗ ដើម្បីឲ្យប្រជាជនរាប់អានជោគ ហើយបោកប្រាសយកសម្បត្តិទ្រព្យរបស់ប្រជាជនទូទៅ » ។

នៅក្នុងអត្ថាធិប្បាយដដែលនោះ ពួកកុម្មុយនិស្ត បានគិះ

www.budinst.gov.kh www.elibraryofcambodia.org

ជេៀលព្រះសង្ឃថា « ក្នុងអតីត ពួកភិក្ខុ-ភិក្ខុនីបានផ្ដេកខ្លួន ពុំធ្វើការងារអ្វីឲ្យកើតជាប្រយោជន៍សោះ មកយូរហើយ ដោយប្រកបតែអាជីវកម្ម ខាងការផ្សងជោគ ។ ដូច្នេះ ភិក្ខុ ភិក្ខុនី គឺជា «បពោក្អែក» ។

ដោយកុម្មុយនិស្តបានចាត់ទុកព្រះសង្ឃថា ‘ក្អែក "ដែលចាំតែជញ្ជក់យកឈាមជីវជាតិពីដើមឈើ ដែលខ្លួនអ ... ាជន ចិន "នោះ ទើបពួកនេះខំប្រឹងប្រើគ្រប់វិធី គ្រប់មធ្យោបាយ ដើម្បីបំផ្លាញបញ្ចើក្អែកនេះឲ្យបាត់ពូជធារពីប្រទេសចិន ។

## ឃ–ចោទថា ភិក្ខុ ភិក្ខុនី ជាអ្នកធ្វើស្រែលើខ្លួនរាស្ត្រ :

« មតិស្តីពីការបែងចែកឋានៈបុគ្គលក្នុងជនបទ »

បានអធិប្បាយថា :

«កិច្ចចាត់ការចំពោះកម្មសិទ្ធិទីដី របស់អង្គការសាធារណៈ »

នោះបានន័យថា កិច្ចចាត់ការចំពោះកម្មសិទ្ធិទីដីនិងទ្រព្យសម្បត្តិដទៃ ។ ដែលជារបស់ស្មសានបុព្វបុរសរបស់វត្តអារាម របស់សមោសរ និងរបស់សមាគមគ្រប់បែបព្រោះពិធីការនៃកម្មសិទ្ធិទាំងនេះ នឹងទៅជាការធ្វើស្រែ

www.budinst.gov.kh www.elibraryofcambodia.org

លើខ្លួនមនុស្សក្នុងជនបទ នៃលទ្ធិនាយទុន យ៉ាងពិតប្រាកដណាស់ ។ កិច្ចប្រតិបត្តិការចំពោះអង្គការផ្សេង ៗ ដូចពោលមកនេះ គួរជាចំណែកមួយនៃការកំណត់ឋានៈនៃអ្នកដែលទាក់ទងនឹងកិច្ចការនេះ » ។

## ខ. ចោទភិក្ខុជាប្រធាន ឬ ចៅអធិការជានាយទុនម្ចាស់ទីដីនិងទ្រព្យសម្បត្តិ

តាមសេចក្តីសំគាល់របស់កុម្មុយនិស្ត ភិក្ខុដែលជាប្រធានឬចៅអធិការ គឺជាម្ចាស់របស់ទីដី នៃលទ្ធិនាយទុន ដែលអាស្រ័យឈាមនិងញើសរបស់ប្រជាជនធ្វើការផ្គត់ផ្គង់មកជាគ្រឿងចិញ្ចឹមជីវិត ដោយមិនត្រូវធ្វើការងារអ្វីដោយខ្លួនឯង ប៉ុន្តែ មានជីវិតរស់នៅបាន ដោយផលនៃការសង្កត់សង្កិន បំភិតបំភ័យ និងកំហែង ។ វិធីនេះ ពួកកុម្មុយនិស្តបានជ្រើសរើសអនុវត្តទៅលើភិក្ខុចាស់និងចៅអធិការ ជាពិសេស គឺកំចាត់ភិក្ខុដែលមានឋានៈជាប្រធានចេញពីភិក្ខុដទៃទៀត ដែលនៅក្នុងប្រភេទបញ្ញើក្អែក ដើម្បីបង្កើតឲ្យមានការមិនពេញចិត្តគ្នា និងការបែកសាមគ្គីគ្នាក្នុងចំណោមពុទ្ធបរិស័ទ ហើយជាពិសេស ដើម្បីឲ្យភិក្ខុដែលមានឋានៈជាប្រធាននោះសាបសូន្យសេចក្តីគោរពរាប់អានពីពុទ្ធបរិស័ទ, វិធានការណ៍

www.budinst.gov.kh www.elibraryofcambodia.org

បំផ្លេចបំផ្លាញ ដែលត្រូវធ្វើឡើងនៅតាមបដិរូបទីដីនេះ បានធ្វើឲ្យចៅអធិការនិងប្រធាន នៃវត្តអារាមទាំងឡាយ បានជួបប្រទះនឹងជតាកម្មយ៉ាងរន្ធត់ ។ ដោយភិក្ខុមានអាយុច្រើន មានចំណេះវិជ្ជាខ្ពស់ និងជំនាញការច្រើន តែងមានឥទ្ធិពលទៅក្នុងចំណោមពុទ្ធបរិស័ទ នោះទើបព្រះសង្ឃទាំងនេះបានធ្លាក់ទៅជាទីដៅដំបូង ដែលពួកកុម្មុយនិស្តត្រូវការបំផ្លាញចោល ។ ដូច្នេះ ជតាកម្មនៃចៅអធិការនិងប្រធាននៃវត្តទាំង-ឡាយ បានទទួលផលអាក្រក់ ពីនយោបាយវាយប្រហាររបស់កុម្មុយនិស្តនេះ ដូចគ្នានឹង “ ម្ចាស់ទីដីនៃលទ្ធិនាយទុន ” ដែរ ។

ការដែលពួកកុម្មុយនិស្តចោទថា ចៅអធិការ ឬប្រធាន ជានាយទុនម្ចាស់ទីដីនិងទ្រព្យវត្តនោះ គឺជាលេសមួយ ហៅមហាអយុត្តិធម៌ ព្រោះតាមព្រះវិន័យ ទីដីនិងទ្រព្យវត្តនេះ ជារបស់សង្ឃ គ្មានអ្នកណាមួយជាម្ចាស់ទេ ដែលដូចគ្នានឹងទ្រព្យសម្បត្តិសាធារណៈខាងផ្លូវលោកដូច្នោះ ។

## ៣—នយោបាយ បរិរូប

ក្នុងការរឹបយកទ្រព្យសម្បត្តិ និងទីដីទាំងអស់ របស់វត្តអារាមនេះ ពួកកុម្មុយនិស្ត ក្រៅពីយករបស់ទាំងនោះទៅធ្វើជារបស់ខ្លួនឯង

www.budinst.gov.kh www.elibraryofcambodia.org

ចេញ នៅមានវត្ថុបំណងគួរឲ្យសង្វេគច្រើនប្រការទៀត ។ ពួកកុម្មុយ-និស្តបានប្រាប់ថា « ត្រូវការដោះរឹមពីអ្នកដែលរាប់អានព្រះពុទ្ធសាសនា ឲ្យផុតពីពន្ធនាគារ នៃសេដ្ឋកិច្ចបែបលទ្ធិនាយទុន » ប៉ុន្តែ វត្ថុបំណង ពិតប្រាកដនៃប្រតិបត្តិការដូច្នេះ គឺដើម្បីឲ្យព្រះសង្ឃសឹក ព្រោះកាល ណាបើគ្មានផ្លូវនឹងចិញ្ចឹមជីវិតរបស់ខ្លួនទេ គណៈសង្ឃ នឹងត្រូវផ្លាស់ ដំណើរជីវភាពរបស់ខ្លួនជាថ្មី ។ ភិក្ខុ និងភិក្ខុនី បានត្រូវពួកកុម្មុយ និស្តបង្គាប់ឲ្យឈប់ឆាន់អាហារអន្លក់ និងឲ្យឈប់សូត្រមន្តការនោ ដែលជាការហាមឃាត់ ដើម្បីធ្វើឲ្យព្រះពុទ្ធសាសនាសាបសូន្យអស់ ទៅ ក្នុងទីបំផុត ។ ក្នុងការធ្វើនយោបាយចោមវាយប្រហារដោយត្រង់ នេះ ពួកកុម្មុយនិស្តបាននាំយក « នយោបាយបដិរូបព្រះពុទ្ធសាសនា » មកប្រើភ្លាម ។

នយោបាយដែលហៅថា « បដិរូបព្រះពុទ្ធសាសនា » នោះ តាមពិត បានត្រូវធ្វើឡើង ដើម្បីបំផ្លាញព្រះពុទ្ធសាសនាពិតប្រាកដ ។ នយោបាយបដិរូបនេះ មាន ៣ បែបផ្សេងៗពីគ្នា ហើយមានការអនុ-វត្តន៍ជា ២ ដំណាក់ ។

ចាប់តាំងពីផ្តើមធ្វើ " បដិរូបក្សេត្រកម្ម " រហូតដល់ចុង

www.budinst.gov.kh www.elibraryofcambodia.org

បំផុតនៃជំហានដំបូងនេះ ទ្រព្យសម្បត្តិ និងទីដីទាំងអស់របស់វត្តអារាម បានត្រូវកុម្មុយនិស្តរឹបយកអស់ ។ ភិក្ខុ ភិក្ខុនី ដោយគ្មានផ្លូវនឹងរស់នៅកើត ក៏ត្រូវតែមិនសប្បាយកាយ មិនសប្បាយចិត្ត ជាធម្មតា ក្នុងពេលដែលឱកាសហុចឲ្យនេះ ពួកកុម្មុយនិស្ត ក៏ចាប់ផ្តើមញុះញង់ដឹកនាំភិក្ខុ ភិក្ខុនី ឲ្យចូលរួមក្នុងវិធានការណ៍ « សិក្សាអប់រំ » ។

ពួកកុម្មុយនិស្តបានប្រកាសយ៉ាងឧឡារិកថា « វិធានការណ៍នេះ ជាកិច្ចទំនុកបម្រុងសេរីភាពក្នុងការរាប់អានសាសនា ព្រមទាំងជួយពុទ្ធសាសនិកជន ឲ្យដោះស្រាយបញ្ហាលំបាករបស់ខ្លួន ខាងផ្នែកអាជីវកម្ម » ហើយក្លែងធ្វើជានិយាយថា ខ្លួនមានការគិតគូរដល់ពុទ្ធសាសនិកជនយ៉ាងខ្លាំង ។

ដើម្បីលួងចិត្ត ភិក្ខុ ភិក្ខុនី ដែលកំពុងតែក្តៅក្រហាយយ៉ាងខ្លាំងនោះ ពួកកុម្មុយនិស្តបានប្តេជ្ញាថា “ កាលបើរំដោះទីដីឲ្យផុត ពីអំណាចនៃលទ្ធិនាយទុនហើយ មុខចំណាយខ្លះនៃវត្តអារាម នឹងបានទទួលទុនពីពុទ្ធសាសនិកជនបរិច្ចាគ ហើយចំណែកខ្លះទៀត នឹងបានទទួលពីការបរិច្ចាគនៃរដ្ឋាភិបាល ប៉ុន្តែតាមពិត គេគ្មានឃើញពួកកុម្មុយនិស្តចិនអនុវត្ត តាមពាក្យប្តេជ្ញារបស់ខ្លួនទាល់តែសោះ ។

www.budinst.gov.kh www.elibraryofcambodia.org

កាសែតឈ្មោះ " តាគុងប៉ាវក្រុងហុងកុង " បានផ្សាយអត្ថបទមួយ បញ្ជាក់អំពីស្ថានការណ៍ពិតប្រាកដ នៅប្រទេសចិនដែនដីគោក ដូចតទៅ :

" បន្ទាប់ពីធ្វើការរំដោះរួច អ្វីទាំងអស់គ្រប់បែបគ្រប់យ៉ាងបានត្រូវផ្លាស់ប្ដូរទាំងអស់ ជាពិសេស មានការផ្លាស់ប្ដូរយ៉ាងខ្លាំងនៅក្នុងផ្នែកសេដ្ឋកិច្ច នៃវត្តអារាមនៅហាន់គៅ ។

ក្នុងអតីតកាល កម្មសិទ្ធិទីដីនិងទ្រព្យសម្បត្តិរបស់វត្ត គ្មាននរណាមួយហ៊ានល្មើសបានទេ ប៉ុន្តែក្នុងពេលនេះ អ្នកជនបទបានជ្រាបក្នុងរឿងនយោបាយច្រើនឡើង ហើយភិក្ខុនិងភិក្ខុនី ដែលមានជីវិតរស់នៅបាន ដោយចំណូលដែលបានមកពីថ្លៃឈ្នួលទីដី និងទ្រព្យសម្បត្តិរបស់វត្តនោះ បានត្រូវគេចាត់បញ្ចូលទៅក្នុងវណ្ណៈម្ចាស់ទីដីទៅហើយ ។ ក្នុងឆ្នាំនេះ អ្នករាប់អានព្រះពុទ្ធសាសនា ដែលធ្វើដំណើរមកកាន់ក្រុងហាន់គៅនោះ មានចំនួនតិចណាស់ ។ ក្នុងចំណោមប្រជាជនដែលធ្វើដំណើរមកកាន់ហាន់គៅ នៅក្នុងអតីតកាលនោះ មានភាគច្រើនជាម្ចាស់ទីដី និងអ្នកជនបទដែលស្ដុកស្ដម្ភ ។ ក្នុងពេលនេះពួកទេសចរប្រភេទនេះ កំពុងតែថយចំនួនទៅជាលំដាប់ ។ ដូច្នេះ

www.budinst.gov.kh www.elibraryofcambodia.org

ដោយផលដែលទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច ក្នុងពេលនេះ ការទំនុកបម្រុងវត្តអារាម បានចោទជាបញ្ហាមួយយ៉ាងលំបាក ដែលត្រូវតែមានការធ្វើផលិតផល សំរាប់ជាមធ្យោបាយដោះស្រាយ" ។

យើងបានដឹងយ៉ាងច្បាស់ អំពីជតាកម្មដ៏សែនវេទនា ដែលភិក្ខុ-ភិក្ខុនី ចំនួនរាប់ម៉ឺន បានជួបប្រទះក្នុងប្រទេសចិន ចាប់តាំងពីកុម្មុយនិស្តបានរឹបយកទ្រព្យសម្បត្តិរបស់វត្តជាដើមមក ។ ភិក្ខុ និងភិក្ខុនី ពុំមែនគ្រាន់តែត្រូវបែរទៅធ្វើការងារបង្កើតផលិតផលប៉ុណ្ណោះទេ គឺត្រូវចូលរួមក្នុងការសិក្សាអប់រំទៀតផង ។ វិធានការណ៍នេះ ជាដំណាក់ការត្រៀមខ្លួនសម្រាប់ដំណាក់ការតទៅ គឺការបង្គាប់ឲ្យភិក្ខុនិងភិក្ខុនីលាចាកសិក្ខាបទ ។

« កាសិក្សាអប់រំ » នេះមានន័យម្យ៉ាងទៀតគឺ « ការលាងខួរក្បាល » ដែលជាវិធានការណ៍សំខាន់បំផុតនៃនយោបាយកុម្មុយនិស្តចិន សម្រាប់បំផ្លាញព្រះពុទ្ធសាសនាឲ្យវិនាសទៅ ដូចគ្នានឹងគេបានធ្វើទៅលើសាសនាដទៃទៀត ជាប្រាកដ ។

ដោយបញ្ហានេះជារឿងធំធៀ កុម្មុយនិស្តចិន ក៏ងាកទៅប្រើការលាងខួរក្បាល ដើម្បីបំបាត់ចោលនូវសេចក្តីគិតឃើញ ខាង

www.budinst.gov.kh www.elibraryofcambodia.org

ផ្នែកព្រះពុទ្ធសាសនាគ្រប់យ៉ាង ឲ្យផុតរលត់ទៅ ប្រយោជន៍នឹងនាំយកលទ្ធិម៉ាកឡេនីន មកប្រៀនប្រដៅបញ្ចូលទៅក្នុងខួរក្បាល ជំនួសវិញ ដោយមានវត្ថុបំណងនឹងបំផ្លាញចោលនូវសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនាឲ្យអស់ក្នុងទីបំផុត ។

ប៉ុន្តែពួកកុម្មុយនិស្ត ដោយយល់ឃើញថា គ្រាន់តែមានការសិក្សាអប់រំប៉ុណ្ណោះ ពុំបានលទ្ធផលតាមសេចក្ដីត្រូវការទេ ក៏ងាកទៅប្រើវិធីផ្សេងៗទៀត ដោយបង្ខាប់ឲ្យភិក្ខុ-ភិក្ខុនី ចូលរួមធ្វើផលិតផលនិងធ្វើកិច្ចការធ្ងន់ ជំនួសការនៅដោយស្ងប់ស្ងៀមដែលធ្លាប់មានមកពីមុន ។ ពួកកុម្មុយនិស្ត បានចាត់ការវាយប្រហារជាពីរផ្នែក ដើម្បីបង្ខាប់ឲ្យភិក្ខុនិងនាងជី ឈប់រាប់អានសាសនារបស់ខ្លួន ។

កាសែត តាគុងប៉ាវ នៅហុងកុង បាននិយាយអំពីការវាយប្រហារនេះថា "ជាការធ្វើឲ្យភិក្ខុ ភិក្ខុនី ចូលប្រតិបត្តិកិច្ចការដាន់ដំបូង តាមប្រពៃណីតាមផ្លូវលោក ។ ការធ្វើដូច្នេះ ពុំមែនបង្ខាប់ឲ្យភិក្ខុនិងភិក្ខុនីសឹកទេ "។

ក្នុងពេលដែលមានបដិរូបកិច្ចការនិងបដិរូបសេចក្ដីគិតនេះ ភិក្ខុ ភិក្ខុនី ទោះជាពេញចិត្តក្ដី មិនពេញចិត្តក្ដី ក៏ត្រូវតែបោះបង់ជីវិតក្នុង

www.budinst.gov.kh www.elibraryofcambodia.org

វត្តហើយត្រឡប់ទៅកាន់ជីវិតផ្លូវលោកវិញ ។ នៅដំណាក់ការនេះ ភិក្ខុ ភិក្ខុនីមានត្រឹមតែឈ្មោះប៉ុណ្ណោះ ។ កាលណាបើ ភិក្ខុនិងភិក្ខុនីអស់ទៅហើយ ការផ្សាយព្រះពុទ្ធសាសនា ក៏ត្រូវអាក់ខាន ហើយនិមិត្តរូបសំខាន់នៃព្រះពុទ្ធសាសនា ក៏ត្រូវសាបសូន្យអស់ទៅផង ។

គួរកត់សំគាល់ថា នយោបាយបដិរូបព្រះពុទ្ធសាសនានេះ ប្រសិនបើពួកកុម្មុយនិស្ត អនុវត្តឲ្យបានសម្រេចលទ្ធផល តាមសេចក្តីត្រូវការរបស់គេហើយ ព្រះពុទ្ធសាសនាក្នុងប្រទេសចិន នឹងនៅសល់ត្រឹមតែសំបកប៉ុណ្ណោះ ទោះបីមានភិក្ខុនិងភិក្ខុនីសល់នៅខ្លះក្តី ក៏បព្វជិតទាំងនេះគ្រាន់តែជាដៃជើងរបស់កុម្មុយនិស្ត ពុំមែនជាអ្នកបម្រើមូលហេតុនៃព្រះពុទ្ធសាសនាសោះទេ ។

## ៤- នយោបាយគ្រួតត្រា

បន្ទាប់ពីមានធ្វើបដិរូបទូទៅមក ព្រះពុទ្ធសាសនាក្នុងប្រទេសចិនក្រហមមានសេចក្តីសំខាន់នៅសល់ត្រឹមតែឈ្មោះប៉ុណ្ណោះ ។ ដោយខ្លាចព្រះពុទ្ធសាសនានឹងរីកចម្រើនឡើងវិញ ពួកកុម្មុយនិស្តក៏ធ្វើនយោបាយមួយបែបទៀតគឺ «នយោបាយដាក់ចំណង» ។ គោលសំខាន់នៃនយោបាយនេះគឺ «សហពន្ធពុទ្ធសាសនា», អង្គការនេះ ត្រូត

ក្រោមអ្នកកាន់ព្រះពុទ្ធសាសនាគ្រប់ផ្នែក ហើយមិនបណ្ដោយឲ្យព្រះពុទ្ធសាសនាមានឱកាសរើខ្លួនឡើងបាន ។ ក្នុងពេលជាមួយគ្នានោះ ពួកកុម្មុយនិស្ត ក៏ប្រើពុទ្ធសាសនិកជន ធ្វើជាឧបករណ៍ សម្រាប់ឃោសនាខាងនយោបាយ ។ ដូច្នេះ ពុទ្ធសាសនិកជននៅប្រទេសចិនប្រជាមានិតបានក្លាយខ្លួនទៅជា អាភរណៈ(គ្រឿងលំអ ) ( décor. médaille ) ថ្មី នៃលទ្ធិប្រជាធិបតេយ្យបែបថ្មីរបស់កុម្មុយនិស្តចិន ។ អត្ថបទដើមដែលសរសេរដោយ ចេនមីនឌូ ជាសមាជិកនៃក្រុមប្រឹក្សានៃប្រជាជនចិន បានចែងថា :

" កិច្ចការក្នុងពេលនេះ និងក្នុងអនាគតនៃពុទ្ធសាសនិកជនគឺរឿងអំពាវនាវឲ្យចាត់តាំង " សហពន្ធសាសនា " ឡើងដែលអាចពោលបានថា

" ពេលនេះ យើងកំពុងឋិតនៅក្នុងយុគ្គថ្មី ។ ដូច្នេះ យើងត្រូវតែបើកភ្នែកបើកត្រចៀកឲ្យធំ ហើយត្រូវយល់ឲ្យច្បាស់ថា ប្រជាធិបតេយ្យថាវត្ថុនិយមនោះ មានគម្ពីរភាព នៃព្រះពុទ្ធសាសនានៅជាមួយផងហើយផ្សាយនូវពុទ្ធវចនៈទាំងឡាយ " ។

" ការងារដែលជួបប្រទះ នឹងពុទ្ធសាសនិកជនក្នុងពេលនេះ មានច្រើនប្រការ ។ យើងសូមឲ្យគ្រប់គ្នាចូលធ្វើការទាំងនេះ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ចូលរួមទំនុកបំរុងបដិរូបឲ្យមាំទាំ ។ ក្នុងកិច្ចបណ្តុះបណ្តាលដែលជាប្រយោជន៍នេះត្រូវមានការបម្រះខ្លួនពីជំនឿ និងពីពាក្យប្រៀនប្រដៅដែលជាបដិកិរិយា ។ ចូរប្រឆាំងនឹងអាមេរិកាំងហើយជួយកូរ៉េ ។ ត្រូវចូលចិត្តឲ្យត្រឹមត្រូវ ចំពោះនិមិត្តរូបនៃព្រះពុទ្ធសាសនានៅទីបេត៍ហើយត្រូវដាស់ពុទ្ធសាសនិកជនក្នុងប្រទេសជប៉ុន ឲ្យបានជ្រួតជ្រាបខាងនយោបាយ ដើម្បីជំទាស់ចំពោះការបង្កើនកម្លាំងសង្គ្រាម ។ ក្នុងករណីនេះ យើងគួរញុះញង់ផ្ចិតផ្ចង់ដើម្បីឲ្យពុទ្ធសាសនិកជនជប៉ុនដឹងស្គាល់នូវនយោបាយថ្មី ហើយរំលំរបបគ្រប់គ្រងដែលជាបដិកិរិយារបស់ជាតិខ្លួន ។

" យើងសូមរួបរួមអង្គការសាសនាទាំងឡាយបញ្ចូលគ្នាដើម្បីធ្វើបដិរូបរួបរួមគ្នា ហើយបង្កើតសាសនាថ្មីឡើងក្នុងគ្រោងការណ៍សាងសង្គមថ្មី ។ ក្នុងគ្រោងការណ៍សាងសង្គមបែបពិសេសនេះ ត្រូវតែមានសាសនាបែបពិសេសដែលចេញមកពីទស្សនៈប្រវត្តិសាស្ត្រ ។ ទោះជាសាសនាណាក៏ដោយ រមែងប្រព្រឹត្តទៅតាមកាលទេសៈ ហើយត្រូវផ្លាស់ប្តូរគ្មានឈប់ឈរ " ។

" អត្ថបទនៃលោក ខេន មីនឌូ ដែលចែងថា យថាវត្ថុ

និយម មានឧត្តមគតិនៃព្រះពុទ្ធសាសនាបញ្ចូលជាមួយផង ហើយមានការប្រែពាក្យប្រដៅនៃព្រះពុទ្ធសាសនាឲ្យឃ្លៀងឃ្លាត ដែលគួរឲ្យស្តាយនេះ បានបញ្ជាក់ឲ្យឃើញថា បានត្រូវគាត់តែងឡើងពីនយោបាយផ្លូវការ របស់កុម្មុយនិស្តចិន ។

តាមពិត ពួកកុម្មុយនិស្ត បើមាននិយាយអំពីគោលព្រះពុទ្ធសាសនានោះ គឺគ្រាន់តែលើកយកមកធ្វើការរិះគន់ ហើយជាពិសេសគ្រាន់តែទាញយកផលប្រយោជន៍ ពីពាក្យប្រដៅរបស់ព្រះពុទ្ធសាសនាទៅឧបត្ថម្ភគ្រោងការណ៍កុម្មុយនិស្ត ស្តីពីការផ្លាស់ប្តូរឧត្តមគតិ និងការពិចារណាដោយខ្លួនឯងតែប៉ុណ្ណោះ ពុំមែននិយាយដើម្បីលើកតម្កើងព្រះពុទ្ធសាសនាទេ ។

អត្ថបទនៃលោក ឌេន-មីនឌូ នេះជាភស្តុតាងមួយបញ្ជាក់ឲ្យឃើញថា ពួកកុម្មុយនិស្តចិនបានផ្លាស់ប្តូរនយោបាយវាយប្រហារ និងនយោបាយបដិវត្ត ទៅជានយោបាយត្រូតត្រា ។

គួរកត់សម្គាល់ថា បន្ទាប់ពីមានការរឹបយកទ្រព្យសម្បត្តិនឹងទីដីវត្តអារាមព្រះពុទ្ធសាសនានោះមក ហើយក្នុងពេលដែលភិក្ខុភិក្ខុនីកំពុងត្រូវគេបង្ខាប់ឲ្យចូលក្នុងគ្រោងការណ៍បដិវត្តការងារ បដិវត្តគំនិត

www.budinst.gov.kh www.elibraryofcambodia.org

នឹងបង្ខំឲ្យសឹកនោះ ផេនមីនជូ បានបោះពុម្ពផ្សាយរឿងរ៉ាវផ្សេង ៗ ដើម្បីឧបត្ថម្ភសង្ឃនយោបាយដែលគ្មានវិន័យ ជាពិសេសឧបត្ថម្ភនយោបាយបង្កើតសហព័ន្ធសាសនានៃប្រទេសចិន ។

ដូចបានជំរាបមកហើយ នៅខាងដើមថា ពុទ្ធសាសនិកជនក្នុងប្រទេសចិន បានទៅមករកគ្នា បានសមាគមនឹងគ្នា តាមអំពើចិត្តជាដរាបមកដោយពុំបានឋិតនៅក្រោមឱវាទនៃអង្គការណាមួយទេ ។

ពួកកុម្មុយនិស្តបានយល់ឃើញថា ការប្រព្រឹត្តិដូច្នេះ ជាគ្រឿងសម្គាល់នៃសេរីភាព ហើយលំបាកដល់ការត្រួតត្រានៃក្រសួងមានសមត្ថកិច្ច ។ ដូច្នេះហើយ បានជាពួកកុម្មុយនិស្តបានបំផ្លាញចោលនូវសេរីភាពនៃពុទ្ធសាសនិកជននេះ ដោយតម្រូវឲ្យព្រះពុទ្ធសាសនានិងសាសនកិច្ច ឋិតនៅក្រោមការត្រួតត្រា និងការណែនាំរបស់ខ្លួនដូចគ្នានឹងវិធានការណ៍ ដែលគេបានអនុវត្តទៅលើក្រុមជននៃសាសនាដទៃទៀតដែរ ព្រមទាំងបង្កើត "សហព័ន្ធសាសនា" ធ្វើជាឧបករណ៍សម្រាប់បង្គាប់បញ្ជានិងត្រួតត្រាព្រះពុទ្ធសាសនាអេះផង ។

វត្ថុបំណងនៃនយោបាយត្រួតត្រានេះ មានចែងយ៉ាងច្បាស់នៅក្នុងពាក្យប្រារព្ធនៃសហព័ន្ធពុទ្ធសាសនា ដែលយើងសូម

www.budinst.gov.kh www.elibraryofcambodia.org

លើកយកមកជម្រាបជូនដូចតទៅ :

" យើងទំនុកបំរុងឲ្យចាត់តាំង " សហពន្ធពុទ្ធសាសនានៃប្រទេសចិន " ឡើង ដើម្បីឲ្យពួកអ្នកកាន់អានព្រះពុទ្ធសាសនាមានសាមគ្គីគ្នា ដោយមានរដ្ឋាភិបាលប្រជាជនជាអ្នកដឹកនាំ ដើម្បីឲ្យសម្តែងស្វាមីភក្តិចំពោះប្រទេសជាតិ ដែលជាស្រុកជូនតាយើង និងដើម្បីឲ្យរក្សាសន្តិសុខនៃពិភពលោក " ។

ចំពោះពាក្យសាមគ្គីដែលគេលើកមកអាងនេះ បើពិនិត្យឲ្យហ្មត់ចត់នៅក្នុងគ្រោងការណ៍របស់កុម្មុយនិស្តចិនទៅ គេពុំអាចនឹងសម្គាល់សេចក្តីថាឲ្យរួបរួមគ្នានោះទេ ព្រោះនៅគ្រប់តែគ្រោងការណ៍គេបង្កើតឲ្យមានមិត្តនិងសត្រូវ សម្រាប់ធ្វើការប្រឆាំងគ្នាជានិច្ច ដូចជាបង្កើតវណ្ណៈអធន ឲ្យប្រឆាំងនិងវណ្ណៈនាយទុន បង្កើតសហពន្ធពុទ្ធសាសនា សម្រាប់ប្រឆាំងនឹងពុទ្ធសាសនិកជនដែលពុំចូលរួមធ្វើជាសមាជិកនៃសហពន្ធពុទ្ធសាសនា ដោយចាត់ទុកអ្នកពុំចូលរួម ថាជាសត្រូវ ។ រួបសេចក្តីទៅ គឺគេបង្កើតអ្វី ៗ ទាំងអស់នៅលើទ្រឹស្តី " បំបែកដើម្បីត្រួតត្រា " ។

ពាក្យប្រារព្ធដែលលើកមកអាងខាងលើនេះ បានបញ្ជាក់

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យឃើញច្បាស់ថា "សហពន្ធពុទ្ធសាសនា" គឺជាគ្រឿងឧបករណ៍នៃគណៈបក្សកុម្មុយនិស្តចិន សំរាប់ធ្វើសកម្មភាពបំផ្លាញព្រះពុទ្ធសាសនាពិតប្រាកដ ពុំមែនតែនៅក្នុងប្រទេសចិនប៉ុណ្ណោះទេ គឺនៅក្រៅប្រទេសទៀតផង ព្រោះក្នុងគ្រោងការណ៍បដិវត្តសាសនានៃកុម្មុយនិស្តចិននោះ គឺបង្កើតឲ្យមានពុទ្ធសាសនាកុម្មុយនិស្តចិនមួយ ជាគូគ្នានឹងលទ្ធិគោនិយម សម្រាប់បំផ្លាញចោលនូវពុទ្ធសាសនាដែលជាឥទ្ធិពលនៃវប្បធម៌ឥណ្ឌា ( Culture indienne ) ឲ្យសាបសូន្យទៅ ហើយយកពុទ្ធសាសនាកុម្មុយនិស្តចិនមកជំនួសវិញ ។

សហពន្ធពុទ្ធសាសនាកុម្មុយចិននេះ បានធ្វើសកម្មភាពផ្សាយពុទ្ធសាសនាក្រខ្សែ និងលទ្ធិកុម្មុយនិស្តនេះនៅប្រទេសជារណបរបស់ខ្លួនខ្លះហើយ ហើយកំពុងតែប្រើស្នៀតធ្វើបដិវត្តព្រះពុទ្ធសាសនាដូចគ្នា និងគ្រោងការណ៍បដិវត្តវប្បធម៌របស់ម៉ៅសេទុងដែរ ( Révolution culturelle de Mao ) ។

គ្រោងការណ៍បំបែកសាមគ្គីនៃពុទ្ធសាសនិកជន ដែលពួកកុម្មុយនិស្តបានចាត់ចែងឡើងនេះ មានចែងនៅក្នុងសេចក្ដីថ្លែងនៃលោកលី -វ៉េ- ហាន់ រដ្ឋមន្ត្រីក្រសួងរណសិរ្សរួមនៃទីស្នាក់ការក្រុងរបស់

គណៈបក្សកុម្មុយនិស្តចិនថា ៖

ក្នុងរយៈពេល៣ឆ្នាំកន្លងមកហើយ អង្គការសំខាន់ ៗ នៃប្រជាជនច្រើនយ៉ាង ទូទាំងប្រទេសបានទទួលសេចក្តីសំរេចកិច្ចការផ្សេង ៗ យ៉ាងគាប់ប្រសើរ ។ អ្នករាប់អានព្រះពុទ្ធសាសនាក្នុងខេត្តនានា បានចូលរួបរួមក្នុងកិច្ចការទាំងនេះ ។ ក្នុងអង្គការព្រះពុទ្ធសាសនាបានត្រូវកំណត់លក្ខខណ្ឌរវាងមិត្តនិងសត្រូវឡើង ហើយវិធានការណ៍នេះជាគ្រឿងកត់សំគាល់មួយយ៉ាងប្រសើរបំផុត ។ ក្នុងឱកាសជាពិសេសនៃការចាត់តាំងសហពន្ធសាសនា នៃប្រទេសចិនឡើងនេះយើងមានសង្ឃឹមថា ពួកអ្នករាប់អានព្រះពុទ្ធសាសនា អ្នកស្នេហាជាតិគង់នឹងរួបរួមគ្នា ហើយខំប្រឹងបែងចែករវាងសត្រូវនិងមិត្តពទៅនឹងរួមដៃគ្នាយ៉ាងមុតមាំជាមួយប្រជាករទាំងអស់ របស់ជាតិក្នុងការចាត់តាំងរណសិរ្សរួមឡើង ។

ការដែលពួកកុម្មុយនិស្ត បង្កើតអង្គការព្រះពុទ្ធសាសនាសំរាប់ធ្វើការបំបែកបំបាក់ ព្រមទាំងបង្កើតរណសិរ្សរួម នៅក្នុងផ្ទៃនៃព្រះពុទ្ធសាសនា សំរាប់ធ្វើការប្រឆាំងតទល់នឹងពួកជនដែលគេចាត់ទុកជាអមិត្តនេះ ផ្ទុយពីគោលការនៃព្រះពុទ្ធសាសនាទាំងស្រុងហើយ

វិធានការបែបនេះ ពុំមែនជាការឧបត្ថម្ភព្រះពុទ្ធសាសនាទេ ផ្ទុយទៅវិញ គឺជាគ្រោងការណ៍បំផ្លាញព្រះពុទ្ធសាសនា ដែលមានពិសកំណាច ជាបំផុត ។

ក្នុងករណីនេះ គេអាចឃើញច្បាស់ណាស់ថា មហិច្ឆិតា នៃកុម្មុយនិស្តចិន ពុំមែនគ្រាន់តែចង់ផណ្តើមធ្វើជាមេនៃលទ្ធិកុម្មុយ-និស្តប៉ុណ្ណោះទេ គឺថែមទាំងចង់ធ្វើជាមេនៃលទ្ធិព្រះពុទ្ធសាសនា ទៀតផង ។ ដូច្នេះហើយបានជាសហពន្ធព្រះពុទ្ធសាសនានៃប្រទេស ចិន បានធ្វើសកម្មភាពនៅក្នុងប្រទេសរណប របស់ក្រុងប៉េកាំង ទាំងប៉ុន្មាន ដើម្បីបង្កើតឲ្យមានពុទ្ធិកសមាគមពិភពលោកមួយដោយ ឡែក ដែលមានក្រុងប៉េកាំងជាមេក្លោង បែកចេញពីពុទ្ធិកសមាគម ពិភពលោក ដែលមានរួចមកហើយ ហើយដែលកំពុងតែចាប់ផ្តើម មានការបែកបាក់គ្នានោះ ។

វិធានការទាំងប៉ុន្មាន ដែលយើងបានរ៉ាយរាប់មកនេះ គឺជានយោ-បាយបំផ្លាញព្រះពុទ្ធសាសនានៅប្រទេសចិន ដោយធ្វើឲ្យសាសនា នៅប្រទេសចិន ដោយធ្វើឲ្យសាសនានេះគ្មានការគោរពរាប់អានទាំង ខាងផ្លូវលោក ទាំងខាងផ្លូវធម៌ ដែលរួមទាំងគុណធម៌ដែលរាច

www.budinst.gov.kh www.elibraryofcambodia.org

ឃើញបាន និងគុណធម៌ដែលឃើញពុំបាននោះផង ។

នយោបាយបំផ្លាញព្រះពុទ្ធសាសនា ដែលពួកកុម្មុយនិស្ត បានធ្វើនេះ កាន់តែបញ្ចេញរូបរាងឲ្យឃើញឡើង ។ គ្រប់រយៈ ដូចការរឹបយកទ្រព្យសម្បត្តិវត្តអារាម ការបែងចាត់វណ្ណៈ ដើម្បីឲ្យមានការបែកសាមគ្គីគ្នានៅក្នុងអង្គការព្រះពុទ្ធសាសនា -- បដិរូបគំនិតដោយបង្គាប់ឲ្យភិក្ខុ ភិក្ខុនី ចូលរួមធ្វើផលិតផល និងយកទៅអប់រំលាងខួរ ហើយលទ្ធផលនៃគ្រោងការណ៍បដិរូបគំនិតនេះ បានធ្វើឲ្យភិក្ខុ និងភិក្ខុនីជាច្រើន លាចាកសិក្ខាបទទៅជាគ្រហស្ថវិញ ។

សព្វថ្ងៃនេះ មានតែភិក្ខុ និងភិក្ខុនី ចាស់ ៗ ប៉ុន្មានរូបប៉ុណ្ណោះ ដែលពុំអាចនឹងត្រឡប់ទៅកាន់ផ្លូវលោកវិញបាន ក៏នៅគាំទ្រសហពន្ធពុទ្ធសាសនា ហើយពួកនេះពុំបានប្រតិបត្តិដោយតឹងរឹងនូវព្រះវិន័យសោះទៅហើយ ព្រោះបានក្លាយខ្លួនទៅជាសមាជិកនៃក្រុមឃោសនាបញ្ចុះបញ្ចូល នៃរបបកុម្មុយនិស្តចិនយូរមកហើយ ។

ចំពោះនយោបាយបំផ្លាញព្រះពុទ្ធសាសនានេះ ទោះបីពួកកុម្មុយនិស្តបានប្រើវិធីផ្សេង ៗ ដើម្បីញ៉ាំងការធ្វើនយោបាយនេះ ឲ្យឋិតនៅក្រោមការលាក់បំបាំងក្តី ក៏កលល្បិចផ្សេង ៗ បានលេចចេញ

www.budinst.gov.kh www.elibraryofcambodia.org

ពីរវិងននដែក បញ្ជាក់ឲ្យពិភពលោកបានដឹងខ្លះហើយ ។ តួយ៉ាង ដូចជាពួកឡាម : បានបំបែកឲ្យមានជាពីរពួកគឺ ពួក ប៉ាន់ឆេនឡាម : និងដាឡៃឡាម : ( panchen Lama et Dalai Lama ) ហើយញុះញង់និងឧបត្ថម្ភ ឲ្យមានការប្រឆាំងគ្នារវាងឡាមៈទាំងពីរពួកនេះ ដែលលទ្ធផលជាចុងក្រោយ ប្រទេសទីបេត៍បានធ្លាក់ទៅជាការលេបរបស់ចិនកុម្មុយនិស្ត ។ ចិនបានវាយយកទីបេត៍ធ្វើជាអាណាខេត្តរបស់ខ្លួនជាង ១០ ដង តាំងពីគ.ស.៨០០មក ។ ដូច្នេះ នយោបាយអ្វីដែលក្រុងប៉េកាំងបានធ្វើទៅលើទីបេត៍នោះ ពុំមែនជានយោបាយសម្រាប់ឲ្យទីបេត៍មានជីវិតទេ ផ្ទុយទៅវិញ គឺជានយោបាយសម្លាប់ទីបេត៍ ។

ទីបេត៍ ដែលជាអតីតសន្តាសនៈយ៉ាងសំខាន់ នៃព្រះពុទ្ធសាសនាខាងមហាយាននោះ បានត្រូវពួកកុម្មុយនិស្ត ចាត់ទុកជាទីដៅយ៉ាងសំខាន់បំផុតនៃការវាយប្រហារ ដោយនយោបាយស្ងប់របស់ខ្លួន ។

សេចក្តីថ្លែងការណ៍របស់កុម្មុយនិស្តស្តីពីទីបេត៍ ច្រើនប្រើពាក្យថោកទាបពុំគួរឲ្យស្តាប់ ។ ឃ្លាដែលគេលើកយកមកនិយាយជាញឹកញាប់នោះ បានបញ្ជាក់ឲ្យឃើញថា ពួកកុម្មុយនិស្តចិនត្រូវការ

www.budinst.gov.kh www.elibraryofcambodia.org

រំលំសម្ដេចដាខ្មែរឡាម៉ាហើយយកប៉ាន់ជេនឡាម៉ា ដែលជាអ្នកបំរើនយោបាយអាណានិគមនិយមរបស់ខ្លួនទៅជំនួសវិញ ។ សម្ដេចដាខ្មែរឡាម៉ាដែលជាប្រមុខរដ្ឋទីបេតផងនោះ ក៏ត្រូវភៀសព្រះអង្គទៅជ្រកនៅប្រទេសឥណ្ឌារហូតដល់សព្វថ្ងៃ ។

សេចក្ដីថ្លែងការនេះថា :

« សម្មតិពុទ្ធនិងសមាជិកនៃគណៈសង្ឃចាស់ក្នុងពេលនេះ កំពុងឆបំបាត់ប្រជាជន បោកប្រាសប្រជាជន ដោយប៉ុនប៉ងអាស្រ័យឥទ្ធិពលនៃលទ្ធិចក្រពត្តិនិយម ដើម្បីធ្វើឲ្យអំណាចរបស់ខ្លួនដែលមានសេសសល់តែបន្តិចបន្តួចនោះ គង់ទ្រង់នៅលើប្រជាជនតទៅទៀត» ។

## ចំពូកទី៤

## ការបំផ្លាញព្រះពុទ្ធសាសនា

ដោយកុម្មុយនិស្តចិន មានវត្ថុបំណងនិងគ្រោងការណ៍បំផ្លាញព្រះពុទ្ធសាសនាឲ្យអស់ទៅ ដូច្នេះហើយបានជាយើងអាចរកពត៌មានបានខ្លះពីវាំងននដែកនៃពួកនេះមកលាតត្រដាង ដើម្បីឲ្យពុទ្ធសាសនិកជនខ្មែរបានជ្រាប សំរាប់ជាការដាស់ស្មារតីឲ្យភ្ញាក់រឭក

www.budinst.gov.kh www.elibraryofcambodia.org

ហើយក្រោកឡើងទាំងអស់គ្នាចាត់វិធានការគ្រប់បែបយ៉ាង ទប់ទល់ចំពោះនយោបាយលេបព្រះពុទ្ធសាសនា ដែលពួកកុម្មុយនិស្តយៀកណាមខាងជើងកំពុងតែធ្វើដោយការលាក់បាំងនេះ ។ ប៉ុន្តែយើងស្តាយណាស់ ដោយពុំអាចរកឯកសារឲ្យបានសព្វគ្រប់ ព្រោះពួកកុម្មុយនិស្ត បានលាក់ឯកសារនិងត្រួតត្រាការផ្សាយពត៌មានតឹងរឹងណាស់ ដូចជាពត៌មានស្តីពីការធ្វើទុក្ខបុកម្នេញពុទ្ធសាសនិកជននេះ គេហាមមិនឲ្យផ្សាយទៅក្រៅប្រទេសទេ ដែលផ្សាយបានខ្លះនោះគ្រាន់តែជាកិច្ចឃោសនានៅក្នុងស្រុកប៉ុណ្ណោះ ។ ទោះជាយ៉ាងណានេះក្តី ពត៌មានដ៏ស្តួចស្តើង ដែលយើងយកមកលាតត្រដាងនេះល្មមឲ្យដឹងបានអំពីជាតាកម្មគួរឲ្យរន្ធត់ និងគួរឲ្យព្រួយបារម្ភ ដែលព្រះពុទ្ធសាសនានៅប្រទេសចិន បានទទួលពីនយោបាយបំផ្លិចបំផ្លាញនៃពួកកុម្មុយនិស្តចិននេះដែរ ។

ដោយគ្រោងការណ៍នៃពួកកុម្មុយនិស្តចិន ត្រូវការលេបត្របាក់នូវព្រះពុទ្ធសាសនាក្នុងប្រទេសដទៃទៀតផង ទើបពុទ្ធសាសនិកជនគប្បីជ្រាបជាមុននូវកលល្បិចគ្រប់យ៉ាង ដែលពួកកុម្មុយនិស្តយកទៅប្រើ ដើម្បីលេបព្រះពុទ្ធសាសនានោះ ប្រយោជន៍នឹងចាត់វិធាន

www.budinst.gov.kh www.elibraryofcambodia.org

ការទប់ទល់វិញឲ្យបានសក្តិសិទ្ធិ ។

ទោះបីគ្រោងការណ៍បំផ្លាញព្រះពុទ្ធសាសនានេះ មានត្រឹមបែបយ៉ាងណាក្តី ក៏គ្រោងការណ៍នេះមានលក្ខណៈដូចជាពពើក្អែក ឬសត្វផ្ញើប្រាណដែលទៅជ្រកបន្លំខ្លួនជាមួយដើមឈើ ឬសត្វប្រឡាំង-កាស ហើយរស់នៅដោយអាស្រ័យដើមឈើនិងសត្វនេះ ប៉ុន្តែបន្ទាប់មក ក៏សម្លាប់ដើមឈើនិងសត្វដែលខ្លួនអាស្រ័យនោះចោលទៅ ។ គឺក្នុងគោលការនេះហើយ ដែលពួកកុម្មុយនិស្តចិនបានយកទ្រឹស្តីកុម្មុយ-និស្ត និងទ្រឹស្តីព្រះពុទ្ធសាសនាទៅក្រឡែបញ្ចូលគ្នា ដើម្បីឲ្យទ្រឹស្តីកុម្មុយនិស្តសម្លាប់ទ្រឹស្តីព្រះពុទ្ធសាសនានោះឯង ។

ពិតមែនតែរឿងរ៉ាវដែលយើងពោលតទៅនេះ ស្របគ្នានឹងចំណុចទាំងឡាយដែលបានអធិប្បាយខាងដើម ប៉ុន្តែរឿងរ៉ាវទាំងនេះបានត្រូវលើកយកមកពោលបន្ថែម ដើម្បីជាភស្តុតាងនិងជាឯកសារដែលលោកអ្នកអានប្រហែលជាចង់ជ្រាបពត៌មានទាំងនេះខ្លះដែរ ។

## ១– ការរឹបនិងការកាន់កាប់សាសនសម្បត្តិ

ការបំផ្លាញព្រះពុទ្ធសាសនា បានត្រូវពួកកុម្មុយនិស្តចិនចាប់ផ្តើមធ្វើព្រមគ្នានឹងគ្រោងការណ៍ " ពេធិរូបទីដ៏ " ។ តាមសេចក្តីថ្លែងតែ

កុម្មុយនិស្តថា វិធានការនេះ មានវត្ថុបំណងដើម្បីកាត់ផ្តាច់នូវគ្រឿងចង្រៀកដែលមានប្រយោជន៍ដល់សេដ្ឋកិច្ចនៃលទ្ធិទាយទុន និងដើម្បីកែប្រែសង្គមបែបនាយទុន ឲ្យទៅជាសង្គមប្រជារាស្ត្រ ។ ដូច្នេះ ការរឹបយកទីដី វិធានការសំខាន់បំផុតនៃគ្រោងការណ៍នេះ ដែលត្រូវធ្វើឡើងក្រោមបាវចនាថា (ការស្រោចស្រង់ឥស្សរភាព និងការបំផ្លាញចោលនូវគ្រឿងចង្រៀកនៃរបបសេដ្ឋកិច្ចលទ្ធិទាយទុន) ។

ក្នុងការអនុវត្តន៍គ្រោងការណ៍បដិរូបទីដីនេះ ទ្រព្យសម្បត្តិទីដីរបស់វត្ត បានត្រូវពួកកុម្មុយនិស្តរឹបយកបន្តិចម្តង ៗ ទាល់តែអស់ ។

នៅប៉េកាំង ដែលជារដ្ឋធានីវឌ្ឍនធម៌របស់ចិន និងជាមជ្ឈមណ្ឌលកណ្តាលខាងនយោបាយ នៃលទ្ធិកុម្មុយនិស្តចិន មុនដំបូង គេនឹកស្មានថានឹងបានទទួលការបន្ធូរបន្ថយខ្លះ ពីពួកកុម្មុយនិស្តចំពោះបញ្ហាទ្រព្យសម្បត្តិព្រះពុទ្ធសាសនា ដើម្បីធ្វើជាកំពង់នៃនយោ-បាយ ប៉ុន្តែគ្មានបានទទួលការបន្ធូរបន្ថយអ្វីទាល់តែសោះ ។

ក្នុងអតីតកាល មុខចំណោយនៃវត្តធំ ៗ នៅរដ្ឋធានីនេះ ភាគខ្លះបានមកពីការបរិច្ចាគធ្វើបុណ្យ នៃអ្នកមានសទ្ធា ក្នុងព្រះពុទ្ធសាសនារួមទាំងមុខចំណូលពីសាសនសម្បត្តិផង ។ មុខចំណូលនេះ ល្មមនឹង

www.budinst.gov.kh www.elibraryofcambodia.org

ជួយដល់ការចាយវាយខ្លះបាន ហើយល្មមនឹងធ្វើឲ្យភិក្ខុក្នុងវត្តផ្សេង ៗ អាចមានជីវភាពតាំងទៅក្នុងភាពបង្គួរ ។

គួរកត់សម្គាល់ថាមានតែមុខចំណូលបែបនេះប៉ុណ្ណោះទេ ដែលអាចជួយឲ្យភិក្ខុភិក្ខុនីមានជីវភាពប្រសើរប្រាសចាកមន្ទិល អាចប្រតិបត្តិតាមគន្លងនៃព្រះវិន័យ និងប្រដៅផ្សាយព្រះធម៌បានដោយគ្មានកង្វល់ ។

ក្នុងពេលដែលកុម្មុយនិស្ត ចូលទៅកាន់កាប់ប៉េកាំង ការផ្លាស់ប្តូរច្រើនយ៉ាង ក៏បានកើតមានឡើងក្នុងរដ្ឋធានីនេះភ្លាម ។ គ្រោងការណ៍សង្គមកិច្ចសេដ្ឋកិច្ច និងជីវភាព នៃប្រជាជនក៏ច្របូកច្របល់ខុសប្រក្រតីទាំងអស់ ។ ប្រជាជនបានជួបប្រទះនឹងសេចក្តីលំបាកក្នុងអាជីវកម្ម ហើយមានប្រាក់កាសតែបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់បរិច្ចាគដល់វត្តអារាម ។ ដូច្នេះ វត្តអារាមផ្សេង ៗ លំបាកនឹងរកមុខចំណូលសម្រាប់ចាយវាយ ហើយមិនយូរប៉ុន្មាន ក៏ពុំអាចនឹងតាំងនៅជាវត្តរកើត ។ ពួកកុម្មុយនិស្តបានឆ្លៀតក្នុងឱកាសនោះភ្លាម ចូលទៅស្រោចស្រង់ភិក្ខុនិងភិក្ខុនីឲ្យផុតពីគ្រឿងចងរិតនៃរបបសេដ្ឋកិច្ចលទ្ធិនាយទុន ។ ក្នុងកិច្ចស្រោចស្រង់នេះទីដីរបស់វត្តអារាម បានត្រូវកុម្មុយនិស្តរឹបយកទៅបែងចែកឲ្យអ្នកស្រែចំការដែលមានទីដីបន្តិចបន្តួចឬគ្មានសោះ ក្រោម

គ្រោងការណ៍បដិរូបទីដី ។

វត្តអារាមខ្លះ បានត្រូវពួកកុម្មុយនិស្តឲ្យក្រសួងផ្សេងៗ ខ្ចី ឬ ជួលទៅ ។ វត្តខ្លះបានក្លាយទៅជាសាលារៀន ឬរោងឧស្សាហកម្ម ។ ជាពិសេសវត្តខ្លះបានត្រូវដាក់ឲ្យជួលជាទីលំនៅ ។ ដោយពិធីនេះភិក្ខុ ភិក្ខុនី ក៏បាត់អស់លើងនូវភាពងាយស្រួលខាងចតុបច្ច័យ សម្រាប់ញ៉ាំង ជីវិតឲ្យប្រព្រឹត្តទៅ ហើយពុំអាចនឹងធ្វើអាជីវកម្មដែលគ្មានចម្រើនអ្វីដល់ ជោគវាសនាខ្លួនតទៅទៀតបានផង ។

## ចំពូកទី ៤

## ១- ការរឹបនិងការកាន់កាប់សាសនសម្បត្តិ

ការរឹបយកទីដីរបស់វត្ត និងការកាន់កាប់អគារផ្សេង ៗ របស់វត្តនេះ ពុំមែនមាននៅប៉េកាំងប៉ុណ្ណោះទេ គឺមាននៅកន្លែង ដទៃទៀត ហើយថែមទាំងមានប្រកាសលទ្ធផលជាផ្លូវការអំពីជោគជ័យ នៃការរឹបយកទ្រព្យសម្បត្តិនៃព្រះពុទ្ធសាសនានេះផង ។

ក្នុងពេលជាមួយគ្នានោះ ដោយត្រូវការបង្កើតកម្លាំងរបស់ ខ្លួន សំរាប់បង្ក្រាប « ពួកធ្វើបដិវត្តតប » ពួកកុម្មុយនិស្តក៏ត្រូវឲ្យមាន

www.budinst.gov.kh www.elibraryofcambodia.org

បន្ទាយទាហាន និងពន្ធនាគារយ៉ាងច្រើន ។ ដូច្នេះហើយ បានជាពួកកុម្មុយនិស្តងាកទៅចាត់ការនិងវត្តទាំងឡាយនៅក្រុងសៀងហៃទៀត ។ ពួកកុម្មុយនិស្តបានរឹបយកវត្ត « សានម៉េ » ក្នុងតំបន់ « សៀងណាន់ណាន់ » ហើយផ្លាស់ប្តូរធ្វើជាបន្ទាយទាហាន ។

ក្នុង «ជុងគឹងនិងសេឈួន » វត្តជូលីន និងវត្តសាងគួ បានត្រូវរឹបយកទៅធ្វើជាមន្ទីរពេទ្យទាហាន សំរាប់ទាហានត្រូវរបួសជាច្រើន ដែលមកពីសមរភូមិកូរ៉េ ។

ក្នុងតំបន់តាឡុង សង្កាត់ស៊ិនតេ មណ្ឌលក្វាងចុង ក្រោយពីរឹបយកវត្តប៉ៅលិន ទៅធ្វើជាលំនៅទាហានចេញ ពួកកុម្មុយនិស្តបានផ្លាស់ប្តូរផ្នែកខាងក្រោយនិងបន្ទប់ធំនៃឧបោសថាគាររបស់វត្តនេះ ធ្វើជាទីឃុំឃាំងអ្នកទោសជាង៦០០នាក់ ។ អ្នកទោសទាំងនោះត្រូវ បង្ខំឲ្យធ្វើការធ្ងន់ ដែលជាហេតុនាំឲ្យការសៅហ្មងយ៉ាងខ្លាំង ដល់គ្រឹះស្ថានសាសនានោះ ដែលកាលពីមុនមកមានតែសេចក្តីសុខស្ងប់ ។

ក្នុងការរឹបយកសាសនសម្បត្តិនេះ ពួកកុម្មុយនិស្តពុំ បានបន្ធូរបន្ថយដល់និកាយព្រះពុទ្ធសាសនាណាមួយទេ ។ ដូច្នេះ ក្នុងពេលដែលគេកំពុងតែជឿថា ព្រះពុទ្ធអង្គនៅទីបេតច្រើនរូប បានទទួលបដិ-

www.budinst.gov.kh www.elibraryofcambodia.org

សណ្ឋានកិច្ចយ៉ាងប្រសើរ ពីចៅក្រសួងកុម្មុយនិស្តនោះ វត្តអារាមរបស់ពួក « ឡាមៈ » ក៏បានត្រូវពួកកុម្មុយនិស្តរឹបយក ។ ដូចជាវត្ត តាឃ្វ ដែលមានឈ្មោះល្បីល្បាញក្នុងមណ្ឌល ជឹងហៃ បានត្រូវរឹបយកទៅធ្វើជារបស់កុម្មុយនិស្តជាដើម ។ វត្តនេះ បានត្រូវបំផ្លាញខ្ទេចខ្ទីអស់ ។ អគារផ្សេង ៗ នៃវត្ត ដែលរួមទាំងវិហារ ចិនយ៉ា ដែលប្រែថា « វិហារត្រៀងមាស » នោះក៏បានត្រូវផ្លាស់ប្ដូរឲ្យទៅជាសភាយោធា និងទយោបាយនៃមណ្ឌល ជឹងហៃ ។

មានវត្តជាច្រើនទៀត ដែលបានរងគ្រោះកម្មដូច្នេះ ហើយពុំមែនត្រឹមតែទីដីដែលជាសាសទសម្បត្តិ នៃវត្តព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ដែលត្រូវរឹបយកនោះ សូម្បីតែអគាររបស់វត្ត ក៏ត្រូវរឹបយកទៅផ្លាស់ប្ដូរសម្រាប់ ប្រើប្រាស់ជាប្រយោជន៍ដល់គ្រោងការណ៍នៃកុម្មុយនិស្តផងដែរ ។

## ២- វត្តអារាមបានត្រូវបំផ្លាញឱ្យខ្ទេចរូបរោម

ទោះបីចិនកុម្មុយនិស្តបានអះអាងជាច្រើនលើកថា ពួកខ្លួនថែទាំនិងរក្សាទូវស្ថានដែលល្អប្រសើរនិងវត្ថុវប្បធម៌ ហើយច្បាប់និងពាក្យប្រ-ដៅរបស់កុម្មុយនិស្ត ក៏មានចែងទុកដូច្នេះក្ដី ប៉ុន្តែមេនៃកុម្មុយនិស្តពុំបាន

www.budinst.gov.kh www.elibraryofcambodia.org

ប្រតិបត្តិតាមនយោបាយនេះទេ ។ គេគ្មានឃើញពួកកុម្មុយនិស្តយកចិត្តទុកដាក់រក្សាការពារវត្ថុវប្បធម៌ នៃព្រះពុទ្ធសាសនាដូចជាខ្លួនបានអះអាងនោះទាល់តែសោះ ។

ផ្ទុយទៅវិញ គេឃើញមានតែការទំលាយបំផ្លាញបូជនីយ-ស្ថានព្រះពុទ្ធសាសនា ឲ្យខូចរូបឆោមនៅគ្រប់តែទីកន្លែងក្នុងប្រទេសចិន ។ មេក្រុមកុម្មុយនិស្តខ្លួនឯងក៏ព្រមទទួលសារភាពចំពោះរឿងនេះដែរ ។

ហេតុការណ៍ដូច្នេះមានកើតឡើងយ៉ាងច្រើន ហើយកំពុងតែបន្តទៅទៀត ។ គ្រាន់តែនៅភូមិភាគខាងជើងនៃប្រទេសចិនមួយកន្លែងប៉ុ-ណ្ណោះ តាមសេចក្ដីរាយការណ៍នៃទស្សនាវដ្ដីប្រចាំខែឈ្មោះ« ស៊ីរហ » បានថ្លែងថា មានការបំផ្លាញបូជនិយដ្ឋានឲ្យខូចរូបឆោមដូចតទៅ :

ចេតិយហ្លួងនៃវត្តក្លងរ៉ៃនៅតំបន់ជេងទិនក្នុងមណ្ឌលហូប៉ៃណាន់ចិនដែលស្ថាបនាក្នុងសម័យនៃវង្សចិន ហើយមានសារសំខាន់ខាងស្ថាបត្យ-កម្មបូរាណបានត្រូវពួកកុម្មុយនិស្តទំលាយរើចេញក្នុងពេលថ្មី ៗ នេះ ។

-កុំដីបីដ័ល្អនៃវត្ត ខ្វងជីថៃភិន នៅដំបន់ចោទីធៀន ក្នុងម-ណ្ឌលហូប៉ៃ ដែលសាងក្នុងគ.ស. ១២០៥ (ព.ស.១៧៤៨) ឬក្នុងឆ្នាំទី៥

នៃសម័យថៃហ្វិនរបស់ចក្រពត្តិ ឆេនចៅ នៃវង្សលៀវនេះ បានត្រូវរុះរើចេញក្នុងពេលថ្មី ។ នេះដូចគ្នា ហើយយកឈើទៅសង់ស្ពាន ។

- កុដិហៃរីនៃវត្តជៀឈៀន នៅតំបន់ថៃទុងជៀនក្នុងមណ្ឌលឆាហា ដែលសាងក្នុងសម័យវង្សលៀវដូចគ្នា នោះបានត្រូវចាងហ្វាងសាលាបឋមសិក្សាជៀប៉ូរុះរើ ហើយយកឈើទៅធ្វើជាផ្ទះមួយខ្នង ព្រមទាំងកៀនពពក៏ផង ។

ចំណែកការបំផ្លាញវត្ថុវប្បធម៌និងសិល្បៈ ខាងព្រះពុទ្ធសាសនានោះ ក៏មានធ្វើជារឿយ ៗ ហើយកុម្មុយនិស្តមានផ្សាយ អំពីរឿងនេះខ្លះ ដូចតទៅ :

ព្រះពុទ្ធរូបសំរិទ្ធចំនួន៣០អង្គក្នុងឧបោសថាគារជ្យេង ។ នៅក្រុងក្វាងទុង បានត្រូវរើចេញពីកន្លែងចូវា ហើយដឹកនាំទៅកាន់សហភាពសូវៀតទុកក្នុងពិពិធភណ្ឌឲ្យប្រជាជនមើល ។ ព្រះពុទ្ធរូបទាំងនេះជាព្រះពុទ្ធរូបបែបដែលមានសល់តិចណាស់ក្នុងក្រុងនេះ ។ ព្រះពុទ្ធរូប ៣ អង្គក្នុងចំណោមព្រះពុទ្ធរូបទាំង ៣០ អង្គនោះបានត្រូវយកមកពីវត្តហៃពុងនៃក្រុងនេះ ។

ពេនរាយការណ៍ថា រូបព្រះអរហន្ត ៥០០ អង្គដែលពីដើមនៅ

ក្នុងវិហារព្រះអរហន្ត ៥០០ អង្គ នៃវត្តល្ហលិន បានត្រូវបញ្ជូនទៅសហ-ភាពសូវៀតដូចគ្នា ។

វត្តប៉ៅលីន ក្នុងតំបន់តាទ្យុង ស្រុកជុនតសៀន ក្នុងមណ្ឌលក្វាងទុង ជាវត្តបុរាណ ដែលមានឈ្មោះល្បីល្បាញជាងគេក្នុងមណ្ឌលនេះ ។ នៅពេលដែលស្រុកនេះ ត្រូវកុម្មុយនិស្តចូលទៅព្រៃព្រា វត្តនេះក៏ត្រូវរឹបយក ហើយរូបទ្វារបាល៤ ដែលមានរូបនិមួយ ៗ មានកំពស់៤ម៥០ បានត្រូវកុម្មុយនិស្តធ្វើឲ្យខូចរូបរាង ។ ព្រះពុទ្ធរូបទាំងធំទាំងតូចចំនួន៣០អង្គក្នុងវត្តនេះ បានត្រូវលួច ហើយបញ្ជូនទៅក្នុងខេត្តទេសបាល ក្រុងក្វាងទុង ។

## ៣ - ការញុះញង់ផ្ទៃក្នុង ឲ្យកើតការ បែកបាក់គ្នា រវាងពុទ្ធសាសនិកជន

បង្កើតឲ្យមានការមិនចុះសំរុងគ្នា និងការទាញយកផលប្រយោជន៍ពីការមិនចុះសំរុងគ្នានោះ គឺជាកលឧបាយ ដែលពួកកុម្មុយនិស្តចិនបានធ្វើប្រឆាំងទល់នឹងសត្រូវរបស់ខ្លួនជាដរាបមក ។ ក្រោងការណ៍បំបែកសាមគ្គីនេះ ពួកកុម្មុយនិស្តចិន ពុំមែនគ្រាន់តែធ្វើក្នុងប្រទេសខ្លួនប៉ុណ្ណោះទេ ផ្ទុយទៅវិញ ពួកនេះបានយកទៅប្រើសំរាប់គ្រោង

www.budinst.gov.kh www.elibraryofcambodia.org

ការណ៍បង្កើតកុម្មុយនិស្តអាស៊ី ក្នុងក្របខ័ណ្ឌនៃបដិវត្តវប្បធម៌ វណ្ណៈអធននផង ។ តទៅនេះ យើងសូមលើកគូយ៉ាង ដើម្បីបញ្ជាក់ឲ្យឃើញថា ពួកកុម្មុយនិស្តបានបង្កឲ្យកើតការបែកបាក់គ្នានៅក្នុងផ្ទៃនៃព្រះពុទ្ធសាសនា ។ ដើម្បីត្រួសត្រាយផ្លូវសំរាប់អនុវត្ត ការប្រឆាំងចំពោះសាសនានេះ តើគេធ្វើយ៉ាងណាខ្លះ ?

វត្តយូទ្បុងនៃក្រុងក្វាងទុង ជាកន្លែងល្អប្រសើរមានឈ្មោះបោះសម្លេងល្បីល្បាញនៅភូមិភាគខាងត្បូងនៃប្រទេសចិន ហើយធ្លាប់ជាកន្លែងដែលប្រជាជនក្នុងស្រុកនោះទៅមកយ៉ាងច្រើន ។ ក្នុងពេលដែលកុម្មុយនិស្តចូលទៅកាន់កាប់ក្វាងទុង និងក្នុងទស្សនៈដែលថា "មានព្រឹត្តិការណ៍កើតឡើង ដោយមកពីភូមិកើតថ្មី ហាមមិនឲ្យចូលវត្តនិងអាស្រម ព្រមទាំងបង្ខំអ្នកដែលបានដោះខ្លួនពិតប្រាកដពីសង្គបឲ្យត្រឡប់ទៅកាន់លោកិយវិស័យវិញ" នោះបព្វជិតចាស់ព្រះនាមស៊ូយុងនៃវត្តនេះមួយអង្គ ។ ដោយសេចក្តីឆ្លាតក៏បានតាំងសិស្សរបស់លោកមួយអង្គឈ្មោះឆេចុង ដែលជាភិក្ខុកំឡោះឲ្យធ្វើជាចៅអធិការរងនៃវត្តនោះ ។ ភិក្ខុកំឡោះឆេងចុង នេះមានសេចក្តីស្និទ្ធស្នាលនឹងចៅក្រសួងដែលត្រួតត្រាមណ្ឌលក្វាងទុង ។ ដូច្នេះទើបលោកមាន

www.budinst.gov.kh www.elibraryofcambodia.org

សេរីភាពពេញទីក្នុងការផ្លាស់ប្តូរកិច្ចការ និងភ្នាក់ងាររបស់វត្តបានតាមអំពើចិត្ត ហើយព្រះថេរៈនៃវត្តនេះដោយស្អប់ខ្ពើមយ៉ាងខ្លាំងនូវភិក្ខុកំឡោះនោះ ក៏រួបរួមគ្នាធ្វើពាក្យតវ៉ាជូនទៅក្រុមគ្រួគ្រាទាហាន ដោយថាភិក្ខុឆេងចុងបានលួចប្រាក់របស់វត្ត ហើយសុំឲ្យតាំងភិក្ខុដទៃទៀតជាចៅអធិការរងជំនួស ។

ក្នុងពេលដែលមានការប្តឹងផ្តល់នេះ ភិក្ខុឆេងចុងបានឮក៏ពុំបង្អែរបង្អង់ឲ្យក្រុមគ្រួគ្រាទាហាន បញ្ជូនអ្នកណាមកអង្កេតសាកសួរឡើយ ភិក្ខុស្វួន-ស៊ុងបានទៅជួបនឹង យៀ ជៀនយិន ប្រធានក្រុមគ្រួគ្រាទាហានដោយខ្លួនឯងនៅកន្លែងធ្វើការឯទុងសាន ។ ភិក្ខុស្វួន-ស៊ុង បានជូនមុខចំណូលនិងមុខចំណាយ យ៉ាងជាក់ច្បាស់របស់វត្តឲ្យយៀ-ជៀនយិន មើល ។ ដោយយៀ-ជៀនយិន ធ្លាប់បានស្គាល់ និស្ស័យសុចរិតរបស់ភិក្ខុឆេងចុង ក៏ឥតបានស្តីបន្ទោសភិក្ខុឆេងចុងទេ គ្រាន់តែប្រាប់ឲ្យត្រឡប់ទៅប្រតិបត្តិនាទីឲ្យបានល្អប្រពៃតទៅ ។

ក្នុងពេលបន្ទាប់មក យៀ-ជៀនយិន ក៏បានសរសេរលិខិតបង្គាប់ការដោយខ្លួនឯង ជូនទៅនាយក្រុមការពារសាធារណភ័យនៃ

www.budinst.gov.kh www.elibraryofcambodia.org

ក្រុងនោះ ឲ្យចាត់ប៉ូលិសមួយក្រុមទៅប្រចាំការនៅវត្តឃុំឡុង ។ ការធ្វើដូច្នេះ គឺដើម្បីបង្កើតឲ្យមានការបែកបាក់គ្នាកាន់តែខ្លាំងឡើង រវាងលោកសង្ឃទាំងពីរពួក ។ តមកភិក្ខុឆេង-ចុង ក៏ស្ម័គ្រចិត្តចូលសិក្សានៅមហាវិទ្យាល័យចិនខាងត្បូងដើម្បីស្វែងរកចំណេះ ហើយក៏ចាកភេទជាគ្រហស្ថវិញទៅ ។

## ៤- បដិរូបគំនិត

បដិរូបគំនិត ដែលពួកកុម្មុយនិស្តចិនបានបង្កើតសំរាប់ភិក្ខុនឹងភិក្ខុនីក្នុងព្រះពុទ្ធសាសនា មានសេចក្ដីពណ៌នាទុកថា «វិធីបដិរូបការសិក្សាក្នុងរយៈពេលយ៉ាងយូរ» ដែលត្រូវធ្វើចំពោះភិក្ខុ ភិក្ខុនីតាំងពីផ្ដើមរលាស់ខ្លួនចេញពីលោកិយវិស័យវិញ ។

អត្ថន័យ «បដិរូបគំនិត» នេះ សំដៅយកការលាងខួរក្បាលដើម្បីកំចាត់នូវគំនិតបុរាណទាំងអស់ពីការនឹកគិត ។ អត្ថន័យម្យ៉ាងទៀតសំដៅយកវិធីបដិរូបក្រួសត្រាយផ្លូវ ដើម្បីធ្វើឲ្យភិក្ខុ ភិក្ខុនីព្រមទទួលរាប់អានលទ្ធិម៉ាក៌សុិស្ទ ឡេនីនិស្ទ ។

តាំងពីពួកកុម្មុយនិស្តចូលទៅកាន់កាប់ក្វាងទុងជាដើមមកបរិយាកាសដែលពេញទៅដោយសេចក្ដីស្ងប់ស្ងាត់ នៃវត្តព្រះពុទ្ធសាសនា

www.budinst.gov.kh www.elibraryofcambodia.org

បានត្រូវបាត់បង់អស់រលីង ។ ពួកកុម្មុយនិស្ត ពុំព្រមឲ្យពពួកសង្ឃអាចមានជីវភាពទៅបានដោយស្ងប់ស្ងាត់តទៅទៀតទេ ។

សមាជិកនៃគណៈបក្សកុម្មុយនិស្ត ទាំងបុរស.ទាំងស្ត្រីបានទៅធ្វើសវនកិច្ច នៅវត្តអារាមនិងអាស្រមភិក្ខុនីម្តងម្តងមួយកាល ហើយច្រើនល្បួងដើម្បីសំដែងសេចក្តីស្រឡាញ់រាប់អាន់ ព្រមទាំងសំដែងខ្លួនជាមិត្តនឹងភិក្ខុ ភិក្ខុនីដោយសេចក្តីអត់ធន់ និងច្រើនធ្វើឲ្យភិក្ខុ ភិក្ខុនីមានជំនឿ ទាល់តែព្រមចូលរួមបឋមសិក្សាផ្សេង ។ ព្រមចូលស្តាប់សន្និសីទ រឿងនយោបាយដែលកុម្មុយនិស្ត បានចាត់ចែងធ្វើឡើងជាពួក។ ព្រមចូលរួមក្នុងកិច្ចប្រជុំតូច ។ ដែលភិក្ខុ ភិក្ខុនីក្នុងក្រុមនោះ ខ្លះនិយាយពីរឿងគ្រោះកាចដែលកើតឡើងដល់ខ្លួនចែកគ្នាស្តាប់ ដើម្បីធ្វើឲ្យចេះដឹងរឿងនយោបាយ នឹងដើម្បីឲ្យសាងមូលដ្ឋានយ៉ាងប្រសើរសំរាប់ធ្វើឲ្យលាសិក្ខាបទក្នុងទីបំផុត ។

មុនដំបូង ពួកកុម្មុយនិស្ត អាចបោះជំហានទៅមុខយ៉ាងយឺតយូរណាស់ក្នុងបដិរូបគំនិតនេះ ។ នៅពេលដែលមានព្រឹត្តិការណ៍ផ្ទុះកើតឡើង ក្រុមទាហានក៏បានដាក់បញ្ជាឲ្យធ្វើបដិរូបគំនិតនេះជាការបង្គាប់ ហើយក្នុងពេលជាមួយគ្នានោះក៏បានដាក់លក្ខខ័ណ្ឌថា ត្រូវធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

បដិរូបនេះឲ្យហើយស្រេចក្នុងថ្ងៃទី១ មិថុនា ១៩៥០ (ព.ស.២៤៩៤) យ៉ាងយូរ ។ រយៈពេលនៃការអប់រំដំបូងនេះ បានត្រូវកំណត់រយៈពេលបណ្ដោះអាសន្នចំនួន២ខែ ។

បន្ទាប់មកនាយក្រុមនៃគណៈបក្សក៏ទៅកាន់វត្ត និងអាស្រម ហើយនិយាយជាមួយភិក្ខុនិងភិក្ខុនី ហើយព្យាយាមរកហេតុផលថា ហេតុអ្វីក៏បព្វជិតទាំងនេះលះបង់ខ្លួនចេញពីគ្រួសារទៅបួស ? នាយក្រុមកុម្មុយនិស្ត បានចាត់ចែងកិច្ចការនេះទៅតាមរបៀបដែលគេបានគ្រោងទុក ។ កិច្ចប្រតិបត្តិការរបស់នាយក្រុមនេះ អាចធ្វើបានយ៉ាងងាយ ដោយមកអំពីមានលក្ខខ័ណ្ឌថា « បន្ទាប់ពីបានអប់រំអ្នកដែលត្រឡប់ចិត្តបានសម្រេចហើយ និងត្រូវបានទទួលលិខិតរ៉ាប់រង ។

ភិក្ខុដែលសល់នៅក្នុងវត្តឡូយុាំងលីក ១៨ អង្គនោះ ក្នុងខែវិច្ឆិកា១៩៥០ (ព.ស.២៤៩៤) បានត្រូវចែកចេញជា « ក្រុមប្រឹក្សា៣ » ដើម្បីរៀន « គោលប្រជាធិបតេយ្យបែបថ្មី » និងដើម្បីទទួលការប្រៀនប្រដៅអំពីទ្រឹស្ដីនៃលទ្ធិម៉ាក់ស៊ីស្មឡេនីនីស្ម ។

ការបង្គាប់ឲ្យភិក្ខុ ភិក្ខុនី ធ្វើបដិរូបគំនិតនេះ ពុំមែនត្រូវធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ត្រឹមតែក្នុងក្រុងភ្នំពេញ និងក្រុងតូចធំដទៃទៀតប៉ុណ្ណោះទេ សូម្បីក្នុងជនបទដាច់ស្រយាលក៏ធ្វើដូចគ្នា ។ នៅហាន់គោ ដែលជាមណ្ឌលព្រះពុទ្ធសាសនាមានល្បីឈ្មោះ ក៏បានត្រូវគេអួតអាងអំពីការអប់រំបែបថ្មីនេះដែរ ។ ក្នុងហាន់គោនេះ ព្រះសង្ឃនិងឧបាសក ឧបាសិកាចំនួន ១៨០០រូបដែលចុះឈ្មោះក្នុងបញ្ជីបានជ្រើសតាំងអ្នកតំណាង ១៧ នាក់ឲ្យធ្វើជាគណៈកម្មការដំបូងបង្អស់នៃព្រះពុទ្ធសហព័ន្ធ ដើម្បី "ណែនាំវិធីសិក្សាឲ្យកើតគំនិតខាងនយោបាយ" ។

ដែលហៅថា "ឲ្យកើតគំនិតខាងនយោបាយនេះ" បានន័យថាភិក្ខុ ភិក្ខុនីត្រូវធ្វើឲ្យចុះសម្រុងនឹង "របបផ្តាច់ការនៃគណៈកម្មាជីព" ព្រមទាំងបំផ្លាញនូវ ការបម្រះរវាងជាន់វណ្ណៈ ក្នុងបំណងធ្វើឲ្យពួកព្រះសង្ឃបន្ទាប់ពីធ្វើបដិវត្តគំនិតមក ពុំមែនគ្រាន់តែលែងមានទស្សនៈក្នុងផ្លូវព្រះពុទ្ធសាសនាប៉ុណ្ណោះទេ គឺថែមទាំងមានកើតគំនិតក្នុងរឿង (ស្អប់វណ្ណៈ) និង "ការបម្រះរវាងជាន់វណ្ណៈ" ផង ។ របៀបនេះនឹងបង្កើតឲ្យមានការផ្លាស់ប្តូរគំនិតដោយបង្ខាប់ ព្រមទាំងបំផ្លាញនូវជីវភាពខាងសាសនានៃព្រះសង្ឃឲ្យអស់ទៅ ហើយខាងផ្លូវចិត្តវិញ របៀបនេះនឹងនាំឲ្យមាន

www.budinst.gov.kh www.elibraryofcambodia.org

ការរើខ្លួនចេញពីភាពម៉ឹងម៉ាត់ចំពោះព្រះវិន័យបន្តិចម្តង ១ ។ កាលណា បើភិក្ខុ ភិក្ខុនី មានចិត្ត ពុំទៀង ទាត់ចំពោះព្រះពុទ្ធសាសនា និងលែងគោរព ព្រះវិន័យហើយ អំពើនេះនឹងបើកទ្វារសំរាប់ការត្រឡប់ទៅកាន់លោកិយ វិស័យវិញ នៃបព្វជិតទាំងឡាយដោយខ្លួនឯង ។

ភស្តុតាង ដែលមាន ផ្សាយក្នុងកាសែត កុម្មុយនិស្តមួយច្បាប់ នៅហុងកុង ដែលយើងដកស្រង់យកមកជូនដូចតទៅនេះ គួរពិចារណា ហើយនឹងឃើញច្បាស់ នូវចិត្តគំនិតរបស់កុម្មុយនិស្ត របស់ព្រះសង្ឃ កុម្មុយនិស្តចំពោះព្រះពុទ្ធសាសនាយ៉ាងណាខ្លះ ។

« ភិក្ខុមួយរូបឈ្មោះ គឹម-ហេម ជាអ្នករួបរួមធ្វើប្រតិបត្តិការ យ៉ាងម៉ឹងម៉ាត់នូវគ្រោងការណ៍បដិរូបគំនិតនេះ បានពោលយ៉ាងសំខាន់ ថា « ការបង្ក្រាបពួកបដិកិរិយានោះ ជាវិធានការមួយដែលឲ្យអស់ទៅ នូវមនុស្សអាក្រក់ ហើយការពារមនុស្សល្អ ។ ការទំលាយបំផ្លាញឲ្យ អស់ទៅនេះ គ្មានទំនាស់អ្វីនឹងសីលដែលហាមមិនឲ្យសម្លាប់សត្វនោះ ទេ ។ ក្នុងអតីតកាល នៅពេលដែលព្រះពោធិសត្វទ្រង់ជួបថា មាន មនុស្សអាក្រក់ម្នាក់នៅក្នុងសំពៅជាមួយគ្នា ដើម្បីឲ្យមនុស្សល្អដែលនៅ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសំពៀរចពីភយន្តរាយ ក៏ទ្រង់ត្រូវតែកំចាត់មនុស្សអាក្រក់នោះចេញ ។

## ៥- វិធានការផលិតកម្ម

កិច្ចការខាងគំនិត របស់សមាជិកគណៈបក្សកុម្មុយនិស្តនេះ ក្រៅពីមានការយល់ឃើញតាមធម្មតាចេញ មានការយល់ឃើញម្យ៉ាងទៀត គឺពួកកុម្មុយនិស្តជឿថា វត្ថុជុំវិញដែលមានវត្ថុបំណងនោះ អាចកំចាត់គំនិតបាន ហើយបានសំអាងថា ការផ្លាស់ប្តូរបៀបចំបាំងផ្សេងព្រេង អាចបណ្តាលឲ្យកើតការផ្លាស់ប្តូរខាងគំនិតផង ហើយគេហៅថា យល់ឃើញបែបនេះ ថាជាគំនិតវិទ្យាសាស្ត្រ ។ ការដែលកុម្មុយនិស្តយក « វិធានការផលិតកម្ម » មកអនុវត្ត ដើម្បីប្រើកំឡាំងកិច្ចការព្រះសង្ឃឲ្យកើតទៅជាប្រយោជន៍ និងកិច្ចកលខាងនយោបាយ ដែលខាងក្រៅកុម្មុយនិស្តអាងថា ជាការជួយឧបត្ថម្ភផលិតកម្មដល់ពួកព្រះសង្ឃនោះ ក៏ប៉ុនគ្នា នឹងរកអាជីវកម្ម ឲ្យ ព្រះសង្ឃ និងជួយឲ្យ ព្រះសង្ឃ ជួយខ្លួនឯង ប៉ុន្តែតាមពិត ពួកកុម្មុយនិស្តបានប្រើការពួតដៃក្នុងផលិតកម្ម ដើម្បីបង្គាប់ឲ្យព្រះសង្ឃផ្លាស់ប្តូរជីវភាពដើម និងឲ្យផ្លាស់ប្តូរនិស្ស័យជាព្រះសង្ឃចេញ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងពេលដែលកំពុងធ្វើផលិតកម្មនេះ ពួកកុម្មុយនិស្ត បានខំព្យាយាមធ្វើឲ្យព្រះសង្ឃប្រព្រឹត្តល្មើសនឹងវិន័យ ។ គ្រោងការណ៍ធ្វើផលិតកម្មនៅវត្តណាន់ហួ តំបន់ឆៅគួន និងនៅវត្តយុងម៉ឺន តំបន់យូយួន ខេត្តក្វាងទុងខាងជើងនោះ បានត្រូវចាត់តាំងឡើងដោយមានគំនិតលាក់បំបាំងដូចេ្នះនៅពីខាងក្រោយ ។

វត្តណាន់ហួ នៅតំបន់ឆៅគួន ដែលកសាងជាង៨០០ ឆ្នាំមកហើយផង វត្តយុងម៉ឺនក្នុងតំបន់យូយួនដែលមានអាយុជាង៦០០ ឆ្នាំនេះ ដូចគ្នានឹងវត្តធំ ៗ ដទៃទៀតក្នុងប្រទេសចិនដែរ ហើយជាវត្តបូរាណដែលមានព្រះសង្ឃច្រើន កាលពីមុនមុខចំណូលនៃវត្តទាំង២នេះ បានមកពីថ្លៃជួលទ្រព្យសម្បត្តិរបស់វត្ត និងពីការបរិច្ចាគនៃពុទ្ធបរិស័ទល្មមចិញ្ចឹមព្រះសង្ឃ ដែលមានចំនួនរាប់រយបាន ។

នៅពេលកុម្មុយនិស្តមកកាន់កាប់ក្វាងទុងខាងជើង ការយកសម្បត្តិទ្រព្យរបស់វត្ត បាននាំឲ្យវត្តទាំង២គ្មានមុខចំណូលអ្វីសោះ ។ ដោយពន្ធដារដែលកុម្មុយនិស្តយកនោះ បានតម្រូវតាំងពីបន្តិចបន្តួចទៅពួកឧបាសក ឧបាសិកា ក៏កំពុងបរិច្ចាគប្រាក់ដល់វត្តឲ្យបាន

www.budinst.gov.kh www.elibraryofcambodia.org

ច្រើនដូចពីមុន អ្នកខ្លះបានបរិច្ចាគប្រាក់បន្តិចបន្តួចតាមដែលខ្លួនមាន ក៏ធ្វើឡើងទាំងភិតភ័យ ព្រោះខ្លាចក្រែងត្រូវចោទថា "ផ្ដល់ប្រាក់ជួយឧបត្ថម្ភដល់ផ្នែកមួយ នៃ "ពួកប្រតិកិរិយា" កាលបើដូច្នេះ វត្តក៏ពុំអាចនឹងចិញ្ចឹមព្រះសង្ឃបានតទៅទៀត ហើយចំនួនព្រះសង្ឃនៃវត្តទាំង២នេះ ក៏ថយចំនួនចុះទៅជាលំដាប់ ។ ក្នុង គ.ស. ១៩៥០ (ព.ស ២៤៩៤) នៅវត្តហ៊ុណវានហ្វូមានព្រះសង្ឃនៅសល់ ៥ អង្គ ហើយនៅវត្តយុងមិន មានព្រះសង្ឃនៅសល់តែ ៨០ អង្គប៉ុណ្ណោះ ។

ការបន្ថយចំនួនភិក្ខុភិក្ខុនីនោះ ពុំអាចដោះស្រាយដោយស្វ័យប្រវត្តិ នូវតម្លៃជីវភាពនៃព្រះសង្ឃបានទេ ។ ដូច្នេះមានតែផ្លូវម្យ៉ាង ដែលព្រះសង្ឃអាចធ្វើបានងាយទៅរកផលិតកម្ម ។

ដើម្បីជាការផ្ដួចផ្ដើម ព្រះថេរៈជាធំនៃវត្តទាំង២ បានរួមប្រាក់គ្នាបានចំនួន៨០០ដុល្លារអាមេរិកាំង ។ ដោយប្រាក់នេះរោងឧស្សាហកម្មតូចមួយហៅថា « រោងតម្បាញនិងដេរសំពត់តាឆេន » ក៏បានត្រូវបង្កើតឡើង នៅតំបន់ផូស៊ីលិនសង្កាត់ឆៅគួន ។ កិច្ចប្រតិបត្តិការនេះបានទទួលការស្រុះស្រួលអំពីចៅក្រសួងកុម្មុយនិស្តយ៉ាងប្រសើរ ហើយក្រុម

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ុនអំបោះនិងទំនិញធ្វើអំពីធ្មៃដែលជាសាខានៃ « ក្រុមហ៊ុនពាណិជ្ជកម្ម ទន្លេខាងជើង » ក្នុងមណ្ឌលក្វាងទុងក៏ជួយទំនុកបំរុងក្លាម ។

តាមលិខិតបង្គាប់ការរោងឧស្សាហកម្មនេះ បានត្រូវធ្វើឡើង ដើម្បីបង្ហាត់បង្រៀនអាជីវវិជ្ជាដល់ភិក្ខុនិងភិក្ខុនី ជាការត្រៀមទុកជាមុន សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិត ក្នុងពេលត្រឡប់ទៅកាន់លោកិយ វិស័យវិញ ។ ផលិតកម្មនេះដូចជាការខារអំបោះ, ការវេញអំបោះ ការ ត្បាញនិងការបត់ទុក ត្រូវភិក្ខុនិងភិក្ខុនីដែលចាត់ជាពួកជាក្រុមធ្វើការ ទាំងអស់ ក្រៅពីនេះមានកំណត់ម៉ោងប្រចាំថ្ងៃសំរាប់ប្រជុំសិក្សា ។ ដូច្នេះ ភិក្ខុនិងភិក្ខុនីគ្មានពេលទំនេរទេ ហើយគ្មានឱកាសនឹងទៅស្តាប់ ធម៌ទេសនាតាមទម្លាប់ផង ។

គេបានដឹងច្បាស់ថា ចិនកុម្មុយនិស្តពុំមែនគ្រាន់តែចង់ឲ្យកិច្ច ការនៃរោងឧស្សាហកម្មតាធេននេះ សំរាប់ភិក្ខុភិក្ខុនីនៃវត្តទាំង២នេះតែ ប៉ុណ្ណោះទេ ។ ដូច្នេះហើយ បានជាពួកកុម្មុយនិស្តកេណ្ឌភិក្ខុភិក្ខុនីនៅឆៅ ឆ្ងួនចំនួន១២រូបទៀត ហើយចាត់ជាក្រុមតូចឲ្យសិក្សាកិច្ចការហត្ថកម្ម ។

ការណ៍នេះបញ្ជាក់ឲ្យឃើញថា កុម្មុយនិស្តបានខំប្រឹងធ្វើឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

កិច្ចចាត់ការបែបនេះ នឹងកិច្ចការបដិវត្តបច្រើនឡើងដោយរួសរាន់ ដើម្បីធ្វើឲ្យភិក្ខុភិក្ខុនី ត្រឡប់ទៅកាន់លោកីយវិស័យវិញ ។

ក្រោយពីវិធានការដូចពេលមកនេះ ពួកកុម្មុយនិស្តបានចាត់ភិក្ខុចាស់ជរានិងអ្នកដែលអាស្រ័យនៅក្នុងវត្ត ឲ្យរួមគ្នាជាពួកធ្វើស្រែធ្វើចំការ ហើយកែខៃទីដីទំនេរ ឲ្យកើតទៅជាប្រយោជន៍ ។ សូម្បីតែភិក្ខុ ភេទ យិន ដែលក្នុងពេលនោះមានអាយុច្រើនជាង ៥០ ឆ្នាំហើយក្តី ក៏ពុំបានទទួលការលើកលែងដែរ គេបានតម្រូវឲ្យធ្វើការងារធ្ងន់ដូចគ្នា ។

ក្នុងពេលដែលត្រូវបង្គាប់ឲ្យធ្វើការ និងកែខៃទីដីទំនេរឲ្យកើតទៅជាប្រយោជន៍នោះ ព្រះសង្ឃត្រូវធ្វើការនឿយហត់ជាច្រើនម៉ោងហើយថែមទាំងមានបញ្ញត្តិយ៉ាងម៉ឹងម៉ាត់សំរាប់ការងារប្រភេទនេះ ។ អ្នកធ្វើការម្នាក់ ៗ ត្រូវធ្វើការដែលគេតម្រូវនោះឲ្យបានហើយស្រេចតាមពេលវេលាដែលបានកំណត់ទុក ។ ចំពោះភិក្ខុដែលធ្វើការបាន គ្រប់អង្គបានត្រូវកំណត់ឲ្យធ្វើការធ្ងន់ដោយមិនសំរាកអស់ពេល ៦ ម៉ោងរាល់ថ្ងៃ ។ ដូច្នេះភិក្ខុអាយុច្រើនឬតិចដែលពុំសូវមាំទាំ គ្មានពេលសំរាកទេ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយហេតុនេះ ក្នុងមួយថ្ងៃ ៗ ក្រោយដែលបានធ្វើការធ្ងន់រួច ភិក្ខុទាំងនេះ ក៏អស់កម្លាំងល្ហិតល្ហៃ គ្មានពេលនឹងប្រតិបត្តិការសាសនកិច្ចកើតទេ ។

ក្នុងក្រុងហាន់គៅ ក៏មានហេតុការណ៍ដូចគ្នានេះដែរ ។ ព្រះសង្ឃវត្តលិនយិន ក្រៅពីត្រូវធ្វើស្រែធ្វើចំការចេញ ក៏ត្រូវបើកផ្ទះលក់អាហារ នៅបរិវេណទន្លេសាប ។ ក្នុងចំណោមវត្តតូច ៗ ដទៃទៀតនៃក្រុងនេះ មានវត្តខ្លះបានតាំងរោងឧស្សាហកម្មតូច ៗ ព្រមទាំងធ្វើស្រែធ្វើចំការ និងធ្វើផលិតផលដទៃទៀត ។

ជាពិសេស « ទីស្នាក់ការចាត់ការងារនៃសហពន្ធ ពុទ្ធសាសនាប្រចាំហាន់គៅ » បានទទួលភារៈ ធ្វើការអប់រំឲ្យធ្វើ «ផលិតកម្ម» និងឲ្យចេះ «កិច្ចប្រតិបត្តិការរួម» ដល់ភិក្ខុនិងភិក្ខុនី ដើម្បីឲ្យទៅធ្វើការដោយខ្លួនឯង ។

ទីស្នាក់ការ ជីភួនយិននៃវត្តជូស៊ុលិង នៅតំបន់ថាងថុងស្រុកចាំងស៊ូក្នុងក្វាងទុងខាងជើង និងវត្តដទៃទៀតក្នុងប្រទេស បានត្រូវចាត់ឲ្យមាន «បដិរូបកិច្ចការ» យ៉ាងទូលំទូលាយដោយការទំនុកបំរុង និងណែនាំពីអង្គការផ្សេង ៗ នៃគណៈបក្សកុម្មុយនិស្ត ។

www.budinst.gov.kh www.elibraryofcambodia.org

វិធានការផលិតកម្មនៃពួកកុម្មុយនិស្តនេះ បានធ្វើឲ្យព្រះសង្ឃប្រកបការងារចិញ្ចឹមជីវិតដូចជាគ្រហស្ថ ផ្ទុយពីបទបញ្ញត្តិនៃព្រះពុទ្ធសាសនា ដែលតម្រូវឲ្យភិក្ខុភិក្ខុនីចិញ្ចឹមជីវិតដោយការបរិច្ចាគនៃអ្នកដទៃ គឺឲ្យត្រេចបិណ្ឌបាត្រដែលមានចែងនៅក្នុងករណីយកិច្ច ៤ នៃភិក្ខុ ។

## ៦- បង្គាប់ឲ្យភិក្ខុនិងភិក្ខុនីសឹក

ការបង្គាប់ឲ្យភិក្ខុនិងភិក្ខុនីសឹកនោះ ជាវិធានការចុងក្រោយបង្អស់នៃការបំផ្លាញព្រះពុទ្ធសាសនានៃចិនកុម្មុយនិស្ត ។ កលល្បិចដែលពួកកុម្មុយនិស្តធ្វើនេះ ដោយមានវត្ថុបំណងដូច្នេះ គឺក្នុងពេលដែលភិក្ខុនិងភិក្ខុនីត្រឡប់ទៅកាន់លោកិយវិស័យវិញ ហើយក៏គ្មានអ្នកផ្សាយសាសនា ហើយព្រះពុទ្ធសាសនាក៏ត្រូវសាបសូន្យទៅដោយឯកឯង ។ ជាការពិតណាស់ ការដែលកុម្មុយនិស្តធ្វើឲ្យភិក្ខុនិងភិក្ខុនីចូលរួមក្នុងបដិវត្តគំនិត និងផលិតកម្មកសិកម្មនោះ គឺជាការត្រួសត្រាយផ្លូវសម្រាប់ធ្វើឲ្យភិក្ខុនិងភិក្ខុនី ត្រឡប់វិលទៅកាន់លោកិយវិស័យវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូចមានបញ្ហានៃក្រុមត្រួតត្រាទាហានរបស់រដ្ឋការក្រុងក្វាងទុង ដែលតម្រូវឲ្យអប់រំភិក្ខុនិងភិក្ខុនីដោយ « បញ្ចូលឲ្យសឹក » ។

ក្នុងថ្ងៃទី ២៧ វិច្ឆិកា ១៩៤៩ ( ព.ស. ២៤៩៣ ) ពួកកុម្មុយនិស្តបានប្រកាសថា ក្នុងពេលដែលក្រុមផ្សេង ៗ នៃកងទ័ពរំដោះជាតិរបស់ប្រជាជនចិន ចូលទៅតាមថ្នល់ចុងហ្វេ នៅសៀងហៃនោះ ព្រះសង្ឃនៃវត្តផ្សេង ៗ ក្នុងក្រុងនេះ កំពុងស្ថិតនៅក្នុងសភាពដែល « ពួកភិក្ខុជាថេរៈធាន់ត្រឹមតែបបរទេ ។ ភិក្ខុដែលប្រជាជនស្គាល់ស្និទ្ធស្នាលត្រូវប្រតិបត្តិខ្លួន ដើម្បីប្រទេសជាតិរបស់ខ្លួន ចំណែកភិក្ខុតូចតាចដែលលោកខាងក្រៅពុំស្គាល់ ត្រូវត្រឡប់ទៅកាន់លោកិយវិស័យវិញ » ។

ក្នុងពេលដែលកុម្មុយនិស្ត ចូលទៅកាន់កាប់ក្រុងសៀងហៃនោះ សភាពសេដ្ឋកិច្ចដែលផុនដាបខ្វាំងណាស់ទៅហើយនោះ ក៏កាន់តែទ្រុឌទ្រោមធ្ងន់ឡើងរាល់ថ្ងៃថែមទៀត ហើយដោយស្ថានភាពសេដ្ឋកិច្ចទ្រុឌទ្រោមនេះ បានពុទ្ធបរិស័ទភិចរកាស់ដែលបានទៅវត្តទៅវ៉ា ។ ការបរិច្ចាគនៃអ្នកមានសទ្ធា បានចុះរនថយទៅរាល់ថ្ងៃ ។ វត្តផ្សេង ៗ បានធ្លាក់ទៅក្នុងស្ថានភាពខ្វះប្រាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

បន្ទាប់ពីការរំដោះជាតិ, ជីវិតស្ងប់រៀបរយនៃភិក្ខុក្នុងវត្ត សានមី តំបន់សៀវណាន់ម៉ាន់ ស្រុកម៉ាន់សី ក្នុងក្រុងសៀងហៃបាន ផ្លាស់ប្តូរខុសពីប្រក្រតីទាំងអស់ ។ ការឆាន់អាហារនៃភិក្ខុក៏បានផ្លាស់ ប្តូរទៅពីការឆាន់បាយមួយថ្ងៃពីរដង និងបបរម្តងនោះ ទៅជាបបរ ២ ដង បាយម្តងវិញ ។ កាលពីមុននេះភិក្ខុឆាន់ម្ហូបដែលជាអន្លក់ ២ មុខ សម្ល១មុខ តមកនៅសល់តែសម្លមួយមុខ ហើយក្នុងទីបំផុត ក៏មាន ត្រឹមតែបបរប៉ុណ្ណោះ ។ ក្នុងពេលជាមួយគ្នានោះចំនួនព្រះសង្ឃដែល មានច្រើនអង្គ ក៏នៅសល់ត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ។ ទោះបីដូច្នេះក្តី វត្តក៏ពុំអាចនឹងចិញ្ចឹមកើត ។

ភិក្ខុមួយអង្គឈ្មោះ ជូហ្វាំង ដែលនៅក្នុងវត្ត ទោះបីបានដឹង ច្បាស់អំពីសភាពលំបាកនៃវត្តដូច្នេះក្តី ប៉ុន្តែដោយយល់ថាជាស្ថាន ការណ៍កើតមកពីការចាត់របៀបសង្គមនិងពុទ្ធសាសនា ក៏ចេះតែធន់ទ្រាំ ចំពោះវិក្រិត្តិការណ៍នេះ ហើយលោកទៅសុំសេចក្តីណែនាំពីមេកុម្មុយ-និស្តម្នាក់ ប៉ុន្តែត្រឡប់ជាបានទទួលការតបយ៉ាងចំអកដែលគួរឲ្យរន្ធត់ ថា :

www.budinst.gov.kh www.elibraryofcambodia.org

« តាំងពីនេះតទៅ ពួកព្រះសង្ឃត្រូវតែជួយខ្លួនឯង ។ ត្រូវបោះបង់ចោលរបៀបជីវភាពនិងគំនិតដែលហួសសម័យចេញឲ្យអស់ ហើយងាកទៅបំពេញកិច្ចការដែលនាំឲ្យកើតផលប្រយោជន៍ដោយរួសរាន់ ។ ត្រូវឲ្យស្វែងរកជីវភាពបែបថ្មី ដោយ[illegible]ខ្លួនដោយខ្លួនឯង និងទទួលបំរើប្រជាជន ។ នេះជាផ្លូវ[illegible]ចេញដែលមានតែមួយគត់ប៉ុណ្ណោះ » ។

លុះបានស្តាប់ដូច្នេះ ភិក្ខុភ្លៀងក៏[illegible]ព្រះទ័យថា ស្ថានការណ៍ដែលវត្តបានជួបប្រទះនេះ ពុំមែនត្រូវ[illegible]ពុំទៀងទាត់តែម៉្យាងប៉ុណ្ណោះទេ គឺមាន[illegible]របស់កុម្មុយនិស្តចំពោះព្រះពុទ្ធសាសនាផង ។ [illegible]នឹងហេតុការណ៍ដូច្នេះ លោកក៏អស់សង្ឃឹម[illegible]ស្ថានភាពនៃវត្តផ្សេង ៗ ល្អប្រសើរឡើងកើត ។

## ៧– ជីវភាពនិង[illegible]

## របៀប[illegible]

ពួកកុម្មុយនិស្ត បានជ្រើសយកព្រះសង្ឃ (ហាន់គោ)

ធ្វើជាកន្លែងសំរាប់អនុវត្តសាកល្បង «បដិរូបពិសេស» គឺគ្រោងការណ៍ ទំនុកបំរុងឲ្យភិក្ខុភិក្ខុនី រៀបអាពាហ៍ពិពាហ៍នឹងគ្នា ។ តមកគ្រោងការណ៍ នេះបានត្រូវពង្រីកទៅក្នុងបរិវេណដទៃទៀត ក្នុងភូមិភាគខាងកើតនៃ ប្រទេសចិន ។

អត្ថបទមួយស្ដីពីវិវាហមង្គល ដ៏ចំពោលមកនេះ គេបាន សរសេរផ្សាយដូចតទៅ :

« ក្នុងពេលដែល ហាន់ គោ ធ្លាក់ទៅក្នុងអំណាចកុម្មុយនិស្ត ជីវិតក្នុងសាសនានៃភិក្ខុភិក្ខុនី បានត្រូវផ្លាស់ប្ដូរតែទាំងអស់ ។ ក្នុងវត្ត ឈិនជូ ក្រុងហាន់គោ មានភិក្ខុមួយអង្គឈ្មោះវិហ្វាំង ដោយត្រូវរកផ្លូវ ចិញ្ចឹមជីវិតព្រះសង្ឃក្នុងវត្ត ក៏រួបរួមនិងព្រះសង្ឃដទៃទៀត ដែលជាមិត្ត ភក្តិច្រើនអង្គ ឈប់ប្រកបពិធីផ្សងព្រេង និងពិធីដទៃទៀត ខាងព្រះពុទ្ធ សាសនា ហើយនាំគ្នាទៅបើកផ្ទះលក់អាហារប្រជាជននៅក្នុងបរិវេណ នៃទីតាំងសហព័ន្ធពុទ្ធសាសនិកប្រចាំក្រុងហាន់គោ ។ ភិក្ខុវិហ្វាំងត្រូវ ធ្វើការដោយខ្លួនឯង ហើយបំពេញនាទីជាអ្នករត់តុ ដោយខ្លួនឯងទៀត ។ ទោះបីភិក្ខុវិហ្វាំង ខំប្រឹងយ៉ាងពភាក្ដី ដោយគស្ងួចំពោះសភាព សេដ្ឋកិច្ចពុំបាន ក៏បិទផ្ទះលក់នោះទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងពេលនោះ មានភិក្ខុនីមួយអង្គឈ្មោះ សែលៀង នៃអាស្រមទាងជីតាប៉េ បានចេញទៅធ្វើការនៅរោងតម្បាញ រ៉ែត្វង ដើម្បីញ៉ាំងជីវភាពឲ្យប្រព្រឹត្តទៅ ប៉ុន្តែមិនយូរប៉ុន្មាន រោងឧស្សាហកម្មនេះក៏ឈប់ធ្វើការ ។

ថ្ងៃមួយភិក្ខុ វិហ្វាំង បានជួបនឹងនាងសែលៀង ដោយចៃដន្យនៅថ្នល់នៃក្រុងហាន់គោ ។ តាំងពីនោះមកទាំង២នាក់នេះ បានស្និទ្ធស្នាលនឹងគ្នាយ៉ាងខ្លាំង ហើយទីបំផុតទៅ ក៏រៀបវិវាហមង្គលនឹងគ្នាដោយពិធីដែលសហពន្ធពុទ្ធសាសនា នៃក្រុងហាន់ចូវតាក់តែងឲ្យ ។

មានភិក្ខុនីមួយរូបទៀតឈ្មោះបៀវហ្វ៊ែ ដែលធ្លាប់នៅអាស្រមភិក្ខុមួយក្នុងស្រុក លូឝុង នៃក្រុងសៀងហៃ ដោយក្រុមកុម្មុយនិស្តចូលទៅកាន់ក្រុងសៀងហៃ រឹតត្បិតខាងព្រះពុទ្ធសាសនាពេក មិនយូរប៉ុន្មានភិក្ខុនីបៀវហ្វ៊ែក៏ចេញទៅធ្វើការផ្សេង ៗ រួមនឹងប្រជាជនក្នុងក្រុងនោះ ។ ការអប់រំធ្វើឲ្យស្រឡាញ់ជាតិបាននាំឲ្យភិក្ខុនីនេះ គាត់ចិត្តបន្តិចម្តង ៗ រហូតដល់បណ្ដោយខ្លួនឲ្យមានលទ្ធផលយ៉ាងវែងទៅទៀត ។ បន្ទាប់មក ក្នុងពេលដែលមានវិធានការបង្គាប់ឲ្យប្រើច្បាប់វិវាហមង្គលថ្មី ភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុនី មៀវហ្វិ ដែលពេលនោះមានអាយុ ៤៣ ឆ្នាំ ហើយបានត្រូវបបួលឲ្យផ្លាស់ភេទ ដោយតែងខ្លួនដូចជាជនធម្មតា ហើយឲ្យរៀបវិវាហមង្គល នឹងម៉ៅឃ្វអាននៃក្រុង កៅឃ្វ ។

ដូចជាអាស្រមភិក្ខុនីឯទៀត ក្នុងក្រុងសៀងហៃ, អាស្រមភិក្ខុនីនៅតំបន់ ចាពូ ពុំបានជាកន្លែងសម្រាប់ភិក្ខុនីប្រតិបត្តិសាសនកិច្ចទៀតទេ ។ ភិក្ខុនី ហោម-ហ្វុង នៃអាស្រមនេះបន្ទាប់ពីបានទទួលការរំដោះមក ក៏ត្រូវបញ្ជូនទៅកាន់សហពន្ធស្ត្រី ដើម្បីចូលរួមក្នុងការអប់រំសិក្សានិងប្រតិបត្តិកិច្ចការផលិតកម្មជាមួយនឹងកម្មករបុរស ។ ក្នុងក្រុមជាមួយគ្នានិងភិក្ខុនី ហោម-ហ្វុង នេះ មានកម្មករបុរសម្នាក់ឈ្មោះ ប៉ៃស៊ុង-សាន ដែលកាលពីមុននេះធ្លាប់នៅទីស្នាក់ការនេសាទជាតិតំបន់ ចាពូ ។ បុរសស្ត្រីគូនេះបានជួបគ្នាជានិច្ច ហើយទាំង ២ នាក់បានជួយគ្នាទៅវិញទៅមក ទាំងក្នុងការបំពេញកិច្ចការក៏ដូចជាការសិក្សាដែរ ។ ក្នុងទីបំផុតដើម្បីតបស្នងដល់ការណែនាំ នៃ « សហពន្ធស្រី » ដែលគម្រូវឲ្យរត់ចេញពីលទ្ធិនាយទុននិងការផ្សងព្រេង និងឲ្យលាងបំបាត់នូវគំនិតបែបនាយទុនចេញនោះ ជនទាំង ២ នាក់នេះ ក៏បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

នេះគ្រាន់តែជាតួយ៉ាង ២-៣ បែបនៃកលឧបាយរបស់កុម្មុយ-និស្ត ដែលបានធ្វើចំពោះពុទ្ធសាសនិកជនក្នុងប្រទេសចិន ។ ហេតុការណ៍ទាំងប៉ុន្មានដូចពោលមកនេះ បានកើតមកពីផែនការរបស់កុម្មុយ-និស្ត ដែលបានគ្រោងទុកជាមុន ដើម្បីបំផ្លាញព្រះពុទ្ធសាសនា ។ គួរកត់សម្គាល់ថា ភិក្ខុនិងភិក្ខុនីដែលបានរងគ្រោះពីគ្រោងការណ៍នេះ ពុំត្រូវការឲ្យមានការផ្លាស់ប្ដូរភេទដូច្នោះទេ ។ នៅគ្រប់តែករណី មានសភាពដូចគ្នា គឺភិក្ខុនិងភិក្ខុនី ដែលរងអំពើបង្ខំឲ្យផ្លាស់ភេទនោះ ច្រើនតែមានអាយុ ៤០ ឬ ជាង ៤០ ទៅហើយ គ្មានបំណងអ្វីនឹងត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញសោះ បើតាមទម្លាប់ពីមុនមក ។

ដែលនិយាយនេះ ពុំមែនបានន័យថា ក្នុងតំបន់ដែលកុម្មុយ-និស្តត្រួតត្រា គ្មានភិក្ខុ និង ភិក្ខុនីកម្លោះក្រមុំសឹកនោះទេ ផ្ទុយទៅវិញមានសឹកជាញឹកញាប់ ទាល់តែពុំមែនជាការចម្លែកអ្វីសោះទៅហើយ ។

តទៅនេះគឺករណីបន្ថែម ដែលបញ្ជាក់ឲ្យឃើញថា កុម្មុយ-និស្តបានបង្គាប់ឲ្យភិក្ខុ និង ភិក្ខុនីសឹកដោយរបៀបយ៉ាងណាខ្លះ :

ក- កាសែតតាគុងពៅ នៅក្រុងហុងកុង ចុះថ្ងៃទី ១៣ វិច្ឆិកា

www.budinst.gov.kh www.elibraryofcambodia.org

១៩៥១ ( ព.ស.២៤៩៥ ) បានពោលថា ក្នុងអាស្រម ជ័ត្ត្វយ៉ែន តំបន់ប៉ែ-ស៊ីចៀវ ដែលនៅក្រៅក្រុងចាងស៊ុយចៀងនៃមណ្ឌលកៀងស្វី មានភិក្ខុនីក្រមុំ ៨ ឬ ៩ អង្គនៅជាមួយគ្នានឹងភិក្ខុនីចាស់ ៗ ។ ក្នុងសម័យសង្គមនាយទុនអាស្រមនេះគេបានស្គាល់ ប៉ុន្តែក្នុងពេលដែលមានការធ្វើបដិ-រូបធីដី ភិក្ខុនីទាំងនេះក៏នាំគ្នាសឹក ហើយខ្លះរៀបអាពាហ៍ពិពាហ៍ ខ្លះទៀតងាកទៅរកកិច្ចការដែលមានប្រយោជន៍ធ្វើ ហើយសល់នៅតែភិក្ខុមួយអង្គ ចាំអាស្រមដែលស្ងាត់ជ្រងំ ។

១- កាសែតតាគុងប៉ោដដែលនេះបានចែងថា ក្នុងតំបន់ឆៅលី ដែលជាស្រុកចាស់នៃខេត្តវ៉ាន់អាន់ មណ្ឌលហ្វូគៀន ភិក្ខុនីចំនួនច្រើនជាង ២០ អង្គ ដែលប្រតិបត្តិតាមការឃោសនាច្បាប់អាពាហ៍ពិពាហ៍ថ្មីបានសម្រេចចិត្តសឹក ហើយរៀបអាពាហ៍ពិពាហ៍ ។

សេចក្តីរាយការណ៍នេះ បានលាតត្រដាងថា ក្នុងតំបន់មួយទៀត មានភិក្ខុនិងភិក្ខុនីច្រើនជាង ២០ អង្គ បានសឹកហើយត្រឡប់ទៅកាន់ជីវភាពធម្មតា ។ ដូច្នេះ បើគិតសរុបចំនួនភិក្ខុនិងភិក្ខុនីដែលសឹកទូទាំងប្រទេសទៅ បន្ទាប់ពីដាក់ឲ្យអនុវត្តច្បាប់អាពាហ៍ពិពាហ៍ថ្មីនោះមក មានចំនួនរាប់ម៉ឺនរូបទៅហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

គ-ទស្សនាវដ្ដីប្រចាំខែឈ្មោះស៊ីហ្វេ បានផ្សាយថា ក្នុងស្រុកថៃចូវផៀនមណ្ឌលជីកៀងមានភិក្ខុនីជាង៥០ អង្គ បានត្រឡប់ទៅកាន់លោកិយវិស័យវិញ ។

គ្មានកាសែតកុម្មុយនិស្ដណាមួយ ផ្សាយអំពីភិក្ខុនិងភិក្ខុនីដែលពុំព្រមសឹក ឬដែលត្រូវបង្ខាប់ហើយពុំព្រមសឹក ឬដែលសម្លាប់ខ្លួន ព្រោះតែគេបង្ខាប់ឲ្យសឹកនោះទេ ។ ព្រឹត្តិការណ៍ដូច្នេះ គង់កើតមានជាប្រាកដ ។

សេចក្ដីរាយការណ៍ ប្រចាំឆ្នាំនៃសាធារណរដ្ឋចិន គ.ស.១៩៥២ (ព.ស. ២៤៩៦) បានពោលថាក្នុងឱកាសពិធីសម្ពោធថ្ងៃទី ៨ មីនា ១៩៥២ សហពន្ធស្រីនៃក្រុងឆាំងឆាបានបង្ខាប់ឲ្យភិក្ខុនី ពី២០០ទៅ៣០០រូបរៀបអាពាហ៍ពិពាហ៍នឹងមេនៃពួកកុម្មុយនិស្ដ ។ ការដាក់បញ្ជាឲ្យសឹកនេះ បានបណ្ដាលឲ្យមានការសម្លាប់ខ្លួនឯងជាច្រើនកន្លែង ។ គេបានស្មានថាក្នុងព្រឹត្តិការណ៍នេះមានភិក្ខុនីជាង ២០ អង្គបានលោតទឹកសម្លាប់ខ្លួននៅទន្លេធៀង ។

គង់មានភិក្ខុនិងភិក្ខុនីរាប់មិនអស់ ដែលព្រមស្លាប់ដើម្បីសាសនារបស់ខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

## ៨- ស្ថានភាពព្រះពុទ្ធសាសនា ក្រោមអំណាចកុម្មុយនិស្ត

ក្នុងខែវិច្ឆិកា ១៩៥២ (ព.ស ២៤៩៦) កុម្មុយនិស្ត បានប្រជុំពុទ្ធបរិស័ទនៅវត្តក្វាងជី ក្រុងប៉េកាំង ដើម្បីចាត់តាំងសហពន្ធពុទ្ធសាសនិកជន ។ សហពន្ធនេះ បានត្រូវចាត់តាំងឡើងដើម្បីត្រួតត្រាអ្នករាប់អានព្រះពុទ្ធសាសនា ឲ្យបំពេញកិច្ចការជាប្រយោជន៍ដល់ពួកកុម្មុយនិស្ត ។

តាមសេចក្តីថ្លែងការណ៍នៃ សហពន្ធពុទ្ធសាសនិកនៃប្រទេសចិន ដែលបានប្រជុំកាលពីថ្ងៃ ១៣ វិច្ឆិកា ១៩៥២ បានបញ្ជាក់ថា វត្ថុបំណងនៃសហពន្ធ គឺដើម្បីធ្វើឲ្យអ្នករាប់អានព្រះពុទ្ធសាសនា មានសាមគ្គីគ្នា ក្រោមការដឹកនាំនៃរដ្ឋាភិបាលប្រជាជន ចូលរួមក្នុងវិធានការរក្សាមាតុភូមិ ដោយស្នេហាក្រៃលែង រក្សាសន្តិសុខនៃពិភពលោក ។

ប៉ុន្តែ ក្នុងពេលដែលសហពន្ធពុទ្ធសាសនិក បានត្រូវចាត់តាំងឡើងជាផ្លូវការនៅប៉េកាំង នៅខែមិថុនា ១៩៥៣, សកម្មភាពនៃ

អង្គការនេះ បានបញ្ជាក់ឲ្យឃើញថា គ្មានអ្វីដទៃក្រៅពីធ្វើជាឧបករណ៍ខាងនយោបាយ នៃពួកកុម្មុយនិស្តនោះឡើយ ។

ក្នុងសេចក្ដីរាយការណ៍ផ្សេង ៗ ដែលកុម្មុយនិស្តបានផ្សាយដោយខ្លួនឯង គេអាចឃើញថា អ្នកតំណាងដែលជ្រើសតាំងមកនោះពុំមែនគ្រាន់តែគេកអរើករាយ ចំពោះការចាត់តាំងរណសិរ្សដែលមុកមាំ ដែលស្រឡាញ់ជាតិ និងរួបរួមគ្នាជាមួយប្រជាជនរបស់ជាតិ ដើម្បីរក្សាមាតុភូមិដោយសេចក្ដីស្មោះត្រង់ និងរក្សាសន្តិសុខរបស់ពិភពលោកតែប៉ុណ្ណោះទេ គឺថែមទាំងមានមតិយល់ស្របយ៉ាងដាច់ខាតឲ្យបំបែកចេញពីគ្នា[illegible] ទាំងខាងផ្លូវចិត្ត និងផ្លូវកាយ ហើយនិង[illegible]បុរសនិងព្រះសង្ឃាត់ពិសេសឲ្យអស់ទៅព្រមទាំងសមាជិកនៃក្រុម[illegible]បានបតិកិរិយាទៀតផង ។

ម្យ៉ាងទៀត [illegible]ក្ដីបំណងនឹងបង្ក្រាបពុទ្ធសាសនិកជនដែលពុំព្រមបំរើដល់[illegible]កុម្មុយនិស្ត ឬពុំព្រមឲ្យក្រសួងមានសមត្ថកិច្ចកែខៃ ។ [illegible]របស់កុម្មុយនិស្ត បានប្រើសហពន្ធពុទ្ធសាសនិកជាឧបករណ៍[illegible] ។ ក្នុងរឿងនេះលំបាកនិង

www.budinst.gov.kh www.elibraryofcambodia.org

ចាត់ទុកថាជារគ្គចំណាងពិតប្រាកដនៃពុទ្ធបរិស័ទណាស់ ទាំងក្នុងការជ្រើសតាំងប្រធាន និងក្នុងការចាត់ការនៃសហាពន្ធនេះ ។

គួរកត់សំគាល់ថា សហាពន្ធពុទ្ធសាសនិកបានត្រូវចាត់តាំងឡើងដោយឆាប់រហ័សណាស់ បន្ទាប់ពីភិក្ខុនិងភិក្ខុនីយ៉ាងច្រើនបានសឹក ហើយវត្តអារាមយ៉ាងច្រើនបានត្រូវរឹបអូសទំលាយ ។ អង្គការនេះពុំបានធ្វើការទាក់ទងអ្វីនឹងព្រះពុទ្ធសាសនាសោះទេ គ្រាន់តែបំពេញកិច្ចការដែលក្រសួងមានសមត្ថកិច្ច គឺរណសិរ្សរួមនៃគណៈបក្សកុម្មុយនិស្តដាក់មកឲ្យធ្វើតែប៉ុណ្ណោះ ។

របៀបជ្រើសតាំងប្រធាននៃសហាពន្ធពុទ្ធសាសនិកនេះ ពួកកុម្មុយនិស្តបានកំណត់ទុកដូច្នេះគឺ :

នាយកទទួលខុសត្រូវ ត្រូវរាយការណ៍អំពីវិធីជ្រើសតាំងជាមុន រួចហើយទើបប្រុងប្រៀបកិច្ចការនិងមានការប្រឹក្សាគ្នា បន្ទាប់មកមានការស្នើឈ្មោះបេក្ខជនដែលស្មគ្រឲ្យគេជ្រើសតាំង រួចហើយក៏មានការជ្រើសតាំងពិតប្រាកដ ។

www.budinst.gov.kh www.elibraryofcambodia.org

គប្បីជ្រាបថា ការត្រៀមនិងការពិភាក្សាគ្នា ដែលកុម្មុយនិស្ត បានធ្វើនៅគ្រប់តែការបោះឆ្នោតនេះ គឺជាកលល្បិចមួយ សំរាប់បើក ឱកាសឲ្យអ្នកដែលជាកុម្មុយនិស្តពិតប្រាកដ អាចស្នើឲ្យបានទទួលការ ជ្រើសតាំង ។ ការជ្រើសតាំងដែលប្រើកលល្បិចបែបនេះ ពុំខុសអ្វីពី ការតែងតាំងនោះទេ ព្រោះគេឲ្យបោះឆ្នោត គ្រាន់តែសំរាប់បំភ័ន្តមតិ សាធារណៈប៉ុណ្ណោះ ។

ពួកកុម្មុយនិស្តបានតែងតាំង ប៉ាន់ជេនង្វ៉ុតុន្នី ជានាយកកិត្តិម-សក្តិ និងភិក្ខុជរាមួយអង្គឈ្មោះ ឃួន យិន ជានាយករបស់សហពន្ធ ( ភិក្ខុនេះអនិច្ចកម្មនៅថ្ងៃទី ២០ កញ្ញា ១៩៥៣ ) ដោយបំណងនឹង លួងចិត្តពុទ្ធបរិស័ទភាគច្រើន ប៉ុន្តែ តាមពិត មានតែនាយកសហពន្ធ សមាគមប៉ុណ្ណោះទេ ដែលមានអំណាចពិតប្រាកដ ហើយគ្រប់គ្នាក៏ ត្រូវមានចិត្តស្វាមីភក្តិ ចំពោះក្រសួងកែខៃរណសិរ្សរួម ។

នៅអង្គការទាំងនេះ ជីចេងចាស្វ នាយករងមុនដំបូង ក្រោយ មក បានទទួលតំណែងជានាយក ចៅភូជូ លេខាធិការ និង ស្វីចាន លេខាធិការរង ទាំង ៣ រូបនេះ មានការទាក់ទងនឹងចិនកុម្មុយនិស្តយ៉ាង ជិតស្និទ្ធ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណែក ជីចីចាឆាក់ ដែលទទួលតំណែងជានាយកចុងក្រោយបំផុត ជាអតីតនាយករងលើកដំបូង និងជាអតីតប្រធាននៃរដ្ឋាភិបាលមណ្ឌល ជឹងហៃ ៗ ពួកកុម្មុយនិស្ត បានតែងតាំងបុគ្គលនេះ បន្ទាប់ពីបានចាត់តាំងសហពន្ធពុទ្ធសាសនិករួចហើយ ហើយពុំបាននឹកគិតដល់ចៅភូជូ និងស៊ូចាន ដែលជាអ្នកអាចកាន់តំណែងនាយកសក្តិសមជាងព្រោះលោកបានត្រូវតែងតាំងជា លេខាធិការ និងជាលេខាធិការរងដែលទុកដូចជាអ្នកកាន់បង្ហៀរនៃអង្គការនេះ ។

ក្នុងពេលដែលកុម្មុយនិស្ត កោះប្រជុំទីប្រឹក្សានយោបាយលើកដំបូង កាលពីខែកញ្ញា ១៩៤៩ នោះ បុគ្គលទាំងពីរនេះ បានទទួលអញ្ជើញទៅចូលរួមប្រជុំ ក្នុងឋានៈជាអ្នកតំណាងអង្គការសាសនា ។ បន្ទាប់មក ចៅភូជូ ក៏បានចូលធ្វើជាសមាជិកនៃគណៈកម្មាធិការជាតិនៃប្រឹក្សានយោបាយរបស់ប្រជាជនចិន ។

តាំងពីបានចាត់តាំងសហពន្ធពុទ្ធសាសនិកមក កិច្ចការផ្សេង ៗ របស់សហពន្ធ ពុំបានទាក់ទងនឹងសាសនកិច្ច នៃព្រះពុទ្ធសាសនាទេ ដូចការផ្សាយសាសនា ការជួយទំនុកបំរុងពុទ្ធបរិស័ទ ក្នុងពិធីផ្សេង ៗ នៃព្រះពុទ្ធសាសនា ឬការសិក្សាព្រះធម៌ ។

www.budinst.gov.kh www.elibraryofcambodia.org

## ៩- បង្គាប់ឱ្យពុទ្ធសាសនិកជន ធ្វើជាឧបករណ៍នយោបាយ

តាំងពីឡើងកាន់អំណាចមក ពួកកុម្មុយនិស្ត បានធ្វើការឃោសនាបញ្ចុះបញ្ចូលខាងនយោបាយជាដរាបមក ដោយធ្វើជាច្រើនលើកច្រើនគ្រា ហើយបង្គាប់ដល់ពុទ្ធសាសនិកជនដែលគេយល់ឃើញថា គ្មានទឹកគិតដល់ផ្លូវលោកសោះនោះ ឲ្យចូលរួមពិភាក្សា នៅគ្រប់ពេលនៃកិច្ចឃោសនា ។ ពុទ្ធសាសនិកជនបានត្រូវកុម្មុយនិស្ត ប្រើធ្វើជាឧបករណ៍នយោបាយ ដូចគ្នានឹងក្រុមដទៃទៀតក្នុងប្រទេសចិន ក្នុងវត្ថុបំណងនឹងបំផ្លាញជីវិតសាសនា និងជំនឿខាងសាសនា នៃបុគ្គលពួកនេះ ។

តទៅនេះ យើងសូមជំរាបអំពីកិច្ចធំដុំខ្លះ ដែលពុទ្ធសាសនិកជនចូលរួមប្រតិបត្តិការជាមួយផងគឺ :

### ក- ចាត់ការឱ្យពុទ្ធសាសនិកជន តស៊ូនឹងអាមេរិកាំងដោយជួយឧបត្ថម្ភកូរ៉េ

ក្នុងពេលដែលស្ថានសិក្សាពុទ្ធសាសនា នៃក្រុងប៉េកាំងប្រជុំ

www.budinst.gov.kh www.elibraryofcambodia.org

គ្នាដើម្បីប្រឹក្សាកិច្ចការបច្ចុប្បន្ន នៅទីស្នាក់ការក្នុងវត្តលៀនលៀងកាលពីថ្ងៃទី ៥ វិច្ឆិកា ១៩៥០ មានការណែនាំឲ្យពុទ្ធសាសនិកជនចូលរួមធ្វើការប្រឆាំងនឹងអាមេរិកាំង ហើយឲ្យជួយគាំទ្រកូរ៉េ ។

ក្នុងកិច្ចពិភាក្សានេះ លូជៀន សមាជិក នៃគណៈនៃស្ថានសិក្សានេះ បានថ្លែងថា « អំពើរាគក្សាគយ៉ាងកំណាច នៃចក្រពត្តិនិយមអាមេរិកាំង ផ្ទុយនឹងគោលព្រះពុទ្ធសាសនា ។ ចក្រពត្តិនិយមទាំងនេះ គឺបិសាចដ៏សាហាវ ដែលកំហែងគំរាមសន្តិសុខនៃមនុស្សជាតិ និងធ្វើឲ្យសន្តិសុខនៃពិភពលោកត្រូវបែកធ្លាយ » ។

ភិក្ខុ មៀយួន បានថែងថា « ការតស៊ូប្រឆាំងនឹងអាមេរិកាំង ហើយគាំទ្រកូរ៉េនោះ នឹងធ្វើត្រឹមតែអំណោយសំដីប៉ុណ្ណោះពុំបានទេ ត្រូវតែធ្វើប្រតិបត្តិការឲ្យសមរម្យទៀត » ។

អ្នករួមប្រជុំម្នាក់ទៀត គឺភិក្ខុ តែចេវ មកពីវត្តជីគលួ បានណែនាំថា « ក្នុងពេលនេះ គ្មានកិច្ចការអ្វីដែលសមរម្យជាងការធ្វើផលិតកម្ម ដើម្បីទំនុកបំរុងរណសិរ្សរួម សំរាប់ប្រឆាំងទល់នឹង អាមេរិកាំងហើយគាំទ្រកូរ៉េនោះទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ចៅអធិការវត្ត ជីធៀង បានណែនាំថា « ការចាត់តាំងក្រុមបឋមព្យាបាល ក៏ជាប្រយោជន៍ដូចគ្នា »

ភិក្ខុ កូលៀង បានថ្លែងថា «ក្រោយពីការខំប្រឹងខ្លាំងណាស់ដើម្បីធ្វើផលិតកម្ម និងការចាត់តាំងក្រុមបឋមព្យាបាលចេញ គួរធ្វើការឃោសនា ដើម្បីឲ្យអ្នកកាប់អានព្រះពុទ្ធសាសនាទាំងមូលដៀផង » ។

ដោយការណែនាំរបស់កុម្មុយនិស្ត អង្គប្រជុំ ក៏បានធ្វើញត្តិមួយថា ពុទ្ធបរិស័ទគួរគាំទ្រ ហើយបន្ទាប់មក ក៏មានសេចក្តីថ្លែងការណ៍រួមរវាងអង្គប្រជុំនេះ និងគណៈបក្សប្រជាធិបតេយ្យ ពង្រូវឲ្យចាត់ការធ្វើផលិតកម្ម. ឲ្យចាត់តាំងក្រុមបឋមព្យាបាលនិងក្រុមឃោសនា ដើម្បីប្រឆាំងទល់នឹងអាមេរិកាំង ហើយគាំទ្រ កូរ៉េ ដើម្បីរក្សាប្រទេសជាតិផង ។

ដោយមានញត្តិដូច្នេះ ពួកកុម្មុយនិស្ត ក៏រើសយក ភិក្ខុ ភិក្ខុនី ហើយចាត់ជាក្រុមបឋមព្យាបាល និងក្រុមអប់រំចិត្ត ដើម្បីបញ្ជូនទៅកាន់កូរ៉េ ខាងជើង ។ មិនយូរប៉ុន្មាន ពុទ្ធសាសនិកជនក្នុងខេត្តដទៃ ៗ ក៏បានត្រូវធ្វើដូច ៗ គ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងពេលជាមួយគ្នានោះ ការដែលពុទ្ធសាសនិកជន ចូលទៅរួមក្នុងពិធីនិយាយលើកទឹកចិត្តទាហាន និងការដង្ហែក្បួន ក្នុងខេត្តផ្សេងៗ ក៏ក្លាយទៅជាព្រឹត្តិការណ៍ធម្មតាសាមញ្ញ ។

ហេតុការណ៍ទាំងប៉ុន្មាននេះ បានបញ្ជាក់ឲ្យឃើញថា ពួកកុម្មុយនិស្ត បានបង្ខំយកភិក្ខុនិងភិក្ខុនី ទៅធ្វើជាឧបករណ៍នយោបាយឲ្យប្រព្រឹត្តខុសនឹងព្រះវិន័យ ដូចរាប់រៀបខាងលើនេះ ។

## ខ- សង្គ្រាមសន្តិភាព

តមកមិនយូរប៉ុន្មាន សហភាពពុទ្ធសាសនិក ក៏បានលើកយក « កិច្ចការរួមសង្គ្រាមសន្តិភាព » មកធ្វើទៀត ។ ក្នុងពេលដែលពួកកុម្មុយនិស្តចាត់ឲ្យមានកិច្ចប្រជុំសន្តិភាព សម្រាប់ភូមិភាគ អាស៊ីនិងប៉ាស៊ីហ្វិក នៅប៉េកាំង កាលពី គ.ស ១៩៥២ នោះ ភិក្ខុ ឃួន យិន បានទទួលការតែងតាំងជាអ្នកតំណាងម្នាក់ក្នុងកិច្ចប្រជុំ ៥ ខែ ។

បន្ទាប់មក ភិក្ខុនេះ បានសរសេរអត្ថបទចុះផ្សាយក្នុងកាសែត « ប្រជាជន» ដែលចេញរាល់ថ្ងៃនៅប៉េកាំង និយាយអំពីកិច្ចប្រជុំនិង អំពាវនាវឲ្យពុទ្ធសាសនិកជនព្យាយាមរក្សាសន្តិភាព ។

www.budinst.gov.kh www.elibraryofcambodia.org

អត្ថបទនេះមានសេចក្ដីថា៖

៤ ពុទ្ធសាសនិកជន គួរមានចិត្តគិតធ្វើកិច្ចការ ដើម្បីសង បំណុលមេត្តា ករុណា របស់ប្រជាជន និងជួយប្រជាជនឲ្យផុតពីសេចក្ដីក្ដៅក្រហាយ ។ កិច្ចពិសេសចំពោះការរុករាន និងរក្សាសន្តិភាពនោះ គួរជាជំហានពិតប្រាកដដែលយើងត្រូវបំពេញក្នុងពេលនេះ ដើម្បីសងបំណុលនៃមេត្តា ករុណា របស់ប្រជាជនដែលមានដល់យើងក្នុងអតីតកាល និងដើម្បីជួយទំនុកបំរុងដល់អ្នកដែលបានទទួលសេចក្ដីក្ដៅក្រហាយ ។

យើងជឿជាក់ថា អ្នកដែលរាប់អានសាសនាយ៉ាងខ្លាំងនោះ គួរធ្វើជាទូតសន្តិភាព ហើយជាពិសេសទៅទៀត យើងជឿថា ធម៌រមែងឈ្នះអធម៌ សេចក្ដីអាណិតអាសូរ រមែងឈ្នះសេចក្ដីស្អប់ខ្ពើម ហើយសន្តិភាពរមែងឈ្នះការឈ្លានពានក្នុងទីបំផុត ។

កិច្ចប្រជុំនៃអ្នកទំនុកបំរុងសន្តិភាពនៃពិភពលោក ដែលត្រូវចាត់ឲ្យមានឡើងនៅក្រុងតូក្យូ កាលពីខែមេសា ១៩៥៤ បានហុចឱកាសឲ្យចិនកុម្មុយនិស្ដមួយលើកទៀត ប្រើពុទ្ធសាសនិកជនជាមេ

អណ្តើកសំរាប់ឃោសនា ។ ផូ ចាន និងចៅ ភូជួ បានលាតត្រដាង នូវអត្ថបទនៃទូរលេខមួយច្បាប់ ដែលជំទាស់ចំពោះសន្ធិសញ្ញាការពារ រួមគ្នា នៃសហរដ្ឋអាមេរិកនិងជប៉ុន ។ ទូរលេខនេះបានត្រូវសហពន្ធ សាសនិកបញ្ជូនទៅឲ្យដោយចំនួនយ៉ាងច្រើន ។

រដ្ឋាភិបាលកុម្មុយនិស្ត ពុំព្រមបណ្តែតបណ្តោយ ការឆ្លៀត ឱកាសប្រើសហពន្ធពុទ្ធសាសនិកឲ្យបំពេញប្រយោជន៍ ដល់ការឃោ-សនានោះឡើយ ។

ក្នុងឱកាសប្រជុំពុទ្ធិកសមាគមពិភពលោកជាច្រើនលើក ដែលមានអ្នកតំណាងពុទ្ធសាសនានៃក្រុងប៉េកាំងចូលរួបរួមផង អ្នកតំ ណាងនេះតែងតែឃោសនាបំរើនយោបាយនៃរដ្ឋាភិបាលខ្លួន ដោយ យកសន្តិភាពនោះមកធ្វើជាមូលដ្ឋាននៃការឃោសនា ហើយបង្កើត ឲ្យមានការបែកបាក់គ្នាកាន់តែខ្លាំងឡើង នៅក្នុងផ្ទៃនៃពុទ្ធិកសមាគម ពិភពលោក ។

ដោយក្រុងប៉េកាំង បានយកភិក្ខុនិងភិក្ខុនីដែលខ្លួនអប់រំ ឲ្យ ទៅជាកុម្មុយនិស្តស្រេចហើយ យកមកឲ្យស្នាក់អាស្រ័យនៅប្រទេស

www.budinst.gov.kh www.elibraryofcambodia.org

នានា ដែលមានអាណិកជនចិននោះ គេអាចយល់បានណាស់ថា ក្រុងប៉េកាំងមានបំណងនឹងអប់រំអាណិកជនចិន នៅបរទេសទាំងអស់ឲ្យទៅជាកុម្មុយនិស្តតាមរយៈនៃព្រះសង្ឃ ដែលក្រុងប៉េកាំងបានចាត់ឲ្យមកបំពេញបេសកកម្មនោះ ។

## ចំពូកទី ៥

## និគមវចនៈ

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជារតនៈត្រៃ នៃព្រះពុទ្ធសាសនាពុំអាចនឹងបំបែកចេញពីគ្នាបានទេ ព្រោះបើបាត់រតនៈវត្ថុណាមួយហើយ ព្រះពុទ្ធសាសនា ក៏គ្មានប្រយោជន៍អ្វី ។

ពាក្យទាំង ៣ ម៉ាត់នេះ មានវត្ថុផ្សេងគ្នា គឺ :

- ព្រះពុទ្ធជាអ្នកត្រាស់ដឹងព្រះធម៌
- ព្រះធម៌ជាអ្នកទ្រទ្រង់សត្វ
- ព្រះសង្ឃជាអ្នកទ្រទ្រង់ព្រះធម៌ នោះក៏ពិតមែនហើយ ក៏ប៉ុន្តែមានអត្ថន័យតែម្យ៉ាងដូចគ្នាគឺ «គ្រឿងពឹងសរណៈឥត្ថ » ដែលមានការជាប់ទាក់ទងគ្នា ពុំអាចនឹងបំបែកចេញពី

www.budinst.gov.kh www.elibraryofcambodia.org

គ្នាគេឥត ហើយពាក្យថាព្រះពុទ្ធសាសនាមួយម៉ាត់នេះ គឺសំដៅយក វត្ថុទាំង ៣ យ៉ាងនេះឯង ។

ក្នុងមហាបរិនិព្វានសូត្រ នៅពេលដែលព្រះសម្មាសម្ពុទ្ធទៀប នឹងចូលកាន់ព្រះនិព្វាន ព្រះអង្គបានទ្រង់ផ្តាំនឹងព្រះអានន្ទថា «អំណើះ ពិតថាគតទៅ ព្រះធម៌ និងព្រះវិន័យទាំងពីរនេះ ជាតំណាងអង្គតថាគត ហើយតថាគតផ្ញើធម៌និងវិន័យនេះនៅលើសង្ឃ ស្រេចតែសង្ឃប្រជុំ សម្រេចទៅតាមកាលៈទេសៈចុះ »

តាំងពីដើមមក ព្រះសង្ឃជាអ្នកផ្សាយព្រះពុទ្ធសាសនា ជា អ្នករក្សាប្រពៃណី និងពិធីនៃសាសនា ដោយសិក្សានិងប្រតិបត្តិនូវពុទ្ធ វចនៈ ។ ដូច្នេះ ព្រះសង្ឃជាឧបករណ៍យ៉ាងសំខាន់សម្រាប់ផ្សាយព្រះ ពុទ្ធសាសនា ។ ប៉ុន្តែ ក្នុងបច្ចុប្បន្ននេះ នៅប្រទេសចិន ដែលកុម្មុយ-និស្តគ្រប់គ្រា ព្រះសង្ឃត្រូវបង្ខំជាត្រូវគេញុះញង់ បំបែកបំបាក់ នឹង បង្ខំឲ្យត្រឡប់ទៅកាន់លោកិយវិស័យវិញ ។

ដោយហេតុនេះ ភិក្ខុ និងភិក្ខុនី នៅប្រទេសចិន បានត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ថយចុំនួនទៅជាលុំដាប់ ។ ក្នុងបច្ចុប្បន្ននេះ នៅវត្តអារាមផ្សេងៗ ក្រៅពីភិក្ខុ និងភិក្ខុនីចាស់ជរា ដែលគ្មានផ្លូវនឹងត្រឡប់ទៅកាន់វិស័យលោកិយវិញ មានតែអ្នកធ្វើនយោបាយទាំងអស់ គឺភិក្ខុ និង ភិក្ខុនី ដែលនៅរស់ទាំងប៉ុន្មាន បានត្រូវគេបង្គាប់ឲ្យធ្វើជាឧបករណ៍នយោបាយរបស់កុម្មុយនិស្ត ។

ក្នុងពេលដែលភិក្ខុ និងភិក្ខុនី មានជីវិតរស់នៅដោយសេចក្ដីលំបាកវេទនា ស្ទើរតែពុំអាចនឹងរស់នៅបាន ដូចម្ដេចនឹងប្រតិបត្តិព្រះពុទ្ធសាសនាកើត ។ ក្រោយពីនេះ ពួកកុម្មុយនិស្តបានប្រើគ្រប់មធ្យោបាយ ដើម្បីស្កះដំណើរកុំឲ្យមានបួសជាភិក្ខុ ឬភិក្ខុនីតទៅទៀត សូម្បីតែពិធីនិងសាសនកិច្ចក្នុងវត្តផ្សេង ៗ ក៏ពុំអាចនឹងធ្វើបានផង ។

ព្រះពុទ្ធអង្គបានទ្រង់ប្រដៅទុកថា បើពុទ្ធសាសនិកជនប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ហើយនឹងបានលុះនូវព្រះនិព្វានប៉ុន្តែក្នុងប្រទេសចិនបច្ចុប្បន្ននេះ ពួកកុម្មុយនីស្តបានចាត់ទុកព្រះធម៌គ្រាន់តែជាវណ្ណកម្មមួយ ដែលមានទស្សនៈខុសពីរបបកុម្មុយនីស្ត ដូច្នេះហើយបានជាហាមមិនឲ្យចំណាយព្រះធម៌ ឬមិនដូច្នេះក៏ដុតចំផ្លាញ

www.budinst.gov.kh www.elibraryofcambodia.org

និងទំលាយព្រះធម៌នោះចោល ។ ជាពិសេសទៅទៀត ពួកកុម្មុយនិស្ត បានផ្លាស់ប្ដូរព្រះធម៌ នៃព្រះពុទ្ធឲ្យចូលនឹងលទ្ធិម៉ាកិស៊ិស្ម-ឡេនីនីស្ម ទៀតផង ( Marxisme.Léninisme ) ។

នៅប្រទេសចិនបច្ចុប្បន្ន ដោយកុម្មុយនិស្តប្រែព្រះសូត្រ ឲ្យខុសពីសេចក្ដីដើម ដូច្នេះពាក្យថា « ពុទ្ធ » ក៏បានសាបសូន្យពី ន័យដើមទៅដូចគ្នាដែរ ។ ក្រោពីនេះ ការគោរពបូជាព្រះពុទ្ធសាសនា ក៏បានត្រូវបង្ខំឲ្យលះបង់ចោល ព្រោះគេបានចាត់ទុកថាជាជំនឿ ព្រេងសំណាង ។

ពោលដោយសរុបទៅ ទោះជាពិនិត្យមើលប្រព្រឹត្តិកម្មរបស់ កុម្មុយនិស្តចំពោះព្រះពុទ្ធសាសនាក្នុងផ្នែកណាក្ដី ក៏ឃើញដូចគ្នាទាំង អស់ គឺកុម្មុយនិស្តបំផ្លេចបំផ្លាញឲ្យអស់ទៅក្នុងទីបំផុត ។ គំនិតនេះពុំ មែនគ្រាន់តែជាការយល់ឃើញនៃបុគ្គលម្នាក់ ៗ ឬយោបល់ផ្ទាល់ ខ្លួននៃអ្នកដឹកនាំកុម្មុយនិស្ត ដែលកំពុងកាន់អំណាចនោះទេ ផ្ទុយទៅ វិញ គឺមានទំនាស់គ្នាខាងផ្នែកមូលដ្ឋានរវាងគោលព្រះពុទ្ធសាសនា និង ប្រាជ្ញាជាន់រូបធម៌នៃលទ្ធិកុម្មុយនិស្តទាំងមូលតែម្ដង ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយហេតុនេះ ទើបគេលែងសង្ឃឹមថា ពួកកុម្មុយនិស្តនឹងអាចប្រគល់ឥស្សរភាពពិតប្រាកដដល់ពុទ្ធសាសនិកជន នៅប្រទេសចិនក្នុងថ្ងៃណាមួយនោះអស់ទៅហើយ ។

ឯយួនកុម្មុយនិស្តដែលចូលមកលុកលុយប្រទេសយើង ក៏ពុំមាននយោបាយអ្វីខុសពីចិនកុម្មុយនិស្ត ដែលជាចៅហ្វាយនាយគេដែរ ។ ហេតុដូច្នេះហើយ បានជាគេចូលមកបំផ្លេចបំផ្លាញវត្តអារាមធ្វើគតព្រះសង្ឃ និងបំផ្លាញស្មសានសាសនាឯទៀត ។ យ៉ាងសន្ធឹកសន្ធាប់ណាស់ ។

ចាប់តាំងពីខែមេសា ១៩៧០ មក ពួកកុម្មុយនិស្តយៀកកុង-យៀកណាមខាងជើង បានព្យាយាមបាញ់កំទេច ឬផុតបំផ្លាញ កំចាត់ព្រះសង្ឃព្រះពុទ្ធសាសនា បព្វជិតខាងកាតូលិក និងអាចារ្យ ទេវិហារខាងសាសនាឥស្លាម ព្រមទាំងកុដិ សាលាសារាយ ព្រះវិហារឲ្យវិនាសបាក់បែក ឬឆេះអស់គ្មានសល់ ។ បដិមាករជាទីគោរពសក្ការៈក៏ត្រូវវាយបំបាក់ និងយកទៅរលាន់ឈ្លីបន្ថោកតម្លៃយ៉ាងឈឺចាប់ ។ គម្ពីរដីកាឬក្បួនខ្នាតផ្សេង ៗ នៅក្នុងនោះ ក៏ត្រូវដុតបំផ្លាញគ្មានសល់ មិនតែប៉ុណ្ណោះ ពួកកុម្មុយនិស្តចាប់ចងធ្វើបាប ឬសម្លាប់ដ៏ឃោរឃៅចំពោះអ្នកប្រតិបត្តិសាសនាទាំងអស់ ដែលមកទល់ដើមឆ្នាំ ១៩៧២ នេះ យើង

www.budinst.gov.kh www.elibraryofcambodia.org

បាននស្រុងទូវការខូចខាតនិងបាត់បង់ដូចតទៅ ៖

-វត្តខាងព្រះពុទ្ធសាសនាដែលត្រូវអន្តរាយមានចំនួន ២៨០ វត្ត

ព្រះសង្ឃដែលវាធ្វើគតយ៉ាងទារុណ ៦២ អង្គ

ព្រះសង្ឃដែលវាធ្វើឲ្យរបួសយ៉ាងទារុណ ១១១ អង្គ

ព្រះសង្ឃបាត់ខ្លួនដោយខ្មាំងចាប់យកទៅ ៣៩ អង្គ

ព្រះសង្ឃភៀសព្រះអង្គទៅនៅភ្នំពេញ ៦០១ អង្គ

-វិហារសាសនាកាតូលិកដែលខូចខាត ១៣ វិហារ

បព្វជិតបាត់បង់ជីវិត ៣ អង្គ

-វិហារសាសនាឥស្លាមដែលខូចខាត ១៣ វិហារ

និងវិហារឬសាលារាយច្រើនទៀតបានខូចខាត តែពុំមានពត៌មានច្បាស់ ។

សរុបសេចក្តីទៅ ឃើញថាទោះបីកុម្មុយនិស្តខំលាក់បំបិទយ៉ាំងណាក្តី ខំឃោសនាអួតអាងថា ខ្លួនជួយទំនុកបំរុងសាសនាក្តី ក៏នៅតែសាកលលោកឃើញច្បាស់ថា កុម្មុយនិស្តឥតត្រូវការសាសនាអ្វីទាំងអស់ ។

-ចប់-

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org